

ះ-ម៉ឹង-ហៅ

17
B-146-1804

# សុភាវធម៌

## តាមកម្មវិធី នៃ សាធារណសិក្សាជាតិ
## នឹង ជាវិជ្ជាពលរដ្ឋទៅ



ឃុត - ម៉ឺន - មឿ

# សុភាវធម៌

តាមកម្មវិធីនៃសិក្សាជាតិ

និងជាវិជ្ជាពលរដ្ឋទូទៅ

បោះពុម្ពលើកទី ៣

រក្សាសិទ្ធិ

*

ព.ស. ២៥០៦ គ.ស. ១៩៦៣

# អំពីសុភាវធម៌ ឬ ភាពសមរម្យ

ក្នុងកម្មវិធីចាស់ ត្រង់អន្លើដែលឥឡូវយើងហៅថា " សុភាវធម៌ " មានបង្អុលឲ្យបង្រៀនអំពីចរិយាសាស្ត្រ ដូចជាមេរៀន អំពីសប្បុរសធម៌ ការគួរសម សម្បជញ្ញៈ ។ល។ ជាដើម ។ គុណសម្បត្តិទាំងនេះ សុទ្ធតែជាពាក្យអរូបពិបាកនឹងពន្យល់បាន ។ ម្យ៉ាងទៀត ទោះបីក្មេងយល់ន័យពាក្យនេះហើយ ក៏នៅតែត្រូវជាទ្រឹស្តីប៉ុណ្ណោះ មិនមែនជាបទឲ្យក្មេងប្រតិបត្តិតាមបានដោយងាយ . . . . .

ក្មេងនៅតូច អាយុពី ៧ ទៅ ១៣ ឆ្នាំ ត្រូវការឲ្យគ្រូណែនាំឲ្យមានទម្លាប់ជាជាងចេះតែពាក្យហើយខ្វះការប្រតិបត្តិ ។ **ឧទាហរណ៍:** ក្មេងទម្លាប់ល្អ បើវារើសបានរបស់អ្វីមួយ វាយកមកជូនលោកគ្រូ ប៉ុន្តែវាមិនទាន់យល់ជាក់អំពីន័យនៃការលួច កុមារនេះត្រូវចាត់ទុកថា ជាកុមារប្រសើរជាងកុមារម្នាក់ទៀត ដែលចេះសូត្រមេរៀនប៉ោច ៗ អំពីទោសនៃការលួច តែបើវារើសបានវត្ថុអ្វីមួយ វាត្រឡប់ជាលាក់ទុកទៅវិញ ។

វិជ្ជាសុភាវធម៌ ជាបង្កើមក្បួនតម្រាទាំងឡាយដែលទម្លាប់កុមារឲ្យមានកាយវិការនឹងសំដីសំដៅសមរម្យ ដើម្បីឲ្យការទាក់ទងរវាងកុមារនឹងអ្នកផងក្នុងសង្គមប្រព្រឹត្ត ដោយសភាពស្រួលល្អ ។

គ្រូមានការជួយឪពុកម្តាយកុមារក្នុងការបង្ហាត់បង្រៀនកុមារនោះ ឲ្យមានទម្លាប់ចេះសំដែងអាការសមរម្យ ខាងកាយវិការនឹងខាងវាចា ។ ទម្លាប់ល្អនេះកុមារកាន់ខ្ជាប់មួយជីវិត ។

ហេតុដែលនាំឲ្យមានសុភាវធម៌ មកតែអំពីធម្មជាតិមនុស្ស ដែលកើតមកហើយត្រូវតែរស់ជាសង្គម ជាមួយនឹងមនុស្សឯទៀត កណ្ដាលធម្មជាតិដ៏ធំធេងនេះ ។

ម្ល៉ោះហើយត្រូវបានការទាក់ទង រវាងមនុស្សនឹងមនុស្ស រវាងមនុស្សនឹងធម្មជាតិ ។ ការទាក់ទងនេះ នាំឲ្យមនុស្សសិក្សាស្គាល់អាត្មាខ្លួនឲ្យច្បាស់ ម្ល៉ោះហើយទៅជាមានបទទាក់ទង មនុស្សនឹងអាត្មាខ្លួនទៀត ។

ការទាក់ទងនេះ បើប្រព្រឹត្តឡើងដោយមិនមានភាពសមរម្យ និស្ស័យដូចដុំកង់ដែលវិលដោយគ្មានប្រេង រមែងមានការទង្គិច ការសៅហ្មងជានិច្ច ។

សុភាវធម៌មិនមែនជាបទអនាម័យ មិនទាន់ជាបទចរិយាសាស្ត្រខ្ពស់ ៗ នោះទេ គ្រាន់តែជារបៀបរៀបសុភាពមនុស្សឲ្យមានការសមរម្យខ្លះ សមនឹងភ្នែក សមនឹងត្រចៀក សមនឹងទម្លាប់អ្នកផង ដែលយើងត្រូវរស់ជាមួយ ដើម្បីចៀសវាងកុំឲ្យមានការចាស់ភ្នែក ចាស់ត្រចៀក នឹងការទង្គិចរវាងមនុស្សដែលរស់ក្នុងសង្គមជាមួយគ្នា ។

<u>ឧទាហរណ៍</u>: សន្មតថាមនុស្សម្នាក់ ជាអ្នកគ្មានបដិបត្តិសាសនាទេ ដល់មនុស្សនោះទៅក្នុងចំណោមដែលគេសូត្រធម៌ទាំងអស់គ្នា ច្បាប់សុភាវធម៌បង្គាប់មនុស្សនោះឲ្យរៀនសូត្រធម៌នឹងគេដែរ ( ចូលស្ទឹងតាមបត់ ... ) គួរដាក់ខ្លួនឲ្យចូលចុះជាមួយគ្រប់ចំណោមមនុស្ស កុំនៅស្ងៀមប្លែកពីគេ ទោះការដែលគេកំពុងធ្វើនោះខុសនឹងទំនៀមទម្លាប់ ឬចំណូលចិត្តយើងក៏ដោយ ។

មូលដ្ឋានមួយបែបទៀតដែលនាំឲ្យមានសុភាវធម៌ ព្រោះធម្មជាតិមនុស្សជាសត្វខ្ពស់ ជាសត្វមានសម្បជញ្ញៈ ជាសត្វមានសន្ទុះទៅរកសីលធម៌ ជាសត្វមានមនោសញ្ចេតនា ដែលដុសខាត់ឲ្យកាន់តែល្អិត ឲ្យកាន់តែថ្លាណាស់ទៅទៀតមិនឈប់ មិនឈរ ។

លក្ខណសម្បត្តិនៃមនុស្សទាំងប៉ុន្មាននេះឯង ដែលជាមូលដ្ឋានឲ្យមនុស្សបង្កើតសុភាសិត គឺរៀបចំពាក្យទង្គ្នាឲ្យខុសពីការពាក្យទងរវាងសត្វនឹងសត្វ ហើយឲ្យចេះតែមានការជឿនលឿនទៅមុខជាដរាប ។ យើងអាចសង្កេតឃើញថា ក្នុងសង្គមមនុស្សដែលអារ្យធម៌ទន់ទាបនៅឡើយ ដែលសម្បជញ្ញៈនៅស្តួចស្តើងនៅឡើយ សុភាសិតក៏គ្រោតគ្រាតនៅឡើយដែរ ។ ដល់សង្គមកាន់តែចម្រើនទៅ អារ្យធម៌កាន់តែខ្ពស់ សម្បជញ្ញៈកាន់តែដុះដាល សុភាសិតក៏កាន់តែចម្រើន មិនកើតឯង ៗ ដោយគ្មានមូលដ្ឋាននោះទេ សុភាសិតជាប់ទៅនឹងការវិវត្តន៍របស់សង្គមមនុស្ស ។

សង្គមខ្មែរចាកភាពទាសភាពហើយ សង្គមខ្មែរយើងកំពុងតែវិវត្តន៍ទៅកាន់ក្តីចម្រើនទៅកាន់ភាពខ្ពស់ ៗ ដូច្នេះយើងគួរនាំគ្នាសិក្សារឿងសុភាសិតឲ្យស្របទៅតាមដំណើរនៃសង្គមយើង ។

សៀវភៅសុភាសិតនេះ មានបំណងចង់ធ្វើសេចក្តីអត្ថាធិប្បាយទូវកម្មវិធីសិក្សាខាងលើឲ្យបានក្បោះក្បាយ ជួយវែកញែកហេតុផលសុភាសិត ជួយចង្អុលមូលដ្ឋានសុភាសិត ជួយណែនាំរបៀបសុជីវធម៌ តាមខ្មែរនិយមនឹងតាមបរទេសនិយមខ្លះ ដើម្បីជាគ្រឿងជំនួយដល់គ្រូអ្នកបង្រៀនក្មេង ។

សៀវភៅនេះឥតមានបំណងថា ជាក្បួនជាក់លាក់ដាច់ខាតនៃសុភាសិតទេ ព្រោះតាមសេចក្តីយល់របស់យើង សង្គមខ្មែរដែលកំពុងតែវិវត្តន៍ មិនអាចឲ្យយើ ចងបទបញ្ញាសុភាសិតបានឡើយ ព្រោះសុភាសិតនេះឯង ក៏កំពុងតែវិវត្តន៍ ធ្វើដំណើ ទៅជាមួយនឹងសង្គមដែរ ។

ម្យ៉ាងទៀត ដោយយល់ថា សុភាសិតមានបទប្លែក ៗ គ្នា តាមតំបន់ជនប

តាមទំនៀមទម្លាប់ តាមជំនឿសាសនា តាមវណ្ណៈ ។ល។ សៀវភៅយើងនេះនិយាយបានតែបែបជាទុកលំទូទៅ ។ អ្នកណាដែលយល់ថាល្មមប្រតិបត្តិបាន សូមប្រតិបត្តិតាមចុះ អ្នកណាដែលយល់ថា បើប្រតិបត្តិទៅហើយត្រឡប់ជាឆ្គងទៅវិញនោះ សូមកុំអាលប្រតិបត្តិ ឬកុំប្រតិបត្តិតាមតែម្តង ។

រួមសេចក្តី សៀវភៅយើងមានវត្ថុបំណងជាសៀវភៅល្បង ជាសៀវភៅណែនាំ មិនមែនជាសៀវភៅបទបញ្ញត្តិតឹងរឹងនោះទេ ។

# សេចក្ដីណែនាំជាផ្លូវគរុកោសល្យទូទៅ

ដូចបានឃើញស្រាប់ហើយពីខាងដើមនេះ គំនិត ក្នុងការអប់រំសិស្សខាងផ្នែកចរិយា ដែលមានក្នុងកម្មវិធីសិក្សាថ្មី សញ្ញាណដែលសំដែងក្នុងកម្មវិធីថ្មីនោះសោតទៀត ក៏មានការប្រែប្រួលស្ទើរតែទាំងអស់ ។

ដូច្នេះវិធីបង្រៀននៃគ្រូ ក៏ត្រូវមានការប្រែប្រួលជាច្រើនអន្លើដែរដូចជា :

១– ក្នុងកម្មវិធីថ្មីនេះ គ្មានការចែកមេរៀនជាឆ្នាំ-ជាត្រីមាសឬជាខែទេ ។ លោកគ្រូអ្នកគ្រូចង់លើកយកមេរៀនណាមួយមកសន្ទនាជាមួយសិស្សក៏យកចុះ សុំតែឲ្យមេរៀននោះស្របនឹងវ័យសិស្ស ស្របនឹងកាលៈទេសៈ ស្របនឹងលក្ខណៈនៃ-សង្គមជុំវិញសាលារៀន ។

២– ក្នុងការសន្ទនានេះ សុំកុំឲ្យបាត់បង់គំនិតមួយថា : សាលារៀនគ្មានការបង្ខំ គ្មានការរិះគន់ដល់ជនណា ដល់គ្រួសារណា ដល់សង្គមណា ។ សាលារៀនមានតែការស្នើៈ ស្នើផ្ទាល់នឹងសិស្ស ដើម្បីយកយោបល់ពីសិស្សនឹងឲ្យមានការអនុវត្តន៍តាម ស្នើដល់មាតាបិតាសិស្ស ដើម្បីនឹងឲ្យមាតាបិតានោះ ជួយតម្រែតម្រង់ចរិយាសិស្សនៅក្នុងគ្រួសារផង ។

៣– មិនមែនតែក្នុងពេលដែលសំដែងពីសុភាវធម៌ទេ ដែលគ្រូអាចនិយាយពីសុភាវធម៌បាន ។ កាលណាកាលៈទេសៈហុចឲ្យហើយ គប្បីគ្រូមានការរំឭកដាស់តឿនសិស្សភ្លាម ដូចជា៖ ស្លៀកពាក់មិនតាមបែបបទជាសិស្ស សំពះមិនសមត្អែក ខាកស្ដោះក្នុងបន្ទប់រៀន ឬតាមបង្អួច បេះផ្កានៅសួនសាលា ។ ល ។

៤– ក្នុងការបង្រៀនរបៀបនេះ មិនសមលោកគ្រូដាក់មេទន្ទេញឲ្យសិស្សសូត្រចាំមាត់ដូចកាលដើមឡើយ ព្រោះលទ្ធផលបានល្អ ឬពុំបានល្អមិនមែនសន្មតត្រង់ថាសិស្សចាំមេរៀន ឬ មិនចាំទេ គឺ ស្រេចនៅការសង្កេតនៃគ្រូចំពោះភាពសមរម្យសិស្ស តើបានចម្រើន ឬ នៅតែដដែល ឬ មួយថយក្រោយទៅវិញ ។

៥– យើងសុំបង្ហាញមធ្យោបាយខ្លះ សម្រាប់ពិសោធន៍ចរិយាសិស្សដូចមានខាងក្រោមនេះ ៖




ក– នៅក្នុងបន្ទប់រៀន គួរមានប្រអប់ចំហមួយតូចល្មម នៅពីមុខសិស្សដោយមានស្លាកបិទពីលើថា ''របស់រើសបាន,, នេះជាមធ្យោបាយសម្រាប់ពិសោធ សុចរិតធម៌នៃសិស្ស បង្ហាញថាកុមារមិនគប្បីតែបំបាត់របស់គេរើសបានរបស់គេមិនលាក់ទុកជារបស់ផ្ទាល់ខ្លួន ។




ខ– គួរឲ្យមានប្រអប់មួយទៀតមានប្រហោងអាចឲ្យ បញ្ចូលសំបុត្របានហៅថា៖ ''ប្រអប់សំបុត្រស្នើ,, ។ គ្រូណែនាំសិស្សឲ្យមានការស្នើពីហេតុផ្សេង ៗ ដែលមានកើតឡើងនៅក្នុង-

សាលា ឬក្រៅសាលា ក្នុងការអប់រំ ឬក្រៅការអប់រំ អ្វីជាប្រយោជន៍ទូទៅ . . . . សេចក្ដីស្នើណាដែលមានសមហេតុសមផលឬដែលមានសិស្សភាគច្រើនស្នើ គួរគ្រូយកមកពិគ្រោះគ្នាជាមួយនឹងសិស្ស ។ សេចក្ដីខ្លះជាអាថ៌កំបាំងជាចំណុចផ្ទាល់របស់សិស្សម្នាក់ គួរគ្រូមានការពិគ្រោះផ្ទាល់នឹងសិស្សនោះម្នាក់ឯង ។



គ– គួរដាក់នៅទ្វារចូលបន្ទប់រៀន ទ្រនាប់មួយសម្រាប់ជូតជើង ឬទ្រនាប់ស្បែកជើង ធ្វើពីកៅស៊ូ ជក់ដូង ហើយសិស្សនឹងគ្រូអាចធ្វើបាននៅពេលបង្រៀន ហត្ថកម្មៗនេះជាមធ្យោបាយមួយសម្រាប់បញ្ជាក់ក្មេងពីគំនិតថា : បន្ទប់រៀន ឬផ្ទះ ឬកុដិ ព្រះវិហារ ជាទីដែលយើងគួរគោរព មុននឹងយើងចូលយើងគួរក្រឡេកមើលជើង ឬទ្រនាប់ជើងយើងសិន ។ ណែនាំសិស្សឲ្យមានទម្លាប់មួយយ៉ាងប្រសើរ នាំឲ្យកាយវិការនេះយូរទៅ ធ្វើឡើងដោយឯង ៗ ។



ឃ- នៅកៀនមួយនៃបន្ទប់រៀន គួរមានដាក់កញ្ចក់មួយសម្រាប់ឲ្យសិស្សឆ្លុះមើលម្ដងៗ តើមុខមាត់ សក់ក្បាល មានត្រង់ណាមិនសមនឹងក្នែកក្នកជិតខាងឬទេ ៗ

ង- តាមវិធីអប់រំរបៀបក្រុមកាយវិទ្ធ គេបញ្ញត្តឲ្យសមាជិកគេម្នាក់ៗ សំដែងនៅមុខក្រុមគេ នូវអំពើណាដែលជាប្រសើរហើយដែលគេបាន បព្រឹត្តក្នុងមួយថ្ងៃ ៗ ៗ គប្បីគ្រូណែនាំសិស្សក្នុងថ្នាក់ទាំងអស់ឲ្យមានសៀវភៅម្នាក់មួយ ម្នាក់មួយ សម្រាប់ឲ្យសិស្សកត់ត្រា អំពើបែបនេះបើមិនបានរាល់ថ្ងៃក៏បានពីរ-បីថ្ងៃម្ដង ឬមួយសប្ដាហ៍ម្ដង ជាការបញ្ជាក់ដល់សិស្សនូវសេចក្ដីចម្រើននៃសិស្សត្រង់ផ្នែកចរិយា ៗ

ច- នៅទីធ្លាគប្បីមានធុងសម្រាមមួយដែលសិស្សអាចធ្វើបាន ៗ ណែនាំសិស្សឲ្យមានទម្លាប់មួយទៀតយ៉ាងប្រសើរ គឺមិនបោះសម្រាមក្រដាសឥតសណ្ដាប់ធ្នាប់ នាំឲ្យមានការពិបាកបោសសំអាតបន្ទប់រៀន ទីធ្លា ទីងផ្ទះសំបែង ៗ បើម្នាក់ៗ មានទម្លាប់បែបនេះ ឃើញថា ការថែទាំទីលំនៅពុំសូវផ្ដល់ការរវល់ច្រើន ៗ

ឆ- តាមផ្លូវចេញចូលក្នុងសាលារៀន នៅចំណតពោចក្រយានក្នុងសាលា គួរមានដាក់

សញ្ញាខ្វះ របៀបដូចសញ្ញាចរាចរដែលក្រសួងសាធារណការដាក់តាមវិថីទីក្រុង ដើម្បីបង្ហាញថា វិថីនេះរថយន្តអាចទៅមុខបាន វិថីនេះទៅពុំបាន ទីនេះជាចំណតរថយន្ត ទីនេះហាមមិនឲ្យរថយន្តចត ។ នេះមិនមែនគ្រាន់តែណែនាំឲ្យមានរបៀបរៀបរយក្នុងសាលារៀនទេ គឺជាមធ្យោបាយមួយទៀត សម្រាប់ទម្លាប់កុមារ កុមារីឲ្យចេះដើរ ឲ្យចេះជិះកង់នៅក្នុងទីក្រុង ចៀសវាងកុំឲ្យមានគ្រោះថ្នាក់ផងទៀត ។



# ជំពូកទី ១

# សុភាវធម៌នៅឯគេហដ្ឋាន

## មេរៀនទី ១ – គេហដ្ឋាន

ផ្ដើមការសន្ទនា: អ្នកបានឃ្លាតចេញពីផ្ទះអ្នកជាយូរថ្ងៃ ខែណាស់មកហើយ ។ អនុស្សាវរីយ៍អ្វីខ្លះ ដែលមកនៅជិតជាប់នឹងដួងចិត្តរបស់អ្នក ? មនោសញ្ចេតនាអ្នកមានដូចម្ដេចខ្លះ ?

ឧទាហរណ៍បរិយាយ:

គេហដ្ឋាននេះសំដៅ គេហដ្ឋានដែលមានន័យឆ្ងាយទូលាយមិនមែនគ្រាន់តែផ្ទះសំបុក ឈើឬស៊ីម៉ង់ត៍ជាម្លប់ជ្រកកោនប៉ុណ្ណោះទេ គឺសំដៅគេហដ្ឋានខាងផ្លូវសម្ភារៈផង ខាងផ្លូវចិត្តផង ។

ខាងផ្លូវសម្ភារ ផ្ទះជាអាគារមួយ ដែលកុមារកើតមកហើយបានជ្រកកោនបានរស់នៅទីនោះ ។ ក្មេងកុមារបានឃើញគេហដ្ឋាននេះជាលើកដំបូងបានជាប់អារម្មណ៍ដឹងថា ទីនេះអញបានស្រួល អញបានសប្បាយ អញបានរស់ធំ ។

ខាងផ្លូវចិត្ត ផ្ទះជាកន្លែងដែលជាប់ចិត្ត ដែលមានទម្លាប់នៅទីនោះនាំឲ្យរឭក នាំឲ្យស្រឡាញ់ហើយនាំឲ្យគោរព ។ ផ្ទះខ្មែរខ្លះ មានរៀបតាំងអាសនៈព្រះពុទ្ធ ដែលមានព្រះពុទ្ធរូប ជួនកាលបុប្ផា ជួនកាលមានភ្លើងធូប ឬភ្លើងប្រទីបអុជឆេះជាអលដ្ឋី ។

គេហដ្ឋាន ដំបូងជាទីជ្រកកោន រួចមកជាទីស្រឡាញ់ រហូតដល់ជាទីគោរព ។

អារ្យធម៌អឺរ៉ុបនិយមទុកគេហដ្ឋាននេះ ជាទីជាប់ចិត្តដ៏ក្រៃលែង ។ ពាក្យគេហដ្ឋាន អង្រួនសន្ដានចិត្តគេ ស្មើនឹងពាក្យអនុស្សាវរីយ៍ក្រុមញាតិ ។

ម្យ៉ាងទៀត របៀបអប់រំ គេលៃលកឲ្យកូនទីមួយ ៗ មានបន្ទប់មួយម្នាក់ ដែលវាអាចរៀបចំទុកដាក់ទៅតាមចិត្ត ទៅតាមរស ទៅតាមគំនិតរបស់វា ៗ បន្ទប់នេះជាសញ្ញាតម្លៃផ្ទាល់ខ្លួនរបស់វា ដែលជារូបនិមិត្តនៃចារឹក ចរិយាឧត្តមគតិ និងបុគ្គលិកលក្ខណា របស់វា ៗ

សិស្សគប្បីយល់ជម្រៅគេហដ្ឋាន ទៅតាមន័យដែលបានអធិប្បាយខាងលើនេះៗ

## មេរៀនទី ២ – កូននឹងឪពុក-ម្ដាយ

ផ្ដើមការសន្ទនា: អ្នកអានមិត្តម្នាក់ដែលចេះគោរពមាតាបិតា ព្រោះធ្វើឲ្យមាតាបិតាសប្បាយចិត្តជានិច្ច ។ សុនិយាយពីកាយវិការ សំដី សំដៅ មិត្តនោះនៅក្នុងគ្រួសារគេ ។

### ឧទាហរណ៍បរិយាយ:

នៅក្នុងផ្ទះ មានឪពុក-ម្ដាយ ជាមេជាអ្នកធំ ។ ចំពោះឪពុកម្ដាយ កូនត្រូវមានសុភាវធម៌យ៉ាងណាខ្លះ ?

ជាគិច្ចឧកាលទូទៅ កូនត្រូវស្រឡាញ់ឪពុក-ម្ដាយ ។ ស្រឡាញ់ហើយ ត្រូវគោរពៈលោកទាំងពីរទៀត ។ ដូច្នេះ បើឪពុកម្ដាយហៅ ត្រូវឆ្លើយ "បាទម្ចាស់", ហើយរត់មកជិតលោកភ្លាម ដោយញញឹមញញែមហើយចាំស្ដាប់គាត់មានប្រសាសន៍ រួចធ្វើតាមបង្គាប់គាត់ដោយទឹកមុខស្រស់ ។

ត្រូវប្រុងស្ដាប់ឪពុក-ម្ដាយហៅ ហើយធ្វើតាមបង្គាប់គាត់ដោយញញឹម ។ ហៅមិនឆ្លើយ ឬហៅមិនមក មកហើយមិនធ្វើតាម ឬធ្វើតាមដោយទឹកមុខក្រញូវ ជាទំនាស់ទឹងសុភាវធម៌ ។

ការចេះលៃឲ្យមានការទាក់ទងរវាងកូន នឹងឪពុក ម្ដាយ ដោយសំដី ដោយកាយវិការខ្លះ តាមពេលដែលធ្វើបានមិនងប់ជ្រុលច្រើនពេក ឬតិចពេក ទុកជាភាព-សមរម្យមួយ ក្នុងគ្រួសារទំនើប ដែលគេឲ្យឈ្មោះថា "សុភមង្គលក្នុងគ្រួសារ" ។

## មេរៀនទី ៣ – គោរពនិងបំរើឪពុកម្ដាយ

**ផ្ដើមការសន្ទនា:** អ្នកបានប្រព្រឹត្តដូចម្ដេចខ្លះចំពោះមុខឪពុក ម្ដាយអ្នក មុននឹងចេញពីផ្ទះមកសាលារៀន ? នៅពេលត្រឡប់ពីសាលាទៅដល់ផ្ទះវិញ ?

**ឧទាហរណ៍បរិយាយ:**

*កូនគប្បីមកជំរាបសួរឪពុក - ម្ដាយ ដោយធ្វើកាយវិការសំពះសួរ នៅពេលដែលភ្ញាក់ពីដំណេក ពេលមុនទៅសាលារៀន នៅពេលដែលត្រឡប់មកពីសាលារៀនវិញ និងនៅពេលទៅចូលដំណេក កូនអាចនិយាយថា : " លោកប៉ា ! អ្នកម៉ាក់ ! ខ្ញុំភ្ញាក់ពីគេងហើយ ខ្ញុំទៅរៀនហើយ ! ខ្ញុំមកពីសាលាវិញហើយ ! ខ្ញុំទៅគេងហើយ ! " ។ ឪពុកម្ដាយក៏គួររកពាក្យឆ្លើយឲ្យទន់ទៅកូនវិញ :*

*" កូនគេងស្រួលទេ ? កូនទៅរៀនហើយ ? ទៅសាលាចាំរៀនណាកូន ! កូនរៀនបានលេខល្អទេ ? ទៅគេងចាប់លក់ណាកូន ! " ។*

*នៅប្រទេសអឺរ៉ុប មានបារាំងសែស មានអង់គ្លេសជាដើម កិច្ចនេះកូននិងម្ដាយឪពុក ប្រព្រឹត្តជារាល់ពេល ។ តាមទំនៀមគេ ឪពុកម្ដាយថើបកូន កូនថើបឪពុកម្ដាយ ។*

*នៅប្រទេសអាស៊ីខ្លះ ដូចជាប្រទេសជប៉ុន កូនៗគោរពឪពុកម្ដាយ ដោយធ្វើកាយវិការ ឱនក្បាល ។ តាមតំបន់ជនបទ តាមកាលៈទេសៈ តាមឋានៈគ្រួសារ តើខ្មែរយើងត្រូវចាប់ប្រតិបត្តិយ៉ាងណា ? ។ ការគោរពនិងការស្រឡាញ់ឪពុកម្ដាយ ត្រូវសំដែងចេញ តាមកាយវិការ និងតាមពាក្យសំដី រាល់ពេលវេលាដែលគួរធ្វើបាន ដូចជានៅពេលឪពុកម្ដាយប្រើបន្តិចបន្តួច ៖*

– ហុចផ្តិល ហុចក្រមា យកឈើគូស យកកាសែត ។

– ពេលឪពុកម្តាយមានភ្ញៀវ បើលោកឲ្យគោរពភ្ញៀវ តោងធ្វើតាមភ្លាម បើលោកឲ្យអង្គុយជិត ឬឲ្យទៅលេងឆ្ងាយ ក៏ត្រូវតែធ្វើតាម ដោយទឹកមុខរីករាយ ។

## មេរៀនទី ៤

## ទៅណា មកណា ជំរាប ឪពុកម្ដាយ

ផ្ដើមការសន្ទនា : ពីម្សិលមិញជាថ្ងៃឈប់ ចៅ សុខ បាត់ពីផ្ទះដោយគ្មានដំណឹង ។ ម្ដាយ ចៅ សុខ ភ័យទំផ្ទេធ្លាដើរសួរគេសួរឯង រហូតដល់ថ្ងៃត្រង់ទើបចៅ សុខ ត្រឡប់ពីដើរលេងវិញ ។ អ្នកយល់ដូចម្ដេចចំពោះអាកប្បកិរិយាចៅ សុខ នេះ ?

ឧទាហរណ៍បរិយាយ :

កាលណាគេកូនមិនឃើញ ឪពុកម្ដាយតែងមានក្ដីបារម្ភជានិច្ច ដូច្នេះមុននឹងទៅណាមកណា កូនត្រូវជំរាបឪពុក-ម្ដាយឲ្យលោកជ្រាប ។ បើលោកមិនឲ្យទៅ ហើយយើងនៅតែចង់ទៅ ត្រូវរកពាក្យពន្យល់ដោយការគួរសមឲ្យលោកស្ដាប់បាន ជំរាបលោកពីដំណើរដែលយើងទៅ ទៅទីណា ? ជួបនរណា ? ពេលណាមកវិញ ? ហើយមានផលប្រយោជន៍យ៉ាងណា ? ។ កូនដែលធ្វើឲ្យឪពុក-ម្ដាយព្រួយដោយសារពីរឿងទៅណាមកណាមិនប្រាប់ ពីរឿងមានជម្ងឺហើយមិនប្រាប់ ទុកជាខុសបទគរុការវធម៌ដែរ ត្រង់អន្ទើដែលកូនបានធ្វើអំពើជាហេតុនាំឲ្យឪពុកម្ដាយមិនសប្បាយ ។

តាមទំនៀមទម្លាប់ខ្មែរពីរឿងទៅបាត់ពីផ្ទះគ្មានដំណឹងនេះ ចំពោះកូនស្រីជារឿងនាំឲ្យឪពុកម្ដាយព្រួយខ្លាំងទៅទៀត ។

ជាបទនិទាន : ចំពោះក្មេងអាមេរិកាំង បើបាត់ពីផ្ទះឪពុកម្ដាយមែននឹកភ្លាមថាមានពួកចោរចាប់កូន ដើម្បីឲ្យម្ដាយឪពុកយកលុយទៅលោះដោយស្ងាត់ ។ ចំពោះក្មេងជប៉ុន ឪពុកម្ដាយភ័យពីរឿងបាត់កូន ក្នុងគ្រោះថ្នាក់ព្យុះ ឬរញ្ជួយផែនដី ។

បំពោះក្មេងខ្មែរ     ពីដើមឪពុកម្ដាយភ័យនឹងប្រមាត់ប្រមង់ចាប់ ៗ     រឿងនេះជារឿង

មិនពិតទេ     ឥឡូវនៅទីក្រុងធំ ៗ ឪពុកម្ដាយភ័យអំពីគ្រោះថ្នាក់ខាងចរាចរ លង់ទឹក

ឆ្កែឆ្កួតខាំ ៗ

## មេរៀនទី ៤ – ជួយធ្វើការផ្ទះ

**ផ្តើមការសន្ទនា :** ក្នុងការជួយសំរាលបន្ទុកកិច្ចការនៅក្នុងគ្រួសារអ្នក តើអ្នកមានភារៈត្រូវធ្វើអ្វី ? បងប្រុសអ្នក ? អ្នកសប្បាយចិត្តនឹងធ្វើកិច្ចការនោះឬទេ ? ។

**ឧទាហរណ៍បរិយាយ :**

នៅក្នុងផ្ទះដដែល រមែងមានការធ្វើបត្តិបត្តជានិច្ច ។ កូនក្មេងត្រូវជួយធ្វើការនោះ ដោយមិនមើលបំណាំ បងប្អូនឯទៀតនឹងអ្នកនៅជាមួយ ។ ការនោះមានដូចជា ស្រោចផ្កា បោសទីធ្លាផ្ទះ រៀបតុបាយ ។ល។

គ្រួសារទាំងនេះខ្លះ មេផ្ទះចែកការដល់កូនឲ្យដាច់មុខពីគ្នា នេះជាការប្រសើរមួយបែបដែរ ។

**ឧទាហរណ៍ :** បងស្រីដាំបបរ ប្អូនស្រោចផ្កា ប្អូនឯទៀតបោសដណ្តើរ ឬបើកបង្អួច ជូតតុទូជាដើម ។

មានពេលខ្លះបងប្អូនមានធុរៈ បំពេញការរបស់ខ្លួនមិនបាន ក្មេងជាបទ សុភាវធម៌ ត្រូវជួយបងប្អូននោះផង ។ កិច្ចនេះជាមធ្យោបាយដឹកនាំសិស្សកុំឲ្យមានអត្តទត្តភាព គឺ គិតតែខ្លួនម្នាក់ឯងឲ្យបានស្រួលជាងគេ ។ ផ្ទុយទៅវិញ នាំសិស្សឲ្យមានចិត្តជួយរំលែកការគេទៅទៀត ដោយទឹកមុខរីករាយ ។

## មេរៀនទី ៦ – សណ្ដាប់ធ្នាប់ក្នុងគេហដ្ឋាន

**ផ្ដើមការសិក្សា:** បងប្រុសអ្នកឬឪពុកអ្នកប្រកាន់សណ្ដាប់ធ្នាប់នៅទីកន្លែងគាត់ណាស់ក្នុងផ្ទះ។ មានថ្ងៃមួយ ប្អូនអ្នកដែលនៅក្មេងរពឹសពៃ បានធ្វើឲ្យរបស់ខ្លះក្នុងបន្ទប់គាត់ផ្លាស់កន្លែង ។ តើមានកើតហេតុអ្វីខ្លះ នៅក្នុងគ្រួសារបន្ទាប់ពីនោះមក ?

**ឧទាហរណ៍បរិយាយ:**

នៅក្នុងផ្ទះ រមែងមានការរៀបចំឲ្យសមសួនជាកន្លែងទទួលភ្ញៀវ ជាបន្ទប់សម្រាប់ដេក ជាដើមគ្រាន់ ៗ ល ។ របៀបនេះ នាំឲ្យវត្ថុនិមួយ ៗ មានកន្លែងច្បាស់របស់វា ចានដាក់ដោយចាន វែកដាក់ដោយវែក ក្រមាដោយក្រមា ។ បើក្មេងយករបស់អ្វីមួយមកប្រើប្រាស់ ប្រើរួចហើយត្រូវយកទៅដាក់កន្លែងវាវិញកុំឲ្យគេពិបាករក ។

ម្យ៉ាងទៀត ម្នាក់ ៗ ត្រូវជួយរៀបចំផ្ទះឲ្យមានសណ្ដាប់ធ្នាប់ ឃើញទាស់ភ្នែកហើយកុំដើរហួស ។ រឿងសិស្សទីងរបស់របរនេះ អាចពន្យារធ្លាយទៅខាងផ្លូវមនោសញ្ចេតនា ខ្លះជាប់ចិត្តយ៉ាងខ្លាំងលើរបស់នេះ ហើយត្រូវដាក់កន្លែងនេះ ។ ក្មេងមិនត្រូវទៅបង្ខិតរបស់គេ ឲ្យខុសកន្លែងបំណាំរបស់គេឡើយ ។ មិនតែប៉ុណ្ណោះ បើមានឱកាសធ្វើបាន គួររករបស់ដែលបងប្អូនស្រឡាញ់ផ្ដល់ឲ្យបងប្អូនផង ។

**ឧទាហរណ៍ :** បើបងស្រីយើងស្រឡាញ់ផ្កាកុលាប បើយើងបានផ្កាកុលាប គួរយកទៅឲ្យបងយើង ដើម្បីបងយើងបានសប្បាយ ។

## មេរៀនទី ៧ — កិច្ចចំពោះគេហដ្ឋាន

ផ្ដើមការសិក្សា: នៅក្នុងភូមិគេហដ្ឋានអ្នក មានរុក្ខជាតិទើបនឹងមានផ្កាលើកដំបូង ឬទើបនឹងមានផ្លែ ។ មានក្មេងអ្នកជិតខាង ឬភ្ញៀវបេះផ្កា ឬផ្លែនោះ ។ តើអ្នកអន់ចិត្ត ឬទេ ?

— ម្ដេចបានជាខ្មែរយើងហាមមិនឲ្យបង្ហើរខ្លែងនៅជិតផ្ទះ ?

### ឧទាហរណ៍បរិយាយ:

យើងបានឲ្យន័យពីគេហស្ថានរួចមកហើយ ឥឡូវនេះ អាស្រ័យទៅតាមន័យនោះ ក្មេងត្រូវគោរពគេហស្ថាន ។ គេហស្ថានត្រូវរៀបឲ្យស្អាតដូច្នេះ ត្រូវជួយបណ្ដុះ ជួយតាក់តែងឲ្យល្អ ។ មុននឹងឡើងផ្ទះត្រូវជូតជើងឲ្យស្អាត ដោះស្បែកជើង បើទំនងត្រូវឲ្យដោះ ដូចជាទំនៀមនៅស្រុកជប៉ុន ទំនៀមនៅវត្ត ។ ក្មេងប្រុសត្រូវដោះមួកជាការគួរសម ពេលចូលដល់ផ្ទះ ដាក់កាពក្រៅឲ្យសមរម្យ សំដីសំដៅឲ្យសមរម្យ ។ រឿងដំណើរជាងនេះទៅទៀត គឺបេះនាំក្មេងឲ្យដាក់ចិត្តថា វានៅចំពោះមុខផ្ទះគេមួយដែលជាទីសុខសាន្ត ជាព្រលឹងរបស់គ្រួសារគេ ។

ទោសដែលក្មេងមិនគោរពផ្ទះមានដូចតទៅ :

— បង្ហើរខ្លែងមកទើរលើដំបូលផ្ទះគេ

— បាញ់គ្រាប់ចំពាមកៅស៊ូឲ្យត្រូវផ្ទះគេ

— ដើរបេះបោចផ្លែឈើក្នុងរបងផ្ទះគេ ។ល។

## មេរៀនទី ៨ –
## ឲ្យដំណឹងមុននឹងចូលទៅតាមផ្ទះណា

ផ្ដើមការសន្ទនា: ឲ្យសិស្សប្រាប់កាយវិការភ្ញៀវពីរនាក់ : ម្នាក់ចូលមកផ្ទះគេដោយគោះច្បាប់ទម្លាប់ ម្នាក់ទៀតដោយមិនដឹងក្បួនទម្លាប់ ។ នាំសិស្សឲ្យឃើញដោលពីហេតុផលល្អ ឬ អាក្រក់នៃអាកប្បកិរិយាទាំងពីរបែបនេះ ។

ឧទាហរណ៍បរិយាយ:

មកដល់មាត់ទ្វារផ្ទះគេហើយ ធ្វើឲ្យគេដឹងសិន ៖ តាមការស្រែកហៅដោយទន់ភ្លន់ លោកអ៊ុំម្ចាស់ផ្ទះនៅឬទេ ? តាមការគោះទ្វារបៀបទំនើបយ៉ាងណាក៏មិនត្រូវចូលស្ងាត់ៗ ឲ្យសោះ ។

ទោសនៃការចូលផ្ទះគេដោយម្ចាស់ផ្ទះគេមិនដឹង នាំឲ្យគេកើតមន្ទិលសង្ស័យក៏មាន តែសំខាន់បំផុត គឺយើងអាចទៅរំខានដល់ការផ្ទាល់ខ្លួនរបស់គ្រួសារគេ ។

ស្រែកសួរគេហើយ ឬគោះទ្វារហើយ ចាំស្ដាប់គេឲ្យដំណឹង តើគេឲ្យចាំបន្តិច ឬគេឲ្យចូលភ្លាម ។

រឿងនេះមានសារៈសំខាន់ចំពោះការិយាល័យនៃអ្នកធំៗ ដល់ចូលទៅហើយ ក្មេងត្រូវកាន់អាកប្បកិរិយាតាមសភាពផ្ទះគេទៀត ៖ អង្គុយកន្លែងឲ្យសមរម្យ អង្គុយបែបដូចម្ដេច ( លើកៅអី លើក្ដារផ្ទៀ ឬលើរនាប ) ។

បើលើផ្ទះគេ ឃើញមានការទាស់ក្នុក យើងកុំនិយាយ ហើយមើលចិត្តអ្នកម្ចាស់ផ្ទះ ពេលណាដែលយើងត្រូវលាគេចេញមកវិញ ។ នៅផ្ទះគេកុំយូរពេក កុំឆាប់ពេក មើលអធ្យាស្រ័យគេផង មើលក្រែងយើងរំខានគេដោយគេមានរវល់ផង ។

# មេរៀនទី ៤ - ភាពបងប្អូនប្រុស - ស្រី

**ផ្ដើមការសន្ទនា :** គ្រូនិយាយរៀបរាប់ពីអាកប្បកិរិយាក្មេងមួយ ដែលចេះដឹងទុក្ខធុរៈបងប្អូនប្រុសស្រី អាកប្បកិរិយាក្មេងមួយទៀតដែលមិនដឹងទុក្ខធុរៈបងប្អូនប្រុសស្រី ។

– ភាសាយ៉ាងណាដែលត្រូវប្រើរវាងបងប្អូនស្រី ?

– កំហុសបងប្អូនយ៉ាងម្ដេច ដែលគួរលោកមួយដងមួយយាមបាន ?

## ឧទាហរណ៍បរិយាយ :

*រវាងបងប្អូនប្រុសនិងស្រី ក្មេងត្រូវរក្សាឫកពារីករាយនឹងគ្នា គឺត្រូវចៀសវាង :*

*– ធ្វើទឹកមុខក្រញូវ ចងចិញ្ចើម អង្គុយធ្មឹង សួរមួយម៉ាត់ និយាយមួយម៉ាត់*

*– រំខានបងប្អូន ដោយកាយវិការ ដោយប្រើសំដីមិនសមរម្យ*

*- មានចិត្តឈ្នានីះ មិនចង់ឲ្យបងប្អូនសប្បាយជាង ឬស្រួលជាង ប្រណែន ចាក់រុក ជួយទៅវិញ ត្រូវបង្កើតឲ្យមានបរិយាកាសរីករាយដោយ :*

*– ធ្វើទឹកមុខស្រស់ញញឹម, ធ្វើកាយវិការសមរម្យ ចំពោះបងប្អូនប្រុសស្រី ប្រើសំដីទន់ភ្លន់មិនមែនមាយា*

*– ដោយជួយយកអាសាបងប្អូន តាំងពីបម្រើហុចនេះហុចនោះបន្តិចបន្តួច រហូតធ្វើឲ្យបងប្អូនបានសប្បាយដោយសារ មានពេលខ្លះ ជួយលាក់កំហុសបងប្អូនក៏បើងបាន ។*

*ខាងផ្លូវចិត្ត មិនប្រចាំគ្នា មិនប្រណែនគ្នា មិនចាក់រុកគ្នា ។ បងប្អូនប្រុស ចំពោះបងប្អូនស្រី ត្រូវចៀសវាងកាយវិការនិងសំដីសំដៅណា ដំណាស់នឹងការអៀនខ្មាស ចំពោះរវាងភេទនិងភេទ ។*

*– ចំពោះមុខបងប្អូនស្រី និយាយនិងធ្វើតែកាយវិការណា ដែលយើងនិយាយ និងអាចធ្វើបានចំពោះមុខម្ដាយយើង ។*

## មេរៀនទី ១០ – រៀនឲ្យចេះថា „ អរគុណ „

ផ្ដើមការសិក្សា : ទម្លាប់សិស្សឲ្យចេះពោលឲ្យរត់មាត់នូវពាក្យ “ អរគុណ ” នេះ កុំឲ្យនៅធ្មឹងកាលណាបានទទួលអំពើល្អអ្វីមួយនៅគ្រប់កាលវេលា ។

ឧទាហរណ៍បរិយាយ :

ដើម្បីឲ្យការទាក់ទង មានទំនងល្អ ត្រូវទម្លាប់ប្រើពាក្យ “ អរគុណ ” ។ ពាក្យអរគុណនេះ យើងត្រូវថានៅពេលដែល :

– អ្នកម្នាក់ទៀតបានធ្វើអំពើអ្វីជាប្រយោជន៍ដល់យើង អ្នកម្នាក់ទៀតជួយយកអាសាយើងតាមបែបបទណាមួយ ។

ពាក្យថា “ អរគុណ ” នេះ ជាសេចក្ដីដែលមានលក្ខណៈស្និទ្ធស្នាលខ្លះៗ

– កូនសិស្សចំពោះគ្រូត្រូវថា; អរគុណលោកគ្រូ អរគុណអ្នកគ្រូ !

– ចំពោះមិត្ត សិស្សខ្មែរអាចថា: អរគុណណាស់ បង !

បើរឿងយកអាសានេះជារឿងធំ សិស្សត្រូវថា : ខ្ញុំសូមអរគុណ . . . ដ៏ជ្រាលជ្រៅ ដោយលោកឬអ្នកបាន . . . ! (ទៅតាមអំពើដែលគេបានធ្វើ) ។

គេអាចតបនឹងពាក្យ “ អរគុណ ” វិញ នៅពេលខ្វះទំនងចំពោះមនុស្សបានដូចតទៅ :

– មិនជាការធ្ងន់ស្រាលប៉ុន្មានទេ !

– ជាការធម្មតាទេ !

– មិនដឹងជាចាំបាច់អរគុណអ្វីទេ ការប៉ុណ្ណឹង !

តាមកម្មវិធី សុវធម៌នៅឯគេហស្ថាន ចប់តែប៉ុណ្ណេះឯង ។ តែគ្រូ បើឃើញសេចក្ដីអត្ថាធិប្បាយនេះខ្វះដោយអន្ទើខ្វះ អាចបំពេញបានតាមការគួរ ។

## មេរៀនទី ១១ – វិទ្យុនិងគ្រឿងឧគ្ឃោសនសព្ទ

**ផ្ដើមការសន្ទនា :** អ្នកកំពុងតែរៀនមេរៀនមួយ កំពុងតែរកចំណោទមួយដោយពិបាក ស្រាប់តែនៅផ្ទះជិតខាងមានគេបើកវិទ្យុយ៉ាងខ្លាំង ។ តើអ្នកខឹងឬទេ ?

**ឧទាហរណ៍បរិយាយ:**

វិទ្យុនិងគ្រឿងឧគ្ឃោសនសព្ទ មានស្ទើរតែគ្រប់ផ្ទះទៅហើយ នៅទីក្រុងក៏ដូចជាតាមជនបទនានាដែរ ។ តែការប្រើប្រាស់គ្រឿងទាំងនោះដូចជានៅមិនទាន់ប្រកបតាមរបៀបរៀបរយសោះ នៅជាការរំខានគ្នាទៅវិញទៅមក ។

ក្នុងការប្រើគ្រឿងទាំងនោះ (វិទ្យុទទួលសម្លេង ម៉ាស៊ីនច្រៀង . . .) គួរចាំនូវគំនិតខ្លះដូចតទៅនេះ :

– កុំមានគំនិតចង់បង្អួតថាយើងមានរបស់ល្អថ្លៃប្រើ

– កុំបើកឲ្យឮសម្លេងទាល់តែដល់កំរិត បើកល្មមតែពិរោះខ្លួនយើងបានហើយ បើអ្នកជិតខាងគេចង់ស្ដាប់ដែរ ទើបយើងបន្ថែមសម្លេងបន្តិចទៀតចុះ

– រសយើងមិនដូចរសអ្នកជិតខាងយើងទេ ។ យើងចូលចិត្តភ្លេងទំនើប គេចូលចិត្តភ្លេងបូរាណ យើងចូលចិត្តភ្លេងអាស៊ី អ្នកជិតខាងយើង (សំខាន់គឺជនបរទេស) គេចូលចិត្តភ្លេងអឺរ៉ុប ។ ដូច្នេះកុំរំខានគេដោយរសរបស់យើង ។

– ជួនកាល ក្នុងគ្រួសារជាមួយ ឬ អ្នកជិតខាងគេមានទុក្ខមានមនុស្សឈឺ មិនគួរបញ្ចេញការរីករាយរបស់យើងដោយគ្រឿងសម្លេងទាំងនោះឡើយ ។

វឌ្ឍនភាពខ្មែរយើងគេអាចសំគាល់ដោយរបៀបប្រើប្រាស់គ្រឿងឧគ្ឃោសនសព្ទនេះបាន ។

# មេរៀនទី១២ : សារុង សំពត់ខ្មៅ ពីសាម៉ា

ផ្ដើមការសង្កេត : អ្នកយល់ឃើញដូចម្ដេចចំពោះការស្លៀកសារុង ស្លៀកពាក់ពីសាម៉ានៅកន្លែងប្រជុំជន នៅទីសាធារណៈ មានវត្តអារាមជាដើម (សុំពន្យល់ម្ដេចគឺពីសាម៉ា) (១)

## ឧទាហរណ៍បរិយាយ :

ការវិវត្តន៍នៃសង្គមខ្មែរយើងក៏ចេះតែដើរលឿនទៅមុខជាលំដាប់ហើយ ៗ ចំពោះសំលៀកបំពាក់ គួរយើងទទួលយកបែបបទខ្លះដើម្បីឲ្យបានស្របទឹងការវិវត្តន៍នោះ៖

<u>សារុង</u> : ពាក្យសារុងនេះគឺបានមកពីភាសាជ្វា ឯសារុងនេះសោតទៀតក៏ជារបស់ជនជាតិចាមជ្វាដែរ ដែលគេប្រើជាធម្មតារបស់គេ ជាសំលៀកបំពាក់ជាតិរបស់គេ ។ ខ្មែរយើងបើបានជានិយមប្រើទៅហើយ គួរតែប្រើតទៅទៀតចុះ តែគួរណាស់ប្រើនៅតែគេហដ្ឋាន កុំប្រើនៅទីប្រជុំជន មានវត្តអារាម សួនច្បារ តាមផ្លូវជាដើម ។

<u>សំពត់ខ្មៅ</u> : នារីខ្មែរយើងនិយមប្រើសំពត់ខ្មៅនេះជាយូរហើយ ៗ គួរយើងសន្មតថា សំពត់ខ្មៅសំរាប់តែនារីពេញរូបពេញរាងមានផ្ទះសំបែងហើយ ឯនារីជាសិស្សសាលា គួរកុំស្លៀកសំពត់នេះមកសាលា ឬក្នុងទីសាធារណៈនានា ។

<u>ពីសាម៉ា</u> : ជាសម្លៀកបំពាក់របៀបអឺរ៉ុប ប្រើបានតែនៅក្នុងផ្ទះ ស្លៀកពាក់នៅបន្ទប់ដេកផង ៗ ដូច្នេះការប្រើពីសាម៉ានេះនៅទីប្រជុំជនផ្សេង ៗ នៅតាមផ្លូវជាអំពើច្គង់ទឹងសុភាវធម៌ ៗ

---

១– ពីសាម៉ា គឺមានអាវស្ដើងដៃវែង និងខោធ្វើពីកំណាត់សំពត់ដូចគ្នា ជើងវែង ច្រើនមានឆ្នូតៗផង ។



# ជំពូកទី ២

# សុភាវធម៌ចំពោះភ្ញៀវ


២ ទឹកចិត្ត

# មេរៀនទី ១៣ - អ្វីហៅថាភ្ញៀវ

ផ្តើមការសន្ទនា : លក្ខណៈត្រង់ណាខ្លះ ដែលអាចឲ្យគេសន្និដ្ឋានបានថា ខ្មែរយើងមានប្រពៃណីល្អត្រង់ គោរពភ្ញៀវ ចេះទទួលភ្ញៀវ នៅគ្រប់កន្លែង?

## ឧទាហរណ៍បរិយាយ :

ភ្ញៀវពទ្វីសំដៅញាតិឆ្ងាយជិត អ្នកនៅជិតខាង អ្នកនៅភូមិជាមួយ ឬអ្នកដទៃហោះដែលមកផ្ទះយើង ដើម្បីមកលេង សួរសុខទុក្ខ ឬមួយមានការទាក់ទងក្នុងការចិញ្ចឹមជីវិត ឬមួយមកសំណាក់ជារយៈក្នុងការធ្វើដំណើរទៅណាមកណា ៗ

ជាតិខ្មែរមានលក្ខណសម្បត្តិមួយពីបុរាណកាលមក ជាអ្នកចេះទទួលភ្ញៀវដោយស្មោះស ៗ គេតែងសង្កេតឃើញថា ខ្មែរតែងយកសម្ភារៈល្អៗ សម្រាប់ទទួលភ្ញៀវ ៗ

ផ្តិល ប៉ាន់តែ ប្រអប់ស្លា ម្លូ ចានក្បាន រហូតម្ហូបអាហារ ក៏សុទ្ធតែសម្រាំងឲ្យបានល្អជាងធម្មតា . . . ភស្តុតាងធំ ៗ ជាងនេះទៅទៀត គឺនៅប្រទេសខ្មែរ ក្នុងតំបន់ជនបទណាក៏ដោយ រមែងមានសង់សាលាសំណាក់ ទុកសម្រាប់អ្នកដំណើរម្នាក់ ៗ នៅមុខផ្ទះខ្លះមានពាងទឹកដាក់តល់ជូនអ្នកដំណើរអាស្រ័យ ៗ លក្ខណៈទាំងនេះ តប្បីយើងដឹងហើយរក្សាទុកដោយរៀបចំទៅតាមដំណើរស្រុកទេសទៅមុខ ៗ

# មេរៀនទី១៤ – ពេលភ្ញៀវមកដល់

ផ្ដើមការសន្ទនា : – មានភ្ញៀវមកដល់ផ្ទះអ្នក នៅពេលដែលឪពុកម្ដាយអ្នកបាត់ពីផ្ទះ ។ ទំរាំតែឪពុកម្ដាយអ្នកត្រឡប់មក តើអ្នកបានធ្វើអ្វីខ្លះចំពោះភ្ញៀវនោះ ?

– នៅពេលដែលចាស់ៗ កំពុងជជែកគ្នា ចៅសុខតែប្រឡែងជាមួយនឹងប្អូនរំខានដល់ភ្ញៀវ. ចៅសុខនេះជាកុមារយ៉ាងដូចម្ដេច ?

ឧទាហរណ៍បរិយាយ :

*បើភ្ញៀវមកដល់ផ្ទះយើង កុមារ ជាបទសុភាពធម៌ មានករណីយកិច្ចបំពេញច្រើនណាស់ ដំបូងអាចស្រែកជំរាបឪពុកម្ដាយថា :*

*"លោកឪ-លោកពូ-អ្នកមីង អញ្ជើញមកហើយ" បើផ្ទះយើងមានឆ្កែត្រូវបង្ក្រាបសត្វនោះកុំឲ្យរំខានដល់ភ្ញៀវ រួចស្ទុះទៅបើកទ្វាររបងដោយប្រើវាចាថា :*

*"លោកឪ-លោកពូ-អ្នកមីង អញ្ជើញឡើងលើផ្ទះ" ។ បើភ្ញៀវមានឥវ៉ាន់ជាទម្ងន់យួរ ត្រូវសុំជួយកាន់ ។*

*នៅស្រុកស្រែអាចមានជួយដោះរទេះ ជួយចងទូក ។*

*ដល់ភ្ញៀវឡើងដល់លើផ្ទះហើយ តាមបង្គាប់ឪពុកម្ដាយ ត្រូវធ្វើពិធីជំរាបសួរ ទឹកមុខញញឹម ហើយឆ្លើយតបសំនួរភ្ញៀវដោយក្បោះក្បាយ តាមធម្មតានិងទៅតាមឋានៈភ្ញៀវ ត្រូវមានដាក់ស្លា ម្លូ បារី ទឹកតែ ទឹកត្រជាក់ទឹកកក រហូតដល់ភេសជ្ជៈផ្សេងៗទៀតក៏សឹងមាន ។*

*បើឪពុកម្ដាយរវល់ មិនទាន់ចេញមកបាន កុមារត្រូវចេះនិយាយសុំទោសភ្ញៀវ*

ជូនឪពុកម្ដាយយើង ។ ជាការកែអផ្សុក អាចយកទស្សនាវដ្ដី សៀវភៅរូប កាសែត ជូនភ្ញៀវមើលនិងអានកំសាន្ត ។ កុមារត្រូវអង្គុយកំដរលុះត្រាតែឪពុកម្ដាយមកដល់ ។

ដល់ឪពុកម្ដាយមកហើយ សួង់ឃើញថាយើងគ្មានហេតុផលអ្វីនឹងនៅទីនេះទេ ទើបថយទៅនៅជិត បម្រុងខ្លួនក្រែងឪពុកម្ដាយនិងភ្ញៀវមានការទាក់ទងរកហៅ ។

បើភ្ញៀវមានកូនក្មេងអាយុដំណាលនឹងយើង ឬ តូចជាងយើង ត្រូវចេះនាំក្មេងនោះទៅលេងជាមួយនឹងយើងផង មើលរូបសៀវភៅ លេងបាយឡុកបាយឡ ។ បើសិនជាហេតុការណ៍ត្រូវឲ្យកុមារនោះនៅជាមួយនឹងភ្ញៀវ ត្រូវចេះនិយាយតបឆ្លើយឲ្យសមរម្យគឺថា ពេលសមនិយាយ សឹមនិយាយ កុំនិយាយតែឯង កុំបញ្ចេញអំនួត ពេលគួរស្ងៀមត្រូវចេះស្ងៀម កុំស្ងៀមទ្រមឹងមិនចេះនិយាយ ។

ការនិយាយ ត្រូវនិយាយសម្របទៅតាមរឿងរបស់ភ្ញៀវ ចៀសវាងបង្កើតរឿងណាដែលជាទំនាស់នឹងសន្ដានចិត្តភ្ញៀវ ។ ការចេះសន្ទនាជាមួយភ្ញៀវទុកជាវិជ្ជាដ៏កម្រមួយ ត្រូវការចេះពោលសំដី ចេះរករឿងនិយាយ ចេះស្ដាប់ ចេះលួងលោមភ្ញៀវ គឺជាប្រើរបៀបមួយរយដំពូកដើម្បីឲ្យភ្ញៀវរីករាយជានិច្ច ។

អក្សរសាស្ត្រខ្មែរយើង មានក្បួនមួយឈ្មោះ “ច្បាប់ស្រី” ដែលចែងអំពីភ្ញៀវដូចតទៅ :

“ក្រមួយមិនបានសំដី ពាក្យទន់តិចនៃ ឲ្យញាតិពូលចិត្ត ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងផឹកស្លា” ។

# មេរៀនទី ១៥ – ចេះគោរពភ្ញៀវ

ផ្ដើមការសន្ទនា: ពេលភ្ញៀវមកដល់លើផ្ទះ ម្ដាយហៅសុខចង់ឲ្យសុខមកបង្ហាញខ្លួនមុខភ្ញៀវ សុខមិនព្រមធ្វើតាមបង្គាប់ ។ ឯចៅសៅប្អូនវិញ ម្ដាយហៅភ្លាមក៏មកភ្លាមអួតអាងបញ្ចេញចំណេះទំនះស្នាដៃរបស់ខ្លួន ។ តើអ្នកយល់ឃើញយ៉ាងដូចម្ដេច ចំពោះអាកប្បកិរិយាក្មេងទាំងពីរនេះ ?

## ឧទាហរណ៍បរិយាយ:

តាមលំនាំធម្មតា ចាស់ៗជួបគ្នាច្រើនជំណាលអំពីកូនចៅ ។ ឪពុកម្ដាយយើង អាចយកយើងទៅបង្ហាញដល់ភ្ញៀវ ។ ដូច្នេះ កុមារត្រូវ:

– មានការគោរពតាមកាយវិការដល់ភ្ញៀវ ដោយដាក់ថ្កុតពា ឈរឬអង្គុយឲ្យសមរម្យ

– ធ្វើតាមចិត្តភ្ញៀវសុំឲ្យធ្វើ ដូចជាមើលសាត្រាជំនាន់ដើម ដូចជាច្រៀងតាមទំនុកដែលរៀននៅសាលា ឬសំដែងរបាំតាមរៀនឯសាលាក៏សឹងមាន ។

ក្រៅពីនោះអាចមានការបង្ហាញសៀវភៅសរសេរ គំនូរ ឬជាស្នាដៃខាងការហត្ថកម្មណាមួយ ។ ពេលនោះ កុមារត្រូវរក្សាស្មារតីឲ្យនឹងនួន កុំសំដែងចំណេះហួសហេតុ ឬអឹមអៀនលាក់មុខមិនបានការ នាំឲ្យបាក់មុខមាតាបិតា ។ ចៀសវាងដាច់ខាតកុំនិយាយចែចូវពីកេរខ្មាសសាលា កេរខ្មាសគ្រូ ឬ កេរខ្មាសមិត្តណាមួយប្រាប់ភ្ញៀវ ។

# មេរៀនទី ១៦ – ក្មេងរំខានភ្ញៀវ

**ផ្ដើមការសន្ទនា** : សូរអ្នករៀបរាប់ពីអាកប្បកិរិយាផ្សេងៗ នៃក្មេងដែលបំបាក់មុខមាតាបិតានៅមុខភ្ញៀវ ។

**ឧទាហរណ៍បរិយាយ** :

*ទោសនៃក្មេងដែលរំខានភ្ញៀវមានដូចតទៅ :*

*– ភ្ញៀវមកដល់នៅលេងផ្ទះគេ ព្រោះឆ្លើយតឆ្លើយដូចគ្មាននរណាមក មិនរវល់អើពើទទួលភ្ញៀវដល់គិចគួរសោះ*

*– បំអកឡកឡឺយឲ្យភ្ញៀវដោយឃើញការមិនគួរបែបណាមួយរបស់ភ្ញៀវ*

*– ពេលភ្ញៀវនិយាយ ខ្លួនក៏តាំងនិយាយខ្លាំងៗដែរ ឬប្រខ្សែងគ្នារត់កាត់បំពោះមុខភ្ញៀវ*

*– លំអុកដាក់ម្ដាយឪពុកទារស៊ី ឬ ទារលុយ គឺធ្វើឲ្យឧកាសដែលម្ដាយឪពុកជាប់ដៃជាមួយនឹងភ្ញៀវ*

*– រឹងរូសមិនធ្វើតាមបង្គាប់ឪពុកម្ដាយនៅមុខភ្ញៀវ ឬមិនធ្វើតាមបង្គាប់ភ្ញៀវ...ៗ*

*បទទាំងនេះត្រូវចៀសវាងដោយដាច់ខាត ។*

# មេរៀនទី ១៧ – ជូនដំណើរភ្ញៀវ

ផ្ដើមការសន្ទនា : – ភ្ញៀវចេញមិនទាន់ផុតពីរបងផ្ទះផង ហៅសុខបិទទ្វារផ្ទះឮសូរគ្រាំង ។

តើអ្នកយល់ឃើញដូចម្ដេច ចំពោះអំពើនេះ ?

## ១ ឧទាហរណ៍បរិយាយ :

ពេលដែលភ្ញៀវទៅវិញ របៀបប្រហែល ៗ នឹងពេលដែលភ្ញៀវមកដល់ ត្រូវកុមារប្រុងចាំប្រតិបត្តិឡើងដូចជា :

– មកសំពះគោរពលាភ្ញៀវ

– ចាំបម្រុងត្រួតឆ្កែកុំឲ្យវាព្រុះ ឬរំខានភ្ញៀវពេលភ្ញៀវចុះពីផ្ទះ

– បម្រុងបើកទ្វាររបងពេលភ្ញៀវចេញ ពេលយប់បំភ្លឺផ្លូវចេញ

– កុំប្រញាប់បិទទ្វារ លត់ភ្លើង ឬសំដែងអាការណាមួយថា យើងចង់ឲ្យតែភ្ញៀវចុះឆាប់ ៗ សំខាន់បំផុត កុំធ្វើទឹកមុខ ឬបទ្ទិសម្ដែងជាសញ្ញាថា យើងបានធុញនឹងភ្ញៀវនោះ ៗ

សុភាវធម៌ទំនើប អាចណែនាំឲ្យបងប្អូនប្រជុំគ្នាដេញដោលគ្នារកការសម ឬមិនសម ៗ រំឭកគ្នា បើអ្នកណាម្នាក់ឃើញថា មានការទាស់ឆ្គងចំពោះភ្ញៀវ ដើម្បីរករបៀបកែទៅថ្ងៃក្រោយ ៗ

រឿងសុភាវធម៌ចំពោះភ្ញៀវសន្មតថាចប់តែប៉ុណ្ណេះ តែគ្រូអាចបង្កើតរឿងវែកញែកឆ្ងាយទូលាយចំពោះភ្ញៀវ ទៅតាមឋានៈជាអ្នកមាន ជាអ្នកក្រ ជាព្រស្ដ ជានាម៉ឺន ជាសង្ឃ ជាពង្សវង្ស ជាជាតិបរទេស ជាអ្នកមានសាសនាខុសគ្នា ៗ

# មេរៀនទី១៨ – សំពះតាមបែបបទ

– ឲ្យសិស្សសាកល្បងម្នាក់ៗ នូវរបៀបសំពះតាមបែបបទ កែកាយវិការមិនទំនងភ្លាមៗ ។ គន់មើលសិស្សគ្រប់នាទីពីរបៀបសំពះនេះ ទាល់តែបានផ្គត់មួយ ។ មើលភ្នែក មើលទឹកមុខ តើស្របនឹងការគោរពនោះ ឬ ទេ ?



សំពះសម



សំពះផ្គង



សំពះផ្គង

## មេរៀនទី ១៥ – របៀបចាប់ដៃតាមអឺរុប

**ផ្ដើមការសន្ទនា :** – សិស្សណាកម្ដងម្នាក់ៗ គូររបៀបចាប់ដៃតាមអឺរុបនេះ ឃើញកន្លែងទាស់ កែភ្លាមៗ ។ ប្រយ័ត្នត្រង់របៀបហុចដៃ នឹងក្រោក ។

### ឧទាហរណ៍បរិយាយ :



បើឱកាសហុចឲ្យ ត្រូវចាប់ដៃគេតាមរបៀបអឺរុប កុមារត្រូវធ្វើកាយវិការនេះឲ្យបានទំនងផង ត្រូវប្រុងប្រយ័ត្នស្មារតីដូចតទៅនេះ ៖

– មើលដៃយើងសិន តើស្អាត ឬមិនស្អាត

– ទុកឲ្យមនុស្សចាស់ហុចដៃមកយើងមុន សឹមយើងហុចដៃតបវិញ លើកលែងតែពេលត្រូវណាគេនៅឱកាសផ្សេងៗ

– ហុចដៃស្តាំទៅគេជាដកប

– ភ្នែកកុំសំឡឹងទៅក្រោមដូចរបៀបសំពះយើង ត្រូវមើលចំភ្នែកគេញញឹមបន្តិចផង កុំញញើតញញើម កុំបន្ទន់ខ្លួន ...

– កុំហុចចុងដៃឲ្យគេចាប់ កុំទុកម្រាមដៃស្តូក ត្រូវច្របាច់ដៃគេវិញយ៉ាងល្មម ខ្លាំងហួសហេតុពេកក៏មិនបាន លើកលែងតែចំពោះមិត្តភក្តិស្និទ្ធស្នាលរបស់យើង ។





ជំពូកទី ៣

សុភាវធម៌ចំពោះអ្នកមកស៊ីឈ្នួល
នៅធ្វើការក្នុងគ្រួសារយើង



៣ ទុំតក្ខុត

ចាឃ្ជ៊ឹកកមុគអ៉ះណាចាំបឹងកែងម

ដឹឃ៉ារោហ៊ល្បូសិតក្រតឹ៍ហ៊ា

# មេរៀនទី ២០ – មនុស្សនៅបំរើ

**ផ្ដើមការសិក្សា** : គួរបំបាត់ពាក្យខ្លះដែលនាំឲ្យខូចតម្លៃមនុស្ស ដោយមានន័យអាក្រក់ជាស្រេច ដូចជាពាក្យ : បាវព្រាវ, អ្នកងារ, ខ្ញុំកញ្ជះ, ទាសីទាសា. ប្រើតែពាក្យកម្មករបានហើយ ។ ពាក្យគួររាជការហាមឃាត់លែងឲ្យប្រើជាស្រេច ។

## ឧទាហរណ៍បរិយាយ :

មនុស្សកើតមកហើយមានតម្លៃស្មើៗគ្នា ។ តែមានមនុស្សខ្លះនៅបំរើដោយការទីទាល់ក្រនឹងដោយគ្មានបំណះ យកកម្លាំងមកលក់យកឈ្នួល ។ របរនេះឥតបន្ថយតម្លៃមនុស្សឡើយ ។ នៅក្រៅប្រទេសនឹងនៅគ្រួសារមានច្បាប់ទម្លាប់ ឈ្នួលបម្រើធ្វើការមានម៉ោងពេល មានពេលត្រូវសម្រាកដូចតែភ្នាក់ងារអ្នកធ្វើការផងទាំងឡាយ ។ នៅធានីធំៗខ្លះ នៅចន្លោះពេលរៀនមានសិស្សតាមមហាវិទ្យាល័យជាច្រើនទៅស៊ីឈ្នួលលាងចាន ជូតស្បែកជើង បម្រើកាហ្វេ មើលក្មេង ឃ្វាលចៀមនឹងគោ ។ល។ ហេតុផលទាំងនេះ បញ្ជាក់ថា មុខការស៊ីឈ្នួលឥតត្រូវចាត់ទុកថាជាថោកទាបឡើយ ។ ឥឡូវនេះ នៅរាជធានីយើង ចាប់មានកូនសិស្សនៅវិទ្យាល័យធ្វៀតរករបរតស៊ូ លក់នំប៉័ង ឈូសឈើ លក់ទឹកទៅហើយដែរ... ។

នេះបញ្ជាក់មួយអន្លើទៀតថា ការលក់កម្លាំងយកឈ្នួលឥតទៅបន្ថយតម្លៃមនុស្សឡើយ ។

ការយល់ជាក់នូវតម្លៃមនុស្សដូច្នេះ នាំឲ្យក្មេងយល់ករណីយកិច្ចខ្លួនចំពោះមនុស្សស៊ីឈ្នួល ។

# មេរៀនទី ២១ — មានចិត្តប្រពៃដល់អ្នកបំរើ

**ផ្ដើមការសន្ទនា :** ឧទាហរណ៍អំពីអំពើផ្ដាំផ្ដងចំពោះអ្នកបំរើកប់មិនអស់មិនហើយទេ នៅមានច្រើនណាស់ ក្នុងសង្គមខ្មែរយើង ។ សុំលោកគ្រូអ្នកគ្រូប្រុងប្រយ័ត្នស្មារតី កុំឲ្យមេរៀនខ្លួនទៅជាការរិះគន់ដល់សង្គមនេះ សង្គមនោះ គ្រួសារនេះ គ្រួសារនោះ នាំឲ្យខូចប្រយោជន៍សាលារៀន ។

## ឧទាហរណ៍បរិយាយ :

ចំពោះមនុស្សស៊ីឈ្នួលក្នុងគ្រួសារយើង កុមារត្រូវប្រុងប្រយ័ត្នរក្សាបទវេហុការធម៌ឲ្យខ្ជាប់ខ្ជួន ដំបូងត្រូវកុំមានចិត្តយល់ថា ពួកនោះ ជាមនុស្សថោកទាប ហើយកំតាំងចិត្តមើលងាយ ។

ផ្ទុយទៅវិញកុមារត្រូវតាំងចិត្តជាដើមសាទ៍ថា : ពួកនោះជាអ្នកកំសត់ទុគ៌តមករួមរស់ជាមួយនឹងគ្រួសារយើង មាននាទីជាអ្នកធ្វើការហត្ថកម្ម ជាអ្នកហត់ច្រើន ជាអ្នកប្រើកម្លាំងកាយសុទ្ធៗ ។

អាស្រ័យហេតុនេះ កុមារត្រូវមានសប្បុរសធម៌ ចិត្តល្អប្រពៃដែលត្រូវសំដែងចេញដោយសំដីវាចា (ហៅ ពូ-មីង-បង តាមអាយុ កុំហៅ ហង-អា-មីង សឹងដាច់សាច់) ដោយកាយវិការ (កុំធ្វើកាយវិការមាក់ងាយ) និងដោយគំនិត (កុំប្រើហួសហេតុ) ។

លើសពីមានចិត្តសប្បុរសធម៌ កុមារត្រូវមានការគួរសមទៀត : គួរសមខាងផ្លូវអាការៈ ខាងវាចា ខាងកាយវិការ និងខាងទឹកចិត្តទៀត ។

ក្នុងការប្រើឲ្យធ្វើការឲ្យយើង ត្រូវចៀសវាងកុំប្រើគ្នាច្រឆាប់ច្រងិលខុសពេលវេលាពេក ដោយមិនលៃទៅតាមកាលទិនកម្លាំង គឺទៅតាមទំនើងចិត្តក្មេងដែលមិនសូវសមហេតុផល ។

ម្យ៉ាងទៀត ត្រូវចៀសវាងបង្ខំអ្នកស៊ីឈ្នួលយើងឲ្យសំដែងការគោរពចំពោះយើងដែលជាបទបន្ទាបបន្ថោកតម្លៃមនុស្ស ។ រួមសេចក្តី កុមារត្រូវចាំក្នុងចិត្តថា យើងត្រូវរក្សាចិត្តល្អ ការគួរសមចំពោះមនុស្សអ្នកស៊ីឈ្នួលក្នុងផ្ទះយើង ។

## មេរៀនទី ២២ – នៅភោជនីយដ្ឋាន

ផ្តើមការសន្ទនា : – នៅភោជនីយដ្ឋាន អ្នកឃើញក្មេងជំទង់ម្នាក់គោះកែវ គោះចាន ស្រែកហៅអ្នកបំរើដោយពោល "អានេះ អានោះ" សំដីងាប់សាប់ ។ អាកប្បកិរិយានេះស្របនឹងបទសុភាវធម៌ឬទេ ? ឆ្គងត្រង់ណា ?

### ឧទាហរណ៍បរិយាយ :

សុភាវធម៌នៅក្នុងភោជនីយដ្ឋានមានបែបបទទូលំទូលាយណាស់ ។ ដោយនិយមទៅតាមការសង្កេតឃើញសព្វថ្ងៃ យើងយកតែអន្លើខ្លះមកបង្ហាញ :

– នៅពេលចូលទៅក្នុងភោជនីយដ្ឋាន បើមានពាក់មួក គោងដោះមួកកាន់នៅដៃភ្លាម ជាកិច្ចគោរពដល់អ្នកអង្គុយទាំងអស់ដែលគេបានដោះមួកមុនយើង ។

– បើគ្មានកន្លែងហើយត្រូវទៅអង្គុយតុជាមួយអ្នកឯទៀត ត្រូវសួរគេមុនសិន តើកន្លែងនោះទំនេរឬទេ ។

– បើត្រូវការកៅអីពីតុជិតខាង ត្រូវសុំច្បាប់គេដែលអង្គុយនៅតុនោះ ។

– កុំដាក់ជើងប្រឆេងប្រឆាង កុំខាក កុំស្ដោះ កុំកណ្ដាស កុំនិយាយខ្លាំង បើមានគ្នាជាមួយ ។

– បើឃើញអ្នកស្គាល់គ្នា កុំស្រែក កុំធ្វើដៃជើងជាបទរំខានដល់អ្នកឯទៀត ។

– កុំប្រើសំដីធំទៅរកអ្នកបំរើ ដូចហៅ "អានេះ អានោះ" សឹងដាច់សាច់ ។ កុំគោះចាន គោះកែវ ដើម្បីហៅអ្នកបំរើ ។ បើភ្នាក់ងារភោជនីយដ្ឋានគិតតម្លៃខុស កុំនិយាយខ្លាំង កុំស្ដី ... ។ យើងអាចនិយាយដោយស្រួលនឹងម្ចាស់ភោជនីយដ្ឋាន ។

– បើឃើញថាមានភ្ញៀវច្រើនរង់ចាំកន្លែងទំនេរ គួរកុំជំអក់និយាយគ្នាលេង បើយើងបានបរិភោគរួចហើយ ។ល។

បទទាំងអស់នេះឃើញថាមានប្រយោជន៍ពិតប្រាកដ តែគ្រាន់តែយើងស្គាល់ហើយ អនុវត្តកុំឲ្យខ្វះ ។



# ជំពូកទី ៤
# សុភាវធម៌នៅពេលបរិភោគ



# មេរៀនទី២៣ - ការបរិភោគអាហារ

ផ្ដើមការសិក្សា : របៀបបរិភោគអាហារតាមខ្មែរយើងភាគច្រើន ដែលម្នាក់ៗ អា យកស្លាបព្រាខ្លួនទៅល្បូកទៅជួសគ្រប់ចានម្ហូប តើសន្មតថាគ្រប់គ្រាន់តាមវិធីអនាម័យបានឬទេ? ពីព្រោះអ្វី?

## ឧទាហរណ៍បរិយាយ :

ការបរិភោគអាហារ ជាឱកាសមួយដែលអាចសំគាល់បានថា កុមារចេះសុភាពធម៌ ឬមិនចេះ ។ គេតែងមានរឿងជំណាលច្រើន អំពីមនុស្សដែលមិនចេះសុភាពធម៌របៀបបរិភោគអាហារ ។

ការបរិភោគអាហារនេះ ក៏មានសភាពនិងទំនៀមទម្លាប់ប្លែកៗគ្នា ទៅតាមគ្រួសារមាន-ក្រ ឬមធ្យម ទៅតាមសាសន៍ជាតិ ចិន-បារាំង-ឥណ្ឌា-វៀតណាម ខ្មែរ និងទៅតាមកាលៈទេសៈ បរិភោគធម្មតាក្នុងគ្រួសារ ពេលបុណ្យទាន ពេលមានភ្ញៀវតទី ឬពិធីជប់លៀងធំៗ ។

គោលធំពីរដែលប្លែកគ្នាដាច់ស្រឡះ គឺរបៀបអាស៊ីនិងអឺរ៉ុប៖

— អឺរ៉ុបមានម្ហូប-ចាន-កែវ-សម-ស្លាបព្រា ដាច់ស្រឡះពីគ្នា ឥតមានយកសម-ស្លាបព្រា យើងទៅជួសសម្លក្នុងចានលាយឡំនឹងគេទេ ។

— អាស៊ីមានម្ហូបជាមួយគ្នា ដែលអ្នកបរិភោគអាហារអាចយកស្លាបព្រា-សមទៅជួសលាយឡំគ្នាបាន ។

សម័យថ្មីនេះ នៅប្រទេសខ្លះ មានជប៉ុន-ហ្វីលីពីន-ប្រទេសថៃជាដើម

គេចាប់ទំយមបំបែកមុខម្ហូបឲ្យដាច់ពីគ្នា គឺថាម្នាក់ៗមានចានគ្រប់ម្ហូបរៀងៗខ្លួន មិនលូកជាមួយគ្នាក្នុងចានតែមួយទៀត ។

របៀបបែកម្ហូបដាច់ពីគ្នានេះ ប្រព្រឹត្តឡើងដោយផលទៅតាមច្បាប់អនាម័យ ។ របៀបនេះជារបៀបងាយយល់ទេ ។

---

## មេរៀនទី ២៤ - មុនពេលបាយ . . .

ផ្ដើមការសន្ទនា : អ្នកមានភារៈត្រូវជួយបំពេញកិច្ចការអ្វីខ្លះដែរ នៅពេលគ្រួសារអ្នករៀបបរិភោគអាហារ?

- តាមរបៀបក្នុងគ្រួសារអ្នក (អង្គុយកៅអី កន្ទេល ស្លាបព្រា ចង្កឹះ) ការប្រុងប្រយ័ត្នឲ្យទៅតាមក្បួនអនាម័យមានដូចម្ដេចខ្លះ?

ឧទាហរណ៍បរិយាយ :

ពេលបរិភោគអាហារបុគ្គលសឹងតែបានកម្រិតម៉ោងស្រេច ម្ល៉ោះហើយកុមារត្រូវមកឲ្យត្រូវពេលវេលាកុំឲ្យទុកទីឲ្យគេផងចាំខ្លួន ។ នៅគេហការខ្មែរធម្មតា កុមារត្រូវជួយរៀបចំ មានការក្រាលកន្ទេល ឬរៀបតុ លើកទឹក ជូតចាន ជូតកែវជាដើម ។ កិច្ចនេះត្រូវធ្វើដោយទឹកមុខរីករាយ តែសំខាន់បំផុត ដោយស្អាតបាត ហើយដោយប្រុងប្រយ័ត្នកុំឲ្យមានការប៉ះការ៖ បែកកែវ បែកចាន ។ បើលធ្វើ

បាន ពេលអាស្រ័យអាហារ គប្បីស្លៀកពាក់ឲ្យសមរម្យដោយទឹកក្នុងចិត្តថា កុំឲ្យខ្លួនយើងជារូបភាពដែលគេអាចខ្ពើមបាន (ញើស - ខ្លួនធុំ ឬ មានក្រមាមិនស្អាត) ។

មកដល់ ឃើញម្ហូបហើយ ចៀសវាងសំដែងអាការៈឃ្លានជ្រុល ឬ ផ្ទុយទៅវិញ ធ្វើទឹកមុខសោះអង្គើយពេក ។ កុមារ បើមេផ្ទះមិនបានបង្អុលកន្លែងឲ្យអង្គុយទេ ត្រូវរំពៃមើលតើកន្លែងណា ដែលសមនឹងខ្លួនអង្គុយ ? គឺកន្លែងមិនជាប់ជិតចាស់ពេក មិនបាំងភ្លើង ឬ បាំងពន្លឺ ។ បើអង្គុយផ្ទាល់នឹងរនាប គប្បីអង្គុយបត់ជើងតាមទំនៀមខ្មែរ ។ បើគេអនុញ្ញាតឲ្យបញ្ឈរជង្គង់ ឬ ពែនភ្នែន ត្រូវប្រព្រឹត្តឡើងដោយរមទម ដាក់ដៃឲ្យសមកុំប្រវេងប្រវាង ។ បើយើងជួសបាយឲ្យគេ ជាលើកដំបូង កុំជួសតិចពេក តែត្រូវចៀសវាងជួសហៀរចានដែរ ហើយជួសជូនចាស់មុនជាលំដាប់មក ។

---

## មេរៀនទី២៨ – របៀបបរិភោគ

ផ្តើមការសន្ទនា : កំពុងតែបរិភោគ មានហេតុខ្លះមកបង្អាក់លែងឲ្យឆ្ងាញ់ ឬក៏លែងឲ្យបរិភោគទៅទៀតបាន ។ ហេតុនោះមានដូចម្តេចខ្លះ ?

- កន្ត្លា តើអ្នកយល់ថាគួរប្រើនៅពេលបរិភោគឬទេ ?
- វីងស្ងួន (ឈើចាក់ធ្មេញ) គួរប្រើនែរឬទេ ? បើចៀសពុំបាន គួរប្រើរបៀបណា ?

## ឧទាហរណ៍បរិយាយ :

វិធីបរិភោគ ដោយបំពោះតែម្តង ត្រូវចាំទុកក្បួនសំខាន់មួយ គឺ: បរិភោគកុំឲ្យឮ ហុតសម្លកុំឲ្យឮគ្រូក គឺកុំបឺត កុំស្រូប កុំព្រួស តែត្រូវហាមាត់ ហើយកបន្តិចស្ទើរតែ យកស្លាបព្រាដួសទឹកសម្លដាក់ទៅក្នុងមាត់ គឺចៀសវាងកុំឲ្យស្លាបព្រាប៉ះចាន-ប៉ះ ធ្មេញ ៗ ទំពាម្ហូបអីកុំឲ្យឮស្នូរ គឺត្រូវទំពាថ្នមៗ កុំបន្ទឺសម្លេងដើម្បីសំដែងសេចក្តី ឆ្ងាញ់ឬការហៀរស្រេល ៗ កុំភ្ជៀតនិយាយពេលម្ហូបនៅក្នុងមាត់ ៗ ចៀសវាងកុំ សើច ក្អឹកឬក្អក ៗ

របៀបខ្មែរ បរិភោគឲ្យអស់ពីចាន ៗ គេតែងនិយមថា :

“កុំបរិភោគឲ្យឆ្អែតពេក គឺលៃឲ្យនៅឃ្លានបន្តិចពេលដែលឈប់បរិភោគហើយ”ៗ

វិធីលូកម្ហូប ក៏ត្រូវឲ្យមានសុភាពធម៌ខ្ពង់ខ្ពស់ដែរ គឺចៀសវាងកុំលូកតែម្ហូបណា ដែលឆ្ងាញ់ជាងគេ លៃលូកម្ហូបឲ្យស្មើៗគ្នា តែបើមានចានឆ្ងាយពីយើងពេក ក៏មិន ត្រូវឈោងទៅលូកដែរ ៗ ពេលកំពុងបរិភោគ គេអាចសួរយោបល់យើងពីម្ហូបអាហារ យើងគប្បីឆ្លើយថាឆ្ងាញ់ពិសាណាស់ ៗ ត្រូវលៃបញ្ចប់ការបរិភោគជាមួយនឹងអ្នកផង ទៀត កុំឈប់មុនគេពេក កុំឈប់ក្រោយគេពេក ៗ បើឈប់មុនគេ ហើយត្រូវ ការក្រោកចេញពីវង់បាយ ត្រូវនិយាយសុំទោសគេជាមុនសិន ៗ

គោលការណ៍ដែលត្រូវចាំមួយទៀត គឺនៅពេលបរិភោគ ចៀសវាងនិយាយ បញ្ចេញសម្តីឬសំដែងអាការៈណាមួយដែលនាំឲ្យគេខ្ពើម ៗ

ការប្រើស្ទូន (ឈើចាក់ធ្មេញ) បើចៀសវាងបាន ត្រូវចៀសវាង ។ បើត្រូវតែប្រើដោយខានមិនបាន ត្រូវយកដៃម្ខាងបាំងមាត់ ធ្វើដោយលាក់លៀម ដោយរហ័ស ហើយលាក់ស្ទូននោះឲ្យបាត់ភ្លាម ។

---

## មេរៀនទី ២៦ – បរិភោគតាមរបៀបសម័យ

ផ្ដើមការសន្ទនា : **អ្នកមិនដែលស្គាល់គ្រួសារណាមួយ ដែលគេប្រព្រឹត្តការបរិភោគតាមរបៀបសម័យ ។ របៀបគេមានដូចម្ដេចខ្លះ ?**

### ឧទាហរណ៍បរិយាយ :

យើងមិននិយាយឲ្យវែងឆ្ងាយពីរបៀបនេះទេ ដោយយល់ឃើញថាគ្រួសារខ្មែរយើងស្ទើរតែទាំងអស់ មិនទាន់និយមរបៀបនេះនៅឡើយ ។

ក្នុងគ្រួសារទំនើបដែលការបរិភោគប្រព្រឹត្តឡើងនៅលើតុនោះ នឹងមានបទសុភាវធម៌ផ្សេងៗទៀត ដូចជា : របៀបអង្គុយលើកៅអី ត្រូវទាញកៅអីកុំឲ្យឮ បើមានស្រី ត្រូវយើងទាញកៅអីឲ្យស្រីអង្គុយមុន ។ ពេលអង្គុយ អង្គុយឲ្យត្រង់ខ្លួន កុំផ្អែកទៅលើកៅអីពេក កុំជិតទៅលើតុពេក កុំកន្ត្រក់ជើងច្រល ធន់ដៃទៅលើតុ

ឲ្យល្មម ហើយឲ្យចេះប្រើដៃទាំងពីរ ។ ត្រូវចេះប្រើកន្សែង ត្រូវចេះកាន់ស្លាបព្រា សម កាំបិត កុំឲ្យគ្គង ។ បើមានការនិយាយ កុំក្កាដៃ-ក្កាជើង ។ កាយវិការទាំងនោះ មិនងាយនឹងបានមកដោយងាយទេ ពល់តែបានឃើញ បានសង្កេតជាញឹកញាប់ បានប្រព្រឹត្តស្ទើរតែរាល់ថ្ងៃ ទើបធ្វើមិនគ្គាំគ្គង ។

## ពាក្យប្រៅណា . . . ខ្វះ !

សុភាវធម៌ដែលបានចែងមកនេះ និយាយតែឧភល់ទូទៅគតសំដែងដល់ពិធីជប់លៀងធំ ៗ នោះទេ ។ មុននឹងបញ្ចប់ជំពូកនេះ ត្រូវរំឭកសុភាសិតខ្មែរខ្លះដូចតទៅ :

“ បើស៊ី កុំតាមឃ្លាន គិតប្រមាណដល់គ្នីគ្នា ”

“ បើស៊ីបង់ពិសា ខ្វិលទំពាឲ្យហ្មត់ហ្មង ”

អាចនិទានរឿងព្រេង ដូចរឿង “ ធនញ្ជ័យនឹងសម្ដីសួ ” ហើយនឹងរឿង “ លោកសង្ឃនឹងផែនដីក្រឡាប់ ” ឲ្យសិស្សស្តាប់ក៏បាន ។



ជំពូកទី ៥

សុភាវធម៌នៅសាលារៀន

## មេរៀនទី ២៧ – បញ្ហាឯកសណ្ឋានសិស្ស

**ផ្ដើមការសិក្សា :** ឯកសណ្ឋានបំពាក់ជាទេះ មានក្រ ធំតូច ឯកសណ្ឋាននាំឲ្យសិស្សកាន់វិន័យ
នឹងហ្មត់ចត់ ។ ហេតុអ្វីបានជាគេថាដូច្នេះ?

**ឧទាហរណ៍បរិយាយ :**



សំលៀកបំពាក់សិស្សសាលា

រឿងនេះ ជារឿងរបស់សិស្ស ដោយចំពោះ ៗ ដូច្នេះ គួរតែយើងលាតត្រដាងបញ្ហាខ្លះនៃរឿងសិស្សានុសិស្ស ។

សិស្សានុសិស្ស ជាសង្គមកុមា-រកុមារីមួយ ដែលមានសារៈក្នុងសង្គមជាតិ ៗ អ្នកផងឃើញកូនសិស្សអាចវិនិច្ឆ័យថា សង្គមនោះបានទៅកាន់សេចក្ដីចម្រើនដល់ណាហើយ ។

ប្រទេសខ្លះរៀបចំកូនសិស្ស ឲ្យមានសំលៀកបំពាក់ជាឯកសណ្ឋានដូច ៗ គ្នា ដោយគេចង់ឲ្យកូនសិស្សមានសភាពខាងក្រៅដូច ៗ គ្នា កុំឲ្យចេះឃើញថា មានអ្នកមាន អ្នកក្រពេក ៗ ម្យ៉ាងទៀត ស្លៀកឯកសណ្ឋាននាំឲ្យល្អមើលផង ហើយទម្លាប់

ក្មេងឲ្យចេះថែទាំសំលៀកបំពាក់ ឲ្យចេះអ៊ុតស្អាត ឲ្យមានបង់បូរ ពាក់មួក សំពត់ខ្លី នឹងស្បែកជើង ស្រោមជើងដូចៗគ្នា ។ របៀបស្លៀកពាក់ជាឯកសណ្ឋាន នាំឲ្យសិស្សមានគំនិតជាសង្គមជាមួយគ្នា ថែមទាំងចេះរក្សាកិត្តិយសដែលជាប់នឹងឯកសណ្ឋាននោះ ព្រោះឯកសណ្ឋានរមែងមានរូបសញ្ញានាមសាលានៅជាមួយផង ។

---

## មេរៀនទី២៨ – សំលៀកបំពាក់សិស្ស

**ផ្ដើមការសន្ទនា :** អ្នកឃើញនារីស្រីជំទង់រ៉ា ដើរតាមផ្លូវ ។ លក្ខណៈត្រង់ណាដែលអាចឲ្យអ្នកសន្និដ្ឋានបានថា នារីនេះជាសិស្សសាលា នារីនេះមិនមែនជាសិស្សសាលា ?

**ឧទាហរណ៍បរិយាយ :**

ប្រទេសខ្លះចោទថា ឲ្យសិស្សស្លៀកឯកសណ្ឋានជារបៀបទាហាននិយមពេក ។ គេបណ្ដោយឲ្យសិស្ស ស្លៀកពាក់តាមចិត្ត តែគង់គេណែនាំឲ្យគាត់សក់មានរបៀប ។ ចំពោះក្មេងស្រីកុំឲ្យពាក់អាវស្តើងចេញសាច់ កុំឲ្យពាក់អលង្ការ មាសពេជ្រជាដើម កុំឲ្យប្រើទឹកអប់ធុនថ្លៃ កុំឲ្យលាបបបូរមាត់ ។

គេហាមប្រាមមិនឲ្យស្លៀកពាក់បែបនេះ ដើម្បីជាបទអប់រំក្មេងស្រី ឲ្យមានភាពជាសិស្សកុមារីសមរម្យ មិនមែនស្រីពេញរូបការទេ ។ ដូច្នេះមានថែមការអប់រំតាំងពីដំណើរ ទឹកមុខ ការធ្វើកាយវិការ ។

ប្រទេសខ្លះ ហាមមិនឲ្យកាត់អាវមានពណ៌ បញ្ចេញពណ៌ភេទស្រី ឬ អាវមានកធំ បញ្ចេញសាច់ គឺចៀសវាងរបៀបស្លៀកពាក់ ដែលជាហេតុនាំឲ្យមានក្ដីសម្រើប សម្រាល ។

ខ្មែរយើងគួរបញ្ជាក់របៀបនេះ តាមបែបបទណាមួយ ។

---

## មេរៀនទី ២៤ – មកសាលាឲ្យទាន់ម៉ោង

**ផ្ដើមការសន្ទនា :** លោកគ្រូចាប់ពន្យល់មេរៀនបានមួយស្របកទៅហើយ ទើបចៅសុខដើរចូលក្នុងថ្នាក់ ។ អ្នកយល់ដូចម្ដេចចំពោះអាកប្បកិរិយាចៅសុខនេះ ?

**ឧទាហរណ៍បរិយាយ :**

សុភាវធម៌នៃសិស្សចំពោះសាលា ដែលត្រូវគត់ចំណាំឲ្យជាក់ជាងគេនោះ គឺ សិស្សត្រូវមកសាលាឲ្យទាន់ពេលវេលា ។ តាមធម្មតា សាលារៀនបង្ហាញពេលវេលាតាមសូរកណ្ដឹង ឬ សូរស្គរពីរដង ៗ ដងដំបូង សម្រាប់ឲ្យដំណឹងដល់សិស្សប្រមូលសិស្ស ៗ សិស្សគប្បីមកដល់សាលាឲ្យទាន់ស្គរ ឬជួង ឬកណ្ដឹងលើកទីមួយ ។

សិស្សមកមិនទាន់ម៉ោង ជាហេតុនាំឲ្យមានទម្លាប់អាក្រក់ ធ្វើអ្វីៗក្នុងជីវិតនេះ តែងមិនត្រូវ ឬមិនទាន់ពេលវេលា ទីងជាកិច្ចមិនគួរសមចំពោះគ្រូទីងចំពោះសិស្ស ៗ មិនគួរសមយ៉ាងណាមិញ គឺមិនគួរសិស្សមកដល់ក្រោយគ្រូ ធ្វើឲ្យលោកគ្រូទីងមិត្ត

ឯទៀតចាំ ៗ បទនេះចាត់ទុកជាបទមើលងាយដល់គ្រូ និងមិត្តជាសិស្សក៏បាន ។ មយ៉ាងទៀត ជាកិច្ចរំខានដល់ថ្នាក់រៀន ដែលបានចាប់ផ្ដើមខ្លះទៅហើយ ។

តែផ្ទុយទៅវិញ សិស្សមិនត្រូវមកមុនម៉ោងជ្រុលពេកទេ ហើយទុកឱកាសមុនចូលរៀននោះទៅលេង ឬ ប្រព្រឹត្តបទណាដែលឃ្លាតពីការរៀនដូចជា គប់ផ្លែឈើ ហែលទឹក ជាដើម ៗ ល្បែងនិងអំពើប្រព្រឹត្តមុនម៉ោងចូលរៀន នឹងក្រៅសាលា អាចនាំក្មេងឲ្យមានគ្រោះថ្នាក់ (ធ្លាក់ពីដើមឈើ - លង់ទឹក - ដាល់គ្នា) ។ តាមទម្លាប់ធ្លាប់ដឹងពីមក គ្រូត្រូវទទួលខុសត្រូវលើសិស្សតែនៅ ១៥ នាទីមុនចូលរៀន - កំពុងរៀន - ពេលចេញលេង និង ៥ នាទីក្រោយចេញពីរៀន ហើយសំខាន់ គឺពេលសិស្សនៅក្នុងក្របខណ្ឌរបងក្នុងវង្វង់សាលារៀន ។

---

## មេរៀនទី ៣០ : ចេះស្លៀកពាក់ក្នុងសាលា

**ផ្ដើមការសន្ទនា :** នៅបន្ទប់និមួយ ៗ នៃសាលារៀនយើង មានកូនបន្ទប់មួយបិទបាំងជិតមានកញ្ចក់ អានក្រាស់ ទឹកស្អាត ។ បន្ទប់តូចនេះមានប្រយោជន៍ដូចម្ដេច ?

– ចំពោះសិស្សស្រីៗ ត្រូវផ្លាស់ខោអាវនៅក្នុងសាលាដោយគោរពកេរខ្មាសបំផុត តើត្រូវធ្វើយ៉ាងដូចម្ដេច?

– ដូចម្ដេចហៅថាសំលៀកបំពាក់សំរាប់កីឡា ចំពោះសិស្សប្រុស ? ស្រី ? ។

**ឧទាហរណ៍បរិយាយ :**

រឿងសម្លៀកបំពាក់ យើងបានចែងខ្លះហើយនៅលំនាំដើម រឿងសំអាតខ្លួន ដោយចំពោះជារឿងអនាម័យទេ ៗ តែតាមបទសុភាវធម៌ សិស្សត្រូវស្លៀកពាក់

កុំបណ្តែតបណ្តោយ ដោយតាំងចិត្តថា ខ្លួនទៅកន្លែងមួយដែលជាទីគោរព មិនមែនទៅលេងល្បះឡោះ ស្លៀកពាក់បានតាមចិត្តនោះទេ ឬក្នុងការស្លៀកពាក់នោះមានការខ្ជីខ្ជា (មិនដាក់ឡេវអាវ - មូរដៃម្ខាង) ។ ត្រង់នេះ គ្រូរំឭកពីរឿងរបៀបផ្លាស់ខោអាវនៅក្នុងសាលា ត្រូវប្រព្រឹត្តដោយគោរពកេរខ្មាសបំផុត បើមានសិស្សប្រុសនិងស្រីលាយឡំគ្នា ។

តាមរបៀបទំនើប សាលាគួរមានបន្ទប់មួយ សម្រាប់សិស្សប្រុស បន្ទប់មួយសម្រាប់សិស្សស្រី ។

ខោខ្លីស្លៀកសម្រាប់កីឡា ត្រូវឲ្យសមទៅតាមខ្នាតកីឡា មិនត្រូវស្លៀកខោទ្រនាប់ចម្នូតាដែលមានពណ៌មិនសម ។

ស្លៀកខោខ្លីហើយកុំច្រៀតឈ្លាត់សៀតបង្កើះទៀត ។ រួមសេចក្តី គឺរបៀបស្លៀកពាក់ ត្រូវស្ថិតនៅគោលគំនិតដូចតទៅនេះ៖ ឲ្យមានភាពសមរម្យ ឲ្យមានរបៀបជាបទចរិយាសាស្ត្រខ្លះ ។

ត្រូវរំឭកដល់សិស្សនូវការទ្រទ្រង់រាងកាយខ្លួនទៅ មានការកាត់សក់ ការកាត់ក្រចក និងរៀបចំខ្លួន ឲ្យមានសភាពជាកុមារមានសណ្តាប់ធ្នាប់ គឺកុំឲ្យរាងកាយជាហេតុទំនាស់ដល់ភ្នែកអ្នកផង ។

## មេរៀនទី៣១ —

## — តាក់តែងកាយចំពោះសិស្សនារី

**ផ្ដើមការសិក្សា :** - ចូររាប់រៀបពីទោសដែលកើតឡើងក្នុងសាលា កាលណាសិស្សស្រីមានពាក់មាស - ពេជ្រមករៀន ?

- មានដំណឹងថា មានសិស្សស្រីម្នាក់បាត់ខ្សែកមាសនៅក្នុងសាលា ។ ចូរនិយាយរៀបរាប់ពីកង្វល់ដែលកើតឡើងដោយសារខ្សែកនេះ ។

**ឧទាហរណ៍បរិយាយ :**

ចំពោះកុមារី គួរបញ្ជាក់នូវរបៀបដោយឡែកខ្លះ ចៀសវាងកុំឲ្យសិស្សស្រីចិញ្ចឹមចិត្តថា ត្រូវតែតែងខ្លួន ដូចជាមនុស្សស្រីពេញរូបពេញរាងទៅហើយ គឺចៀសវាងពាក់អាវទំនើបសម័យដែលចាប់រាងពេកមិនខ្មាស ឬជាសំពត់ស្ដើងឃើញសាច់ ។ ការថែទាំសក់ មានការអ៊ុត - ការចាប់រាងក្បាល - ការលាបមុខ - ផាត់ម្សៅ - ប្រើទឹកអប់ ពាក់មាសពាក់ពេជ្រ ក៏ត្រូវតែបន្ថយ ដោយរក្សាគោលគំនិតថា កុមារីមិនត្រូវតែងខ្លួនឲ្យហួសឋានៈជាសិស្សស្រីចូលដល់ឋានៈមនុស្សស្រីពេញរូបពេញរាងទេ ។ ការធ្វើកាយវិការ សំដីសំដៅ - ទឹកមុខ - ដាក់ឫកពា - របៀបដើរ ក៏ត្រូវគិតប្រព្រឹត្តទៅតាមគោលការណ៍ថា សិស្សស្រីជាកុមារី ឬ យុវតីសិក្សា មិនមែនជាស្រីពេញរូបពេញរាងទេ ។

មាសនឹងពេជ្រនាំទោសបីយ៉ាង :

១- បង្កើតសេចក្ដីប្រណែន នឹងការរិះគន់ បង្កើតឲ្យមានវណ្ណៈទីទៃពីគ្នា ផ្ទុយនឹងលក្ខណៈសាលាខ្មែរយើងដែលជាទីសាធារណៈ ជាទីអព្យាក្រឹត្យ ។

២- រំខានដល់ការរៀនសូត្រ ការសរសេរ ការអាន ការហាត់ប្រាណ

៣- កាលណាមានការបាត់គ្រឿងនោះម្ដង ៗ នាំឲ្យរំខានកង្វល់ដល់គ្រូនឹងសិស្សទាំងអស់ក្នុងសាលា ។

សាលារៀនរាប់មានបញ្ញត្តិដោយតឹងរ៉ឹងបំផុត មិនឲ្យសិស្សប្រុស-ស្រីពាក់មាសពេជ្រនេះជាដាច់ខាត ។

---

## មេរៀនទី ៣២ – ពិធីគោរពទង់ជាតិ

ផ្ដើមការសន្ទនា : ពេលគោរពទង់ជាតិ ចៅសុខឈរពីក្រោយគេ មិនត្រង់ខ្លួន មិនប្រុងស្មារតី មិនស្ងឹងស្ងាត ងាករកគេឯង ។ អ្នកយល់ថាសុខនេះជាសិស្សដូចម្ដេច?

ឧទាហរណ៍បរិយាយ :

មុននឹងចូលរៀន មានពិធីគោរពទង់ជាតិ ៗ តើពិធីនេះ មានន័យយ៉ាងណា?

ដំបូងជាកិច្ចប្រមូលសិស្សឲ្យឈរជាជួរ ឲ្យច្រៀងបទនគររាជដែលជាសញ្ញាកូននឹងទំនុកជាតិខ្មែរ ៗ ពេលនោះ សិស្សម្នាក់បង្ហូតទង់ជាតិខ្ពស់ត្រដែតទៅ ៗ នៅ

នាទីនេះ សិស្សត្រូវមានចិត្តក្តួចក្តោះដល់ជាតិខ្មែរ - សាសនា - ព្រះមហាក្សត្រ ។ នាទីគោរពទង់ជាតិទាញអារម្មណ៍ក្មេងឲ្យវិលមកប៉ះគោលគំនិតមួយថ្ងៃបានពីដើម ។ បទសុភាវធម៌ដែលត្រូវទាញចេញ នៅពេលគោរពទង់ជាតិ ខាងផ្លូវកាយ ត្រូវឈររបៀបប្រុង - របៀបគោរព - មានសម្បជញ្ញៈច្រៀងបទនគររាជ - ច្រៀងឲ្យត្រូវបទភ្លេង ត្រូវសម្លេង ។ ត្រូវមានចិត្តគោរពនឹងស្រឡាញ់ ។ ខាងផ្លូវចិត្ត នៅនាទីគោរពទង់ជាតិ ធ្វើចិត្តកុំឲ្យរវើរវាយនឹកទៅឯណា តែត្រូវតាំងចិត្តនឹកស្រឡាញ់គោរពជាតិ សាសនា ព្រះមហាក្សត្រ ។

នៅពេលបញ្ចប់ពិធីគោរពទង់ជាតិ សិស្សមិនត្រូវស្រែកហោកញ្ជ្រៀវទេ តែត្រូវរៀបជាជួរដោយវិន័យបម្រុងនឹងចូលរៀន ។

---

## មេរៀនទី ៣៣ ការគោរពគ្រូ

ផ្តើមការសន្ទនា: បង្ហាត់សិស្សឲ្យចេះថាដោយរត់មាត់ឃ្លាខ្លះដែលត្រូវប្រើ ក្នុងការទាក់ទងដោយគួរសមជាមួយនឹងគ្រូថា = សូមលោកគ្រូមេត្តាអត់ទោស សូមអរគុណលោកគ្រូ សូមលោកគ្រូអនុញ្ញាតឲ្យខ្ញុំបានទៅ - ជំរាបសួរលោកគ្រូ! ។ល។

## ឧទាហរណ៍បរិយាយ:

នៅក្នុងសាលា គ្រូជាបុគ្គលដែលសិស្សត្រូវស្រឡាញ់ហើយគោរព៖ គោរពលោកដោយវាចា គឺនិយាយដោយសំដីទន់ភ្លន់មានប្រយោគ-ប្រធាន ។ កុំនិយាយកំបុត ហើយប្រើពាក្យឲ្យគួរសមទៀត ។ តាមធម្មតាសិស្សត្រូវឈរ ឈរឲ្យត្រង់ កុំមាត់ កុំអាកមុខពុះឡើង ក្អេកសម្លឹងរកប្រឡែងគ្នា ជាកិច្ចគោរពគ្រូនៅពេលចូលរៀនម៉ោងដំបូង ។ នេះជាបទគោរពតាមកាយវិការ បើលោកគ្រូហៅ ត្រូវឆ្លើយភ្លាម បើត្រូវការចេញចូល ត្រូវសុំច្បាប់លោកគ្រូ ។

បើលោកគ្រូនិយាយ ត្រូវប្រុងស្ដាប់ កុំធ្វើឫកពាព្រងើយ ។ ត្រូវចៀសវាងជាដាច់ខាតបំអកឡកឡឺយដល់លោកគ្រូ និយាយដើមគ្រូ និងសំដែងអាការៈណាមួយធ្វើឲ្យលោកគ្រូមិនសប្បាយចិត្ត ។

បើយើងមានវត្ថុអ្វី ដែលត្រូវជូនទៅលោកគ្រូ ត្រូវហុចទៅជូនលោកដោយដៃពីរ ទទួលវត្ថុពីលោកក៏ទទួលដោយដៃពីរ ។ ចំពោះមិត្តស្មើគ្នា ហុចវត្ថុនិងទទួលវត្ថុ ត្រូវប្រព្រឹត្តឡើងដោយដៃស្ដាំ ។

ត្រូវរំឭកមេរៀនមុន ៗ ដែលសិស្សត្រូវនិយាយថា “សូមអរគុណ” ។

កំពុងរៀន បើមានមនុស្សប្លែកចូលមក សិស្សត្រូវក្រោកឈរជានិច្ច គោរពភ្ញៀវដែលចូលក្នុងថ្នាក់ ។ ពេលដែលភ្ញៀវនោះរវល់ជាមួយនឹងគ្រូយើង យើងមិនត្រូវឆ្លៀតពេលនោះជជែកគ្នាឡើយ ត្រូវរក្សាសេចក្ដីស្ងៀមស្ងាត់ អង្គុយឲ្យនឹងនួន ដើម្បីកុំឲ្យរំខានលោកគ្រូយើងនិងភ្ញៀវ ។ ដល់ភ្ញៀវចេញទៅវិញ សិស្សក៏ត្រូវក្រោកឈរជានិច្ចគោរពភ្ញៀវ ។ ភ្ញៀវចេញទៅមិនទាន់ផុត កុំសំដែងនិយាយដើមឬបំអកឡកឡឺយឲ្យភ្ញៀវ ។

## មេរៀនទី ៣៤ - អាការៈគោរពគ្រូ

ផ្ដើមការសន្ទនា : គ្រូស្ដីបន្ទោសចៅសុខ សុខធ្វើមុខក្រញូវហើយនៅស្ងៀម ។ អ្នកយល់ថាសុខជាសិស្សយ៉ាងដូចម្ដេច ?

- ភ្ញៀវចេញទើបនឹងផុតពីថ្នាក់ សុខងាកមុខរកមិត្តខ្លួនធ្វើត្រាប់ភ្ញៀវនោះ ។ អំពើនេះផ្ទុយត្រង់ណានឹងបទសុភាវធម៌ ?

### ឧទាហរណ៍បរិយាយ :

នៅក្នុងថ្នាក់ដូចតែនៅក្នុងផ្ទះនានា សិស្សត្រូវប្រឹងជួយបម្រើអ្នកផងជាកិច្ចបន្តិចបន្តួច ដូចជាបើកទ្វារឲ្យគេចូល យកកៅអីឲ្យគេអង្គុយ ។ ការបន្តិចបន្តួចនេះជាភាពសុភាវធម៌យ៉ាងល្អ គួរតែសិស្សមានស្មារតីប្រឹងបំពេញឲ្យបានរាល់ពេលវេលា ។ បើយើងជាអ្នកបានទទួលអំពើល្អណាមួយពីគេវិញ ត្រូវកុំភ្លេចអរគុណគេភ្លាម ៗ ។ បើគ្រូស្ដីបន្ទោស ឬ ហាមប្រាមបទណាមួយ ត្រូវយើងទទួលសេចក្ដីបន្ទោសនឹងសេចក្ដីហាមប្រាមនោះដោយចិត្តរីករាយ កុំធ្វើទឹកមុខក្រញូវរឹងរូសមិនចង់ស្ដាប់ ។

បើមានឱកាសខ្លះ យើងបានជាជ្រុលខុសការគួរសមដល់លោកគ្រូនូវបែបបទណាមួយ ត្រូវឆាប់កែខ្លួនដោយទៅសុំទោសលោកគ្រូនោះភ្លាម ៗ ។

ការសំដែងការគោរពតាមរបៀបខ្មែរចំពោះអ្នកធំ ត្រូវសំពះដៃពីរ ។ បញ្ហាសំពះនេះ ត្រូវមានរបៀបកម្រិតឲ្យត្រូវក្បួនខ្នាត ។ តែត្រង់នេះ យើងបញ្ជាក់ថាទីសំពះ ត្រូវយកឲ្យត្រង់ ឲ្យសមរម្យ លើកដៃភ្ជាប់គ្នាឲ្យទន់កុំប្រឆេងប្រឆាង កុំធ្វើឡើងដោយប្រញាប់ប្រញាល់ពេក ឲ្យតែរួចពីដៃ ។

ជំពូកសុជីវធម៌នៅក្នុងសាលានេះ គ្រូអាចមានឱកាសច្រើនណាស់ ដើម្បីនឹងអប់រំសិស្ស ដោយយកគោលការណ៍តទៅនេះជាមូលដ្ឋាន ៖

ឲ្យសិស្សមានសភាពក្រៅ - កាយវិការ - វាចាសំដីសំដៅ - សន្តានចិត្ត សមរម្យ គឺមានសម្បជញ្ញៈដកប ៗ

---

## មេរៀនទី ៣៨ - ចំពោះមិត្តភក្តិ រវាងមិត្តភក្តិ

### ផ្ដើមការសន្ទនា : មិត្រល្អមានលក្ខណៈដូចម្ដេចខ្លះ ?

- យកអាសាគេ ដោយចង់ឲ្យគេតបស្នងសងគុណ ដោយបញ្ចេញអាការៈក្រៅថាយើងគ្រាន់បើ នេះសន្មតថាយកអាសាប្រកបដោយលក្ខណៈប្រពៃ ឬ ទេ ?

ជួយលាក់កេរខ្មាសលាក់កំហុសខ្លះ នៃមិត្រភក្តិ តើអាចសន្មតបានថាជួយយកអាសាមិត្របាន ឬ ទេ ?

### ឧទាហរណ៍បរិយាយ :

មិត្តភក្តិនៅសាលាជាកុមារ - កុមារីទាំងឡាយ ដែលនៅរៀនក្នុងសាលាជាមួយគ្នា ដោយចំពោះក្នុងថ្នាក់ជាមួយគ្នា ៗ ចំពោះមិត្រភក្តិនេះ កុមារសិក្សាមានការទាក់ទងស្ទើរតែរាល់ថ្ងៃ ៗ ដូច្នេះ គោងមានបទសុជីវធម៌ដើម្បីការទាក់ទងនេះ បានធ្វើឡើងដោយរីករាយទីនដោយប្រពៃ ៗ

ដំបូងកុមារត្រូវចេះយកអាសាមិត្តភក្តិ ពោលគឺឲ្យតែមានឱកាសត្រូវជួយមិត្តភក្តិ-បម្រើមិត្តភក្តិ-ធ្វើកិច្ចល្អណាមួយ ឲ្យមិត្តភក្តិបានសុខស្រួល បានសប្បាយដោយសារ ។ ការយកអាសាមិត្តភក្តិនេះ មិនត្រូវធ្វើឡើងដើម្បីបញ្ចេញឫកពាបង្ហាញអ្នកផងថា ជាក្មេងចិត្តល្អនោះទេ តែធ្វើឡើងដោយសុទ្ធចិត្ត ដោយចិត្តរីករាយ ។

ការមិនជួយយកអាសាគ្នា ជាហេតុនាំឲ្យនៅជាមួយគ្នាដោយមិនស្រុះស្រួល ដោយប្រកាន់តែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗ រហូតដល់មានចិត្តឈ្នានីសនឹងគ្នា ។ អំពើទាំងនេះ ត្រូវកុមារចៀសវាងដោយដាច់ខាត ។

---

## មេរៀនទី៣៦- កុំរំខានអ្នកដទៃ

ផ្តើមការសន្ទនា : កាយវិការ សំដីសំដៅដែលរំខានដល់លោកគ្រូនិងមិត្រនៅក្នុងបន្ទប់រៀន មានដូចម្តេចខ្លះ ?

ការរំខានដួនមានធ្វើឡើងដោយចេតនា ដួនដោយអចេតនា ។ សុំពន្យល់ ។

ឧទាហរណ៍បរិយាយ :

ការរស់ជាមួយគ្នា បើយើងមិនប្រុងស្មារតី មិនបានជាគិត ខ្លួនយើងនេះឯងអាចទៅជាគ្រឿងរំខានអ្នកផងឯទៀត ។

រំខានដល់កាយគេ ដោយយើងធ្វើកាយវិការមិនសមទៅលើគេ – ដោយទៅឈរបាំងមុខគេ គ្រអឹតដាក់គេ ដោយអង្គុយប្រជ្រៀតទីងគេ ដោយធ្វើអាការៈក្រៅបែបណាមួយជាទំនាស់ដល់គេ ។

រំខានគេខាងផ្លូវចិត្ត ដោយប្រើវាចាយ៉ាងខ្លាំងទៅរំខានសេចក្ដីស្ងប់ស្ងៀមរបស់គេ ដោយនិយាយពាក្យចំអកបំអួនឲ្យគេឮ ដោយសំដែងអាការៈចង់ដឹងអាថិកំបាំងរបស់គេ ដោយប្រើសំដីទ្រគោះបោះបោកដល់គេ គឺធ្វើអាការៈទាំងឡាយណា ដែលនាំឲ្យគេមានទឹកចិត្តមិនស្រួល ។

កុមារត្រូវចាំភ្ជាប់ក្នុងចិត្តថា ក្នុងលោកនេះខ្លួនត្រូវតែរស់ជាសង្គមជាមួយគេជាដរាប ។ ដូច្នេះ តាំងតែពីការដាក់ទឹកមុខឡើង មិនត្រូវធ្វើទឹកមុខក្រញូវ ទឹកមុខស្រងូតស្រងាត់ជ្រួល ទឹកមុខព្រួយហួសហេតុ ដែលអាចជាហេតុ នាំឲ្យអ្នកផងឯទៀតពិបាកចិត្តដោយសារខ្លួន ។ ក្នុងអទ្វើនេះ គោលគំនិតជាមូលដ្ឋានដែលត្រូវចាំ គឺកុមារត្រូវប្រុងស្មារតីជានិច្ច កុំឲ្យសភាពក្រៅរបស់ខ្លួន (ទឹកមុខ-កាយវិការ-សម្លៀកបំពាក់-សំដីសំដៅ) ទៅរំខានអ្នកផង តែរក្សាអាកប្បកិរិយា - ទឹកមុខស្រស់បស់ - សំដីសំដៅទន់ភ្លន់ ជាហេតុនាំអ្នកផងឲ្យរីករាយជាមួយយើង ។

## មេរៀនទី៣៧- ចេះឈ្នះ ចេះចាញ់

ផ្តើមការសន្ទនា : ចៅសុខ នឹង ចៅសៅ រៀនពូកែដូចគ្នានៅសាលារៀន ។ តែមិត្រឯទៀតស្រឡាញ់រាប់អានចៅសៅ មិនរាប់អានចៅសុខ ។ ពីព្រោះអ្វី ?

- ម្តេចហៅថាចេះឈ្នះ ? ម្តេចហៅថាចេះចាញ់ ?
- ម្តេចបានគេតែងថា "មិនត្រូវប្រាថ្នាឈ្នះគេទេ ត្រូវប្រាថ្នាឈ្នះតែខ្លួនយើង ?

### ឧទាហរណ៍បរិយាយ :

ការរស់នៅជាសង្គមក្នុងសាលា រមែងមានការប្រកួតប្រណាំង ការប្រជែងជានិច្ច ដូចនៅក្នុងល្បែងកីឡាទាំងនៅក្នុងការរៀនសូត្រ ។ កុមារត្រូវយល់ថា ការប្រកួតប្រណាំងនេះ ជាកិច្ចនាំឲ្យសិស្សម្នាក់ៗ ខិតខំដោយមធ្យោបាយយុត្តិធម៌ ដើម្បីបានជោគជ័យលើមិត្តរបស់ខ្លួន ។ របៀបប្រកួតប្រណាំង ជាហេតុមួយអាចដឹកនាំកុមារឲ្យប្រព្រឹត្តអ្វីៗ កាន់តែបានល្អឡើង ។ អ្នកអប់រំគេតែងយករបៀបប្រកួតប្រណាំងនេះ ទៅធ្វើជាមធ្យោបាយដើម្បីកំចាត់ពីគំនិតក្មេង នូវទោសពីរយ៉ាង :

- ម្យ៉ាងទោសដែលមានៈនឹកថា ខ្លួនជាមនុស្សអន់ជាងគេ ម៉្លោះហើយគំនិតអន់នេះមកគ្របដណ្តប់ក្មេង ឲ្យខ្លាចមិនហ៊ាននិយាយស្តី ឬធ្វើអ្វីឡើងចេះតែតាំងខ្លួនជាមនុស្សចាញ់ជានិច្ច ។ កូនខ្មែរយើង ដោយប្រទេសយើងធ្លាប់នៅខ្ញុំចំណុះគេ រមែងមានចិត្តចាញ់នេះច្រើនណាស់ ។ ផ្ទុយទៅវិញ ទោសម្យ៉ាងទៀត គឺកុមារដែលដាក់ចិត្តខ្ពស់ពេកថា ខ្លួនចេះតែគ្រាន់បើជាងគេទាំងអស់ ក៏កើតចិត្តព្រហើនមើលងាយមិត្តឯទៀត ឬជារឈ្លើយខុសទំនង ។

គ្រូត្រូវដឹកនាំក្មេងឲ្យស្គាល់តម្លៃពិតរបស់វា ដោយបង្កើតឲ្យមានការប្រកួតប្រណាំងដោយយុត្តិធម៌ ៗ ក្នុងការប្រកួតប្រណាំងនេះ លទ្ធផលធម្មតា ត្រូវតែមានចាញ់ឈ្នះជាដរាប ៗ បើយើងត្រូវចាញ់នោះ កុមារត្រូវទទួលចាញ់ដោយសុទ្ធចិត្ត គឺព្រមក្នុងចិត្តថា គេបានឈ្នះយើងដោយយុត្តិធម៌ ដោយគេប្រឹង ដោយគេឆ្លាតជាងយើង ៗ ពេលចាញ់ កុមារមិនត្រូវសំដែងអាការៈឈ្នានីសជោគជ័យរបស់មិត្តភក្តិទេ ឬបង្កើតហេតុអាក្រក់ណាមួយទៅបំផ្លាញជោគជ័យមិត្តភក្តិតាមមធ្យោបាយអយុត្តិធម៌ទេ ៗ

ផ្ទុយទៅវិញ ត្រូវមានការសរសើរដោយសុទ្ធចិត្ត ៗ សិស្សដែលមានជោគជ័យនេះសោតទៀត ត្រូវបញ្ចេញសំដី ឬ កាយវិការណាមួយឲ្យឃើញថា ខ្លួនសមជាប៉ិនតូកៃមែន ប៉ិនប្រសប់មែន ក្នុងក្តីយុត្តិធម៌ដោយមិនហួសហេតុពេក ៗ

---

## មេរៀនទី ៣៨ - ចៀសវាងការជម្លោះ

ផ្តើមការសន្ទនា : សិស្សដែលមានឈ្លោះប្រកែកគ្នានៅសាលារៀន ដល់មានដាល់តប់គ្នាទៅវិញទៅមក ដោយមកពីហេតុដូចម្តេចខ្លះ ?

– ចូរអ្នករ៉ាយរ៉ាប់ពីអាកប្បកិរិយានៃសិស្សម្នាក់ដែលចូលចិត្តបង្កបង្កើតហេតុ ឲ្យមានការឈ្លោះប្រកែកគ្នានៅសាលារៀន ។

## ឧទាហរណ៍បរិយាយ:

រវាងមិត្តភក្តិក្នុងសាលារៀន ត្រូវចៀសវាងការជម្លោះដោយបង្កើតឲ្យមានការជជែកគ្នាតឹងសរសៃកហូតដល់មានការប្រវាយប្រតប់គ្នា ។ ការជម្លោះនេះអាចកើតឡើងដោយការប្រណែនទន្ទា ដោយចិត្តអាក្រក់ ចង់ឲ្យតែមិត្តភក្តិចាញ់ខ្លួន ហើយទាបជាងខ្លួន ឬមកពីការជជែកដោយប្រកាន់យកត្រូវតែម្នាក់ឯង មិនព្រមរំលែកយោបល់មិត្តផង ។

កុមារត្រូវចៀសវាងការជម្លោះប៉ុន្មានប្រភេទដោយដាច់ខាត គឺកុំឲ្យមានជជែកតឹងសរសៃ ការប្រវាយប្រតប់គ្នា ឲ្យរស់ជាមួយគ្នាដោយញញឹមសុខស្រួល ដោយមានសុភាពធម៌រកគ្នាទៅវិញទៅមក ទើបដោយរក្សាចិត្តស្រឡាញ់គ្នាជានិច្ច ។

---

## មេរៀនទី ៣៤ – បើមានមិត្តពិការ

**ផ្តើមការសិក្សា:** បើមានសិស្សពិការនៅក្នុងថ្នាក់មែន សុំលោកគ្រូឆ្លៀតរកឱកាសពេល សិស្សនោះមិនមកសាលាដើម្បីសន្ទនាពីមេរៀននេះ ។

— សួរសិស្សតើម្នាក់ៗ បានប្រព្រឹត្តអំពើល្អអ្វីខ្លះចំពោះមិត្តពិការនោះ ? ។

សិស្សម្នាក់បានទទួលគ្រោះថ្នាក់ទាល់តែត្រូវទៅដេកពេទ្យ ។ សិស្សឯទៀត បេះផ្កាសំរាប់ប្តូរគ្នាម្តងម្នាក់ៗ ...ក់ទៅមិត្តខ្លួននៅមន្ទីរពេទ្យ ។ អ្នកយល់ឃើញដូចម្តេចចំពោះមិត្តភាពបែបនេះ?

## ឧទាហរណ៍បរិយាយ :

បើមានមិត្តភក្តិណាមួយ មានពិការ (បាក់ដៃ - បាក់ជើង - គ្រដិត - ខ្វាក់ម្ខាង) ជាដើម កុមារត្រូវកុំចំអកឲ្យកឡើយដោយទឹកមុខ ដោយការធ្វើតម្រាប់តាម ដោយសំដីបញ្ចិតបញ្ចៀងដល់មិត្តពិការនោះឲ្យសោះ ។ តែយើងត្រូវធ្វើដូចជាមិនដឹងខ្លួន មិនចាប់អារម្មណ៍ថាមិត្តយើង ជាមនុស្សខុសពីយើងដោយមានពិការភាព ។ ត្រូវក្សាទឹកមុខធម្មតាឲ្យមិត្តពិការនោះជឿក្នុងចិត្តថា គ្នាមិនខុសពីយើងទេ ។ តាមធម្មតា មិត្តពិការរមែងត្រូវការពប់ពានពីមិត្តឯទៀតណាស់ ។ ដូច្នេះ កុមារត្រូវដឹងទុក្ខធុរៈមិត្តពិការ ត្រូវជួយដោះទុក្ខគ្នា ក្នុងរឿងជីវិតធម្មតាដែលកើតឡើងដោយពិការភាពនោះ ។ ឧទាហរណ៍ : បើមិត្តយើងបាក់ជើងម្ខាង បើមានការត្រូវឡើងជណ្តើរខ្ពស់ ត្រូវយើងជួយដឹកដៃ ។

---

| មេរៀនទី ៤០ - រាប់មិត្តសិស្សស្រីប្រុស |
| --- |

ផ្តើមការសន្ទនា : ចំពោះសិស្សប្រុស = អ្នកបានប្រុងប្រយ័ត្នដោយបទណាខ្លះ ដែលបង្ហាញឲ្យឃើញថាអ្នកគោរពភេទស្ត្រីនៃមិត្តរបស់អ្នក ?

ចំពោះសិស្សស្រី = នាងបានប្រុងប្រយ័ត្នដោយបទណាខ្លះ ដើម្បីការពារកេរ្តិ៍ឈ្មោះនាងនៅមុខមិត្តប្រុសៗ នៅថ្នាក់ជាមួយគ្នា ?

## ឧទាហរណ៍បរិយាយ :

សិស្សប្រុសនឹងសិស្សស្រី ដោយហេតុមានភេទខុសគ្នា ក្នុងការទាក់ទងរវាងគ្នា ត្រូវធ្វើឡើងឲ្យសមរម្យ ។ សិស្សប្រុសមិនត្រូវនិយាយចំពោះមុខសិស្សស្រីនូវរឿងខ្លះដែលយើងអាចនិយាយប្រាប់បានតែសិស្សប្រុស ។ ការធ្វើកាយវិការរបៀបនិយាយលេងក៏ដូច្នោះដែរ គឺនៅចំពោះមុខមិត្តស្រី យើងត្រូវធ្វើផ្សេងពីចំពោះមុខមិត្តប្រុស ដោយចៀសវាងធ្វើអំពើទៅប៉ះទង្គិចសេចក្ដីអៀនខ្មាសរបស់ស្រី ។ នៅចំពោះមុខមិត្តប្រុស ត្រូវមានសំដីសំដៅ - កាយវិការផ្សេងពីនៅចំពោះតែស្រីគ្នាឯង ។

ត្រង់នេះ ត្រូវរំឭក ជូនកាលមានការផ្លាស់ខោអាវ លេងល្បែងកីឡា ឬលេងរបាំសិល្បៈជាដើម ស្រីត្រូវធ្វើដោយឡែកស្រី ប្រុសត្រូវធ្វើដោយឡែកប្រុស កុំឲ្យច្របូកច្របល់ មានការស្និទ្ធស្នាលជ្រុល ។

ទំនៀមទម្លាប់បារាំងនឹងខ្មែរខុសគ្នាខ្លាំងណាស់ក្នុងរឿងនេះ ។ ខ្មែរយើងដូចយើងដឹងស្រាប់ ច្រើនប្រកាន់មិនឲ្យស្រីប៉ះពាល់ សូម្បីតែដៃជើងគ្នាក៏មិនបានផង ។ ឯបារាំងវិញ ទំនៀមទម្លាប់គេមិនសូវប្រកាន់ទេ ។ កុមារស្រីប្រុសកាន់ដៃ កាន់ជើងគ្នាជាការធម្មតា រហូតដល់ឱបថើបគ្នាជាការគួរសមរវាងមិត្តនឹងមិត្តផង ។

យើងជាកូនខ្មែរ ថ្វីដ្បិតបានរៀនបារាំងខ្លះ មិនត្រូវយកទម្លាប់បារាំងនេះមកប្រតិបត្តិឲ្យជំទាស់នឹងទំនៀមទម្លាប់ខ្មែរទេ ។ តែយើងក៏មិននៅប្រកាន់របៀបចាស់ហួសសម័យទៅហើយដែរ ។

ព្រលឹងខ្មែរ
www.ameriamerisee.fr

សុភាវធម៌របស់សិស្សនៅក្នុងសាលាចំពោះគ្រូ ទីងចំពោះក្មេងមកសាលា ទីង ចំពោះមិត្តភក្តិមានច្រើនណាស់ ។ បើគ្រូប្រុងប្រយ័ត្នតែសង្កេត អាចឃើញអំពើសិស្ស មិនសមរម្យស្ទើរតែគ្រប់នាទី ក្នុងសម័យបច្ចុប្បន្ននេះ ។

បើគ្រូសង្កេត បានឃើញមិនសមរម្យត្រង់ណាហើយ អាចទាញយកមកធ្វើជាមេរៀនបង្ហាត់បង្ហាញសិស្សគ្រប់គ្នាយ៉ាងស្រួលបាន ។

---

[illegible]

[illegible]

[illegible]

[illegible]

[illegible]




# ជំពូកទី ៦

# អាកប្បកិរិយាដែលត្រូវប្រព្រឹត្តនៅទីកន្លែងសាធារណៈ



## មេរៀនទី៤១– កុមារនៅទីកន្លែងសាធារណៈ

### ផ្ដើមការសន្ទនា : អ្វីខ្លះដែលហៅថាកន្លែងសាធារណៈ ?

– នៅកន្លែងសាធារណៈអ្នកបានប្រុងស្មារតីដោយរបៀបណាខ្លះ ដែលអាចការពារកិត្តិនាមអ្នកជាសិស្សសាលា ?

ជនបរទេសគេអាចសន្និដ្ឋានបានដូចម្ដេច បើគេឃើញយុវជនខ្មែរភាគច្រើនចោលក្រដាស សំរាមនៅសួនក្រុង បត់ជើងតូចតាមដងផ្លូវ ទាក់ស្ដោះតែពាស ?

### ឧទាហរណ៍បរិយាយ :

*សិស្សសាលាមិនមែនត្រូវតែមានសុភាវធម៌ក្នុងគ្រួសារ និង ក្នុងសាលាប៉ុណ្ណោះទេ ។ កុមារសិក្សាដែលល្អ ត្រូវមានសភាពសមរម្យនៅកន្លែងសាធារណៈ កុំឲ្យកុមារយល់ថា ៖ « អញចង់ធ្វើអ្វីបានតាមចិត្ត » ។ ផ្ទុយទៅវិញគឺនៅទីសាធារណៈនេះហើយ ដែលកុមារមានការទាក់ទងចំពោះមនុស្សច្រើនប្រភេទឥតគណនា ។ ដូច្នោះ កុមាររឹតតែប្រឹងស្មារតីរក្សាសុភាវធម៌ឲ្យបានខ្ជាប់ខ្ជួន ហើយឲ្យប្លែកៗទៅតាមកាលៈទេសៈ ទៅតាមទីកន្លែង និងទៅតាមប្រភេទមនុស្សដែលយើងទាក់ទង ។ នៅលំនាំដើមនេះគួររំឭកថា ក្នុងឋានៈជាសិស្សសាលា កុមារមានករណីយកិច្ចមួយត្រូវរក្សាកិត្តិនាម « កិត្តិនាមសិស្សសាលា » ។ គប្បីឲ្យអ្នកផងថា យុវជនអ្នកសិក្សាជាយុវជនមានវិន័យ បេះបញ្ជាប់ទម្លាប់ មានតួជ មិនមែនជាក្រុមយុវជនរជាប់រជោប រលីមរលាម គ្មានវិន័យ ឬមានចិត្តមើលងាយអ្នកផងនោះទេ ។*

សិស្សខ្លះ ដោយនឹកក្នុងចិត្តថា អញជាកូនសិស្ស ជាអ្នករៀន ជាក្មេងមិនទាន់ទទួលខុសត្រូវ អញត្រូវមានសេរីភាពជាងគេ អញអាចធ្វើអ្វីបានទាំងអស់ ដូចជាដើរអាឡេអាឡូតាមវិថី ឬ ក្នុងសួនច្បារជាដើម ។ ការយល់ខុសបែបនេះផ្ទុយពីការសិក្សានៅសាលា ដោយចំពោះ ផ្ទុយពីបទសុភាវធម៌យ៉ាងខ្លាំង ។ កិត្តិនាមសាលាទាំងមូល កិត្តិនាមប្រទេសទាំងមូល គឺធ្លាក់នៅលើបុគ្គលសិស្សនៅទីសាធារណៈនេះហើយ ។

---

## មេរៀនទី ៤២ – គោរពភ្នាក់ងារតម្រួតក្រុង

ផ្ដើមការសន្ទនា: អ្នកឃើញពួកសិស្សមួយក្រុមជិះទោចក្រយានទន្ទឹមគ្នាតាមដងផ្លូវក្រុង ។ ភ្នាក់ងារតម្រួតផ្លុំកញ្ចែហៅឈប់ សិស្សទាំងនោះក៏នាំគ្នាដាក់កង់យ៉ាងលឿន ចែកផ្លូវគ្នារត់បាត់អស់ ។ អ្នកយល់ឃើញដូចម្ដេច ចំពោះអាកប្បកិរិយាសិស្សទាំងនោះ?

ឧទាហរណ៍បរិយាយ:

ក្រុមភ្នាក់ងារតម្រួតក្រុង មានភារៈត្រូវរក្សារបៀបរៀបរយនៅក្នុងក្រុងនីមួយៗ ឲ្យមានសណ្ដាប់ធ្នាប់ដើម្បីឲ្យពលរដ្ឋរស់នៅប្រកបការងារដោយសុខសាន្ត ។ បទល្មើសនឹងរបៀបរៀបរយនៅក្នុងក្រុងរាប់មិនអស់មិនហើយទេ (ប្លន់សម្លាប់ ចរាចរ សន្តិសុខ អនាម័យ . . . ) ហើយទោះបីភ្នាក់ងារតម្រួតមានចំនួនច្រើនយ៉ាងណាក៏ដោយ

បើពលរដ្ឋម្នាក់ៗ មិនយកចិត្តទុកដាក់ប្រឹងស្មារតី ជួយដោយបទផ្សេងៗផង របៀបរៀបរយនោះក៏ពុំអាចកើតឡើងបានឡើយ ។

គោរពភ្នាក់ងារតម្រួត គឺគោរពច្បាប់ក្រុង ប្រតិបត្តិតាមបញ្ញត្តិច្បាប់ក្រុង នៅចំពោះមុខភ្នាក់ងារតម្រួតឬឆ្ងាយពីភ្នែកក្រុមតម្រួត ។ លើសពីនេះទៅទៀត សិស្សានុសិស្សនឹងពលរដ្ឋទូទៅ អាចជួយជាពត៌មានផ្សេងៗដល់ក្រុមតម្រួតក៏សឹងបាន ។ បទសុភាពធម នៅអាការៈចំពោះភ្នាក់ងារតម្រួតមិនបង្ហិដល់ទៅឲ្យឱនក្បាលលើកដៃសំពះ ប្រើពាក្យគួរសមហួសហេតុ ដូចគេតែងប្រទះឃើញជាញឹកញាប់នោះទេ ។ ឈរត្រង់ខ្លួនប្រើភាសាធម្មតា (លោក ខ្ញុំ...) សន្មតថាគ្រប់គ្រាន់ហើយ ។

វឌ្ឍនភាពនៃទីក្រុងនីមួយៗ ប្រទេសគេអាចឲ្យកើតបានដោយសារផ្អែកលើការប្រស្រ័យទាក់ទងគ្នារវាងក្រុមតម្រួតនឹងពលរដ្ឋនេះឯង ។

---

## មេរៀនទី ៤៣— កុមារនឹងច្បាប់ចរាចរ

ផ្ដើមការសន្ទនា : របៀបចេញពីសាលា មានរបៀបធ្វើដូចម្ដេចនៅសាលាអ្នក ?

— សិស្សបី ឬ បួននាក់ជិះកង់ទន្ទឹមគ្នាតាមផ្លូវ ។ ធ្វើយ៉ាងនេះសមនឹងភ្នែកអ្នកផងទាំងពួងទេ ?

— យកសញ្ញាចរាចរម្ដងមួយៗ មកបង្ហាញសិស្ស ហើយសួរពីន័យនៃសញ្ញានោះ ។

## ឧទាហរណ៍បរិយាយ :

ការចរាចរនៅទីក្រុងធំៗ ជាបញ្ហាស្មុគស្មាញមួយ ដែលពិបាកនឹងដោះស្រាយ ។ វិទ្យាសាស្ត្របង្កើតរថយន្តកាន់តែលឿនឡើង ៗ ការគ្រោះថ្នាក់ក៏កាន់តែមានច្រើនឡើង ៗ អ្នកបរឡានដែលបុកគេដោយខុសច្បាប់ គេទុកជាពេជ្ឈឃាតមួយ ។ ដើម្បីនឹងរៀបចរាចរនេះឲ្យរៀបរយ គឺចៀសវាងការគ្រោះថ្នាក់ រាជការចងក្រងជាបទបញ្ជា ដោយមានធ្វើសញ្ញាជារូបភាព ឬជាភ្លើង ឬ ជាសម្លេងកណ្ដឹង ៗ រាជការថែមទាំងមានចាត់ភ្នាក់ងារឲ្យឈរចាំទីកន្លែងប្រជាជនធ្វើសញ្ញាឲ្យអ្នកចរាចរប្រតិបត្តិតាម ថែមទាំងមានភ្នាក់ងារដើរត្រួតត្រាគ្រប់កន្លែង ៗ គ្រោះថ្នាក់ ក៏គង់នៅមាន ៗ

កុមារត្រូវមានសុភាវធម៌ដោយជាក់លាក់ណាស់ចំពោះច្បាប់ចរាចរនេះ ៗ ដំបូងត្រូវដឹងគោលនឹងបទបញ្ជាចរាចរខ្លះ គឺសញ្ញាជារូបភាព ជាភ្លើងពណ៌ ឬ ជាសម្លេង ដែលបញ្ជាឲ្យយើងឈប់ ឲ្យយើងដើរ ៗ ដល់ចេះហើយ ត្រូវប្រតិបត្តិឲ្យបានជាក់លាក់ ៗ

កុមារខ្លះ យកការធ្វើដំណើរតាមវិថីជាការសប្បាយ ការចង់ប្រដែងឲ្យបានលឿនជាងគ្នា នេះជាបទខុសមួយយ៉ាងខ្លាំង ៗ ការធ្វើដំណើរក្នុងវិថីត្រូវប្រុងប្រយ័ត្ន កុំមានចិត្តរំលោភ ព្រហើនមើលងាយអ្នកផងឯទៀត ដោយចង់គៀងដំណើរគ្នាយកឈ្នះ យកបាញ់ ៗ

ក្រុងដែលមានរបៀបរៀបរយហើយ មានលក្ខណៈចរាចរខ្លះដែលសិស្សត្រូវរៀន ដូចតទៅ ៖

គេមានបោះជាដែកគោលធំៗ  កាត់ផ្លូវជាចន្លោះទុកឲ្យសាធារណៈ ស្វ័យប្រវត្តិភ្លើងក្រហមរថយន្តត្រូវឈប់ៈ  អ្នកដើរឆ្លងផ្លូវតាមចន្លោះដែកគោលដែលបានចែងមកហើយៗ  ភ្លើងលឿង ត្រូវប្រុងទាំងអ្នកដើរ  ទាំងរថយន្ត  ព្រោះមានការផ្លាស់ប្តូរឥឡូវហើយៗ  ភ្លើងបៃតង រថយន្តត្រូវទៅ  អ្នកដើរត្រូវឈប់ចាំៗ

មានបង្កើតឲ្យមានរថក្រុងជំនួសយានតូចៗ ដូចជាស៊ីក្លូជាដើមៗ

មានវិធានការណ៍កុំឲ្យស្នូរសម្លេងឮពេក  បង្គាប់ទៅរថយន្តកុំឲ្យបន្លឺសម្លេងញាប់ពេកទឹងមិនឲ្យមានពពាយទាយលក់អីវ៉ាន់ៗ  បើយប់ ត្រូវហាមសោះតែម្តងៗ

សម្លេងទីក្រុងអាចជាហេតុនាំឲ្យរាក់ស្មារតីពលរដ្ឋនៅទីក្រុងផងៗ

គោលៗទាំងនេះ  គប្បីកុមារដឹង  ព្រោះរាជធានីភ្នំពេញ  កាន់តែជិតចូលទៅកាន់ភាពទីក្រុងធំបែបអន្តរជាតិហើយៗ

នៅទីសាធារណៈ  យើងក៏ត្រូវចៀសវាងកុំនិយាយពាក្យបំអាសបំអូងៗ

ដូច្នេះ នៅទីសាធារណៈ  យើងគោរពការស្ងៀមស្ងាត់របស់អ្នកផង  ដោយនិយាយគ្នាហឹមៗ ឲ្យស្តាប់បានតែគ្នាឯង  ហើយកាន់អាកប្បកិរិយាថ្លៃថ្នូរជានិច្ចៗ នៅអឺរ៉ុប  គេគ្មានស្រែកប្រកួកហៅគ្នានៅតាមថ្នល់ ឬ ស្រែកឡូឡាដាក់គ្នា  នៅពេលជួបគ្នាឡើយ  ម្នាក់ៗរក្សាភាពសមរម្យរបស់គេរៀងៗខ្លួនៗ  ទម្លាប់ល្អនេះគួរតែយើងប្រតិបត្តិតាមៗ

## មេរៀនទី ៤២ - គោរពសួនច្បារ

ផ្ដើមការសន្ទនា : អ្នកបានឃើញក្មេងម្នាក់ បេះផ្កានៅសួនច្បារក្រុង ។ អ្នកបានរំឭកដានិរូន្ទានដល់ក្មេងនោះ ។ សំដីអ្នកមានដូចម្ដេចខ្លះ ?

— អ្នកបានឃើញមនុស្សម្នាក់ធ្វើឲ្យបែកដបដាក់ទេចនៅលើទីសួន ហើយដើរព្រងើយទៅបាត់ទៅ ? អ្នកបានធ្វើអ្វីខ្លះបន្ទាប់ពីឃើញដូច្នោះ ? ពីព្រោះអ្វី ?

ឧទាហរណ៍បរិយាយ :

ការគោរពទីស្ថានសាធារណៈមួយបែបទៀត ត្រូវប្រព្រឹត្តឡើងដោយចៀសវាងបោះចោលរបស់កខ្វក់មានសំបកផ្លែឈើជាដើមទៅលើទីស្មៅដែលដាំ ។ សួនច្បារជាកន្លែងលំអមួយដែលបង្កើតបរិយាកាសរីករាយដល់អ្នកផង ។ កាលបើយើងយករបស់កខ្វក់មួយទៅបោះចោលនៅទីនោះ ភាពល្អក៏ល្អក់បាត់អស់ ។ យើងជាអ្នកបានបំផ្លាញភាពល្អ ។ បើកាលៈទេសៈខ្លះនាំយើងឲ្យបរិភោគអ្វីលើវាលស្មៅ លុះបរិភោគរួចហើយ ត្រូវប្រមូលរៀបចំសំបកឈើនិងសំណល់អាហារបោសចោលឲ្យស្អាត កុំទុកឲ្យមានជាសំណល់បំផ្លាញភាពល្អនៃធម្មជាតិនោះ ។

កុំទម្លាប់បេះបោចផ្កានិងផ្លែឈើដែលនៅក្នុងសួនសាធារណៈ ។ ផ្កានិងផ្លែទាំងនេះ ជារបស់រដ្ឋការ គឺជារបស់ទាំងអស់គ្នា ។ មិនមែនតែមិនគោរពដល់សួន ដល់ធម្មជាតិប៉ុណ្ណោះទេ ថែមទាំងអាចចាត់ទុកជាអ្នកលួចរបស់សាធារណៈផង ។

ទម្លាប់អាក្រក់មួយបែប គឺបត់ជើងតូចធំនៅទីសួន ។ ទម្លាប់នេះជាទម្លាប់ខុសបំផុត ត្រូវចៀសវាង ។ សួនច្បារជាកន្លែងសិរីសួស្ដី ជាកន្លែងរីករាយដែលអ្នកផងមកកំសាន្ត មកយកខ្យល់អាកាសល្អ ។ ចុះបើយើងនាំគ្នាបត់ជើងបត់ដៃទីនោះ សួននឹងមានសភាពយ៉ាងដូចម្ដេចទៅវិញ ? ។

នៅទីក្រុងធំៗ គេមានធ្វើសួនល្អៗ ដើម្បីឲ្យពលរដ្ឋមកសម្រាក ដើរលេងនៅទីនេះ ។ រាជធានី នឹង ទីក្រុងយើង នៅខេត្តខ្លះកាន់តែមានសភាពនេះជាលំដាប់ហើយ ។

---

## មេរៀនទី ៤៥ –

## វត្ថុជាសាធារណៈ ជាទ្រព្យជាតិ នេះសភាពល្អ

ផ្ដើមការសន្ទនា : យកឧទាហរណ៍ក្មេងដែលដឹកគោឲ្យស៊ីស្មៅតាមចិញ្ចើមថ្នល់ ។ ក្មេងខ្លះយកកាំបិតទៅកាប់ដើមឈើតាមខាងផ្លូវ ខ្លះទៀតយកធ្យូងទៅគូរលើផ្ទាំងរបាំង ។ល។ . . . មកសន្ទនានឹងសិស្ស ។

ឧទាហរណ៍បរិយាយ :

វត្ថុជាសាធារណៈ ហើយជាសម្បត្តិជាតិមានដូចជាផ្លូវថ្នល់ បង្គោលខ្សែលួស ដើមឈើដែលដាំតាមបណ្ដោយផ្លូវ ផ្ទាំងសញ្ញាចរាចរ ស្ពាន ផ្លូវដែកអយស្ម័យយាន ហើយនៅជិតសិស្សនេះ មានអាគារសិក្សា មន្ទីរ ឬ ក្រសួងរាជការនានា ព្រមទាំងសង្ហារណៈដែលមាននៅក្នុងនោះ ។

រីឯតំបន់នោះសុទ្ធជាសម្បត្តិជាតិ កើតឡើងដោយធម្មជាតិ គឺសម្បត្តិពលរដ្ឋទាំងអស់គ្នា ។ បំផ្លាញរបស់តំបន់នោះសន្មតថា បំផ្លាញសម្បត្តិជាតិទាំងមូល ។ ច្បាប់រដ្ឋមានចែងច្បាស់ណាស់ ចំពោះបទបំផ្លាញផ្សេងៗដែលនាំឱ្យខូចខាតរបស់នោះៗ ពលរដ្ឋម្នាក់ៗ មិនគ្រាន់តែមិនត្រូវបំផ្លាញរបស់នោះទេ ត្រូវជួយថែរក្សា ជួយឱ្យពត៌មានដល់ពួកការពារបទល្មើសផ្សេងៗ ថែមទៀត ។

ទេសភាពល្អដែលគេឃើញតាមជនបទនានា ក៏ចាត់ទុកជាសម្បត្តិរដ្ឋបានដែរ មានដូចនៅកែប ទឹកឈូ ទឹកធ្លាជាដើម ទេសចរនិយមមកលេងកំសាន្តៗ បំផ្លាញទេសភាពល្អនោះ មានដូចកាប់ដើមឈើ បេះផ្កា ធ្វើឱ្យកខ្វក់ ។ ព្រៃឈើក៏ជាសម្បត្តិដែរ ផលប្រយោជន៍នៃព្រៃឈើមានវែងឆ្ងាយណាស់ យើងពុំអាចរាប់អស់នៅពេលនេះឡើយ ។ ភ្លើងជាសត្រូវធំនៃព្រៃឈើ ។ កុមារកុមារី និងពលរដ្ឋទូទៅ មានករណីយកិច្ចត្រូវបំពេញចំពោះសម្បត្តិជាតិទាំងនោះដូចៗគ្នា ។

---

## មេរៀនទី ៤៦ – អំពីស្តោះនិងកណ្តាស់

**ផ្តើមការសិក្សា** : បង្ហាញរបៀបស្តោះ និង កណ្តាស់ ដែលមិនរំខានអ្នកផង ។

– នៅក្នុងរថយន្តកំពុងបរ អ្នកអង្គុយមុខម្នាក់មិនបានប្រយ័ត្នស្តោះទឹកមាត់ទៅខាង ។ តើមានកើតហេតុយ៉ាងម្តេចខ្លះ ?

## ឧទាហរណ៍បរិយាយ:

ការស្ដោះទឹកកណ្ដាស់ដែលប្រព្រឹត្តឡើងដោយពុំ ជាបទរំខានអ្នកដទៃ ។ អ្នកដទៃអាចឈ្លើមពីការខាកស្ដោះទឹក ការកណ្ដាស់នោះ ។ អ្នកមិនបានដឹងនូវរឿងនេះ ធ្វើការខាកស្ដោះទឹកកណ្ដាស់នៅមុខគេធម្មតា មាននៅពេលបរិភោគ ឬនៅពេលដើរតាមផ្លូវជាដើម ។

ប្រទេសអឺរ៉ុបគេហាមប្រាមមិនឲ្យខាកស្ដោះរហូតដល់កុំកណ្ដាស់ ។ តែបើយើងចៀសមិនរួចត្រូវប្រព្រឹត្តឡើងដោយលាក់លៀម ។

យើងអាចយករបៀបអឺរ៉ុបមកប្រើ គឺម្នាក់ៗគោងមានកូនកន្សែងដៃមួយ ។ បើត្រូវការស្ដោះ យកកន្សែងខ្ចប់មាត់លបស្ដោះដាក់កន្សែង ។ បើត្រូវការកណ្ដាស់ យកកន្សែងខ្ចប់ច្រមុះកណ្ដាស់ដាក់កន្សែង បត់កន្សែងនោះដាក់ហោប៉ៅទៅផ្ទះបោកភ្លាម ៗ ។

ខ្មែរយើងគប្បីនាំគ្នាប្រឆាំងនឹងការស្ដោះ ដែលម្នាក់ៗច្រើនប្រព្រឹត្តឡើងដោយឥតដឹងខ្លួន នៅពេលបរិភោគគុយទាវព្រឹកៗ ពេលបាយ ពេលជិះកង់ឬស៊ីក្លូ (ជួនកាលស្ដោះប៉ើងទឹកមាត់ ឬ កំហាកមកលើអ្នកជិះក្រោយ) ។ កំហុសខាកស្ដោះអាចចាត់ទុកជាកំហុសទូទៅនៅប្រទេសខ្មែរ ។ គួរតែនាំគ្នាកុំខាកស្ដោះខុសសុភាវធម៌ទៅទៀត ។

# មេរៀនទី ៦៧ — របៀបរៀបរយ

ផ្ដើមការសិក្សា : បង្ហាញរបៀប "ឈរបន្ទាត់" នៅមុខកន្លែងទិញសំបុត្រល្ខោនឬភាពយន្ត ។

— កន្លែងណាខ្លះដែលត្រូវរក្សាភាពស្ងប់ស្ងៀម ?

## ឧទាហរណ៍បរិយាយ:

ទីសាធារណៈនិមួយៗ រមែងមានសណ្ដាប់ធ្នាប់និងភាពស្ងៀមស្ងាត់របស់គេ ។ យើងមិនត្រូវប្រើអាកប្បកិរិយាណាមួយ ទៅបំបាត់សណ្ដាប់ធ្នាប់និងភាពស្ងៀមស្ងាត់នៃទីសាធារណៈឡើយ ។ ផ្ទុយទៅវិញ យើងត្រូវរក្សានិងគោរពសណ្ដាប់ធ្នាប់ ។ រាជធានីយើងនិងទីក្រុងខ្លះកាន់តែរីកធំគួរសមដែរហើយ ។ មនុស្សក៏កាន់តែកើតច្រើន ។ ម្ល៉ោះហើយក្នុងការចរាចរក្ដី ក្នុងការទិញអីវ៉ាន់ក្ដី រមែងមានការប្រជ្រៀតគ្មានសណ្ដាប់ធ្នាប់ ។

ច្បាប់សុភាវធម៌ហាមយើងមិនឲ្យប្រជៀតដុះប្ដុះ ឲ្យយើងចេះ "ឈរបន្ទាត់" គឺឈរតគ្នាចាំដល់វេនយើងសឹមក្បូល ។ អ្នកណាមកមុន គេឈរមុខ អ្នកណាមកក្រោយ ឈរក្រោយ ឥតមានរើសបានះឡើយ ។ ការឈរបន្ទាត់នេះ ច្រើនត្រូវធ្វើនៅចំពោះផ្ទះជំនួញ នៅចំពោះបន្ទប់ទិញសំបុត្រមើលទស្សនីយភាព នៅចំពោះកន្លែងចំណតរថក្រុង និងបន្ទប់បត់ជើង ។

ដែលហៅថារថក្រុង គឺរថយន្តធំៗដែលបើកតាមវិថីនៅក្រុង សម្រាប់ដឹកនាំអ្នកទៅមកជំនួសស៊ីក្លូសព្វថ្ងៃនេះ ។ ទីក្រុងធំៗតែងមានរថក្រុងជាធម្មតា ។ រថក្រុង

នេះមានមនុស្សគ្រប់ប្រភេទជិះប្រជ្រៀតគ្នាជាច្រើន ដូច្នេះ ត្រូវមានច្បាប់សុភាពធម៌នៅលើរថភ្លើងជាច្រើនដូចជា ៖

បើប៉ះគេ ឬ ជាន់ជើងគេ ឲ្យសុំទោស ប្រសបើឃើញមនុស្សស្រី មនុស្សចាស់ ឬមនុស្សមានផ្ទៃពោះ មនុស្សពិការ ត្រូវជូនកន្លែងអង្គុយទៅមនុស្សនោះ ៗ ត្រូវស្លៀកពាក់ដោយសមរម្យផង កុំកាន់វត្ថុជាប់នឹងខ្លួនច្រើនពេក ឬ វត្ថុណាដែលមានក្លិនស្អុយឆ្អាប ។

---

## មេរៀនទី៤៨– គ្រោះថ្នាក់នឹងទុក្ខអ្នកដទៃ

**ផ្តើមការសន្ទនា** : អ្នកកំពុងតែស្តាប់ភ្លេងសប្បាយ សើចលេងក្អាកក្អាយជាមួយនឹងបងប្អូនអ្នក មានក្បួនដង្ហែសពមកដល់មុខផ្ទះអ្នក ។ អ្នកធ្វើដូចម្តេចខ្លះ ?

- អ្នកប្រទះឃើញគ្រោះថ្នាក់មួយយ៉ាងធ្ងន់តាមបណ្តោយផ្លូវ ។ អ្នកអាចជួយយកអាសាបានដោយបែបណាខ្លះ ?

**ឧទាហរណ៍បរិយាយ** :

កុមារប្រកបដោយសុភាពធម៌ចេះសំដែងអាកប្បកិរិយាចំពោះទុក្ខអ្នកផង ៗ នៅទីសាធារណៈ ទុក្ខអ្នកផងរមែងមានដោយ : ការគ្រោះថ្នាក់តាមវិថី ដោយមានក្បួន

ដង្ហែសព ឬ ដោយឃើញពិការភាពនៃអ្នកផង ។ នៅចំពោះមុខព្រឹត្តិការណ៍ទាំងនេះ កុមារត្រូវមានករុណាធម៌សំដែងឡើង តាមអាកប្បកិរិយាក្រៅជាភាពសមរម្យ ទឹកមុខស្រងូតស្រងាត់ ឬ ទៅជួយរំលែកទុក្ខគេតែម្ដង ។

បើជាការគ្រោះថ្នាក់ កុមារត្រូវខ្នះខ្នែងសួររកភ្នាក់ងារនគរបាលទទួលខុសត្រូវ ។ បើមានការរបួស យើងជួយសម្រាលឈឺចាប់បានប៉ុន្មាន យើងជួយប៉ុណ្ណោះ ហើយអាចជួយជាអ្នកសាក្សីឲ្យពិតមានដោយយុត្តិធម៌ទៀត ។ តែមិនត្រូវទៅរំខានគេ បើយើងពុំអាចជួយយកអាសាបានទេ ឈរមើលជិតជាការរំខានដល់ភ្នាក់ងារតម្រួត ហើយនាំឲ្យអ្នករងគ្រោះរកខ្យល់ដកដង្ហើមពុំបានផង ។

បើជាក្បួនដង្ហែសព បើមានមួកត្រូវដោះមួក កុំដើរ ឬ ជិះកាត់ក្បួនដង្ហែសព កុំធ្វើទឹកមុខសប្បាយ កុំបញ្ចេញវាចាខ្លាំង ៗ ចំពោះមនុស្សពិការ យើងត្រូវធ្វើកុំឲ្យមនុស្សពិការចាប់អារម្មណ៍ថា យើងជួបចិត្តសង្វេគពិការភាពរបស់គ្នា តែបើគ្នាមានការពិបាកយ៉ាងណាមួយ ត្រូវយើងទៅជួយយកអាសាគ្នាភ្លាម ដូចជាដឹកដៃជូនដល់ជាដើម ។

---

## មេរៀនទី ៤៩ – របស់ដែលរើសបាន

**ផ្ដើមការសន្ទនា** : តាមផ្លូវ អ្នកបានប្រទះឃើញនឹងប៉ាកកាស៊ីឡូមួយយ៉ាងស្អាត ។ មានសុភាវធម៌បង្ខំឲ្យអ្នកធ្វើដូចម្ដេចពេលនោះ ?

– បើម្ចាស់របស់គេតបស្នងដោយប្រាក់កាស ជូនអំពើទៀងត្រង់របស់អ្នក តើអ្នកទទួលយករង្វាន់នេះទេ ? ហេតុអ្វី ?

## ឧទាហរណ៍បរិយាយ :

បើសិនជាយើងរើសបានវត្ថុអ្វីមួយ យើងត្រូវជំនះចិត្តលោភរបស់យើង ហើយយកវត្ថុនោះទៅប្រគល់ដល់ដៃភ្នាក់ងារ ដែលទទួលខុសត្រូវពីវត្ថុបាត់ ឬបើឃើញម្ចាស់ត្រូវឲ្យម្ចាស់គេវិញ ដោយចិត្តស្មោះត្រង់ឥតកួញកាញចង់បានរង្វាន់ពីគេឡើយ ។

គួរប្រព្រឹត្តតាមវិន័យក្រមកាយរិទ្ធិ ដែលគេហាមមិនឲ្យសមាជិកគេទទួលរង្វាន់ផ្សេងៗ ជាដាច់ខាត កាលណាគេបានប្រព្រឹត្តអំពើល្អអ្វីមួយចំពោះអ្នកដទៃ ៗ ពាក្យថាអរគុណមួយម៉ាត់ ឬទឹកមុខរីករាយដែលគេតបមកកាយរិការយើង គួរយើងទុកជារង្វាន់យ៉ាងប្រសើរហួយបាន ។

---

**មេរៀនទី ៥០ – អំពីរថក្រុង**

ផ្តើមការសន្ទនា : រថក្រុងខុសពីរថធម្មតាដូចម្តេច ?

ត្រូវចេះគួរសមដោយរបៀបណាខ្លះនៅលើរថក្រុង ? (អីវ៉ាន់ ចាស់ជរា មនុស្សពិការ ស្ត្រីមានគភ៌ សុំទោស អរគុណ . . )

– បើត្រូវស្តោះ ឬកណ្តាស់ផ្ទុសពុំបាន តោងប្រុងប្រយ័ត្នដូចម្តេចខ្លះ ?

## ឧទាហរណ៍បរិយាយ :

យើងមកដល់អវិត្រូវអធិប្បាយពីរថក្រុងទៀត ៗ មានរថក្រុងជារថយន្តធំៗ ជារថយន្តដែលប្រើកម្លាំងអគ្គិសនី ឬជារថភ្លើង រទេះភ្លើងក្រុង ៗ នៅក្រុងធំៗ ប៉ារីស

ឡុងដុង មូស្គូ ។ល។ មានរថភ្លើងក្រុងបរក្នុងដីតាមផ្លូវដែលជីកក្រោមក្រុង ។ នៅក្រុងធំ ៗ ដូច្នេះ នៅមានតែឡានតាក់ស៊ី ឯស៊ីក្លូ ឬរ៉ឺម៉កគ្មានទេ ។ រថក្រុងទាំងនោះបរមានរយៈ ។ ដល់រយៈ គេឈប់ មានមនុស្សចុះ មានមនុស្សឡើង ។ បទសុភាពធម៌បង្គាប់ថា តាមរយៈ ត្រូវយើងបន្តកន្ទុយ គោរពវេនយើង មិនប្រជ្រៀត មិនដណ្ដើមឡើងឲ្យតែពីខាងបាន ។

នៅក្នុងរថក្រុង តែងមានកន្លែងអង្គុយនឹងកន្លែងឈរ ។ បើយើងមានកន្លែងអង្គុយ ហើយមានមនុស្សស្រីឡើងមកគ្មានកន្លែង សុភាពធម៌បង្គាប់ឲ្យកន្លែងនោះទៅមនុស្សស្រី ឯយើងឈរវិញ ។ ចំពោះមនុស្សពិការ ស្ត្រីមានគភ៌ក៏ដូច្នេះដែរ ។ បើយើងមានកន្លែងអង្គុយ គោងជូនកន្លែងនោះទៅមនុស្សទាំងនោះ ។

ក្នុងរថក្រុងនេះច្រើនតែចង្អៀត ដូច្នេះយើងត្រូវកុំនិយាយខ្លាំង ៗ បើមានការនិយាយគ្នានិយាយខ្សឹប ៗ កុំជក់បារីបង្ហុយផ្សែង កុំស្ដោះ កុំធ្វើកាយវិការប្រងើង-ប្រង៉ាង ។

ក្រុងភ្នំពេញទើបមានរថក្រុងក្នុងពេលថ្មីៗនេះ គប្បីកុមារសិក្សាសុភាពធម៌ក្នុងរថក្រុងឲ្យដឹងជាមុនខ្លះ ។

ចំពោះកុមារ បើសិនជាមានប្រុសឯណា ឲ្យកន្លែងអង្គុយក្នុងរថក្រុងមកយើង យើងត្រូវពោលថា " អរគុណ " ដល់គេ ។ យើងជាក្មេង ទោះយើងជាស្រីក៏ដោយ បើឃើញមនុស្សពិការ មនុស្សចាស់ មានមនុស្សមានផ្ទៃពោះ ត្រូវយើងជូនកន្លែងអង្គុយទៅមនុស្សទាំងនោះ ។

លើរថក្រុងក្តី តាមវិថីក្តី បើមានអ្នកផងណាសួរពត៌មានអ្វីមួយដល់យើង យើងត្រូវជូនពត៌មានទៅគេ ដោយរាក់ទាក់ ដោយសំដីទន់ភ្លន់ ដោយចិត្តចង់យកអាសា ។ ចំពោះបរទេស បើយើងឲ្យពត៌មានបានល្អ ជាការប្រសើរលើកកិត្តិយសជាតិយើងយ៉ាងអនេក ។

---

## មេរៀនទី ៩១ – តាមបណ្តោយវិថី

ផ្តើមការសន្ទនា : **អ្នកឃើញស្ត្រីចាស់ម្នាក់ កាន់អីវ៉ាន់ធ្ងន់នៅដៃ ហើយចង់ឆ្លងកាត់ថ្នល់ តែញញើតញញើមមិនហ៊ានឆ្លង ។ អ្នកគួរធ្វើដូចម្តេច ?**

ឧទាហរណ៍បរិយាយ :

តាមចិញ្ចើមវិថី ក៏មានសុភាវធម៌ទៀត ។ កុមារមិនត្រូវហួងហែងចិញ្ចើមវិថីឡើយ ដោយដើរជាជុំ ជាក្រុម ឬ ដើរឥតសណ្តាប់ធ្នាប់ ដើរបណ្តើរ ប្រឡែងគ្នាបណ្តើរ ។

បើឃើញកូនក្មេង ឬ មនុស្សចាស់ត្រូវការដើរឆ្លងកាត់វិថី យើងត្រូវទៅជួយដឹកដៃកូនក្មេង ឬ មនុស្សជរានោះ ដឹកដៃដោយមើលនាយអាយចៀសវាងគ្រោះថ្នាក់ កុំឲ្យរថយន្តមកប៉ះទង្គិចបាន កុំដឹកដៃឲ្យដើរលឿនពេក កញ្ឆក់ ឬ បំភ័យ ត្រូវធ្វើឡើងឲ្យសមរម្យ ។ បើជនទាំងនោះមានរបស់យួរ ត្រូវយើងជួយយួរផង ។

កុមារប្រុស បើជួបនឹងជនដែលគួរគោរពត្រូវបើកមួកគោរពជននោះ ដោយទឹកមុខញញឹមញញែម ដោយបន្ទូរវាចាសួរបានដូចថា :

“ លោកអ៊ុំអញ្ជើញទៅណាមកណា ? ” ។ ត្រូវចៀសវាងធ្វើជាមិនឃើញ ហើយធ្វើទឹកមុខក្រអឺតដាក់ ។

---

## មេរៀនទី៥២ – ភេទទស្សនីយភាពនិងសន្និសីទ

<u>ផ្ដើមការសន្ទនា</u> : ជនដែលរំខានគេឯង នៅក្នុងរោងកុន រោងភាពយន្ត ឬ សន្និសីទ តើរំខានដោយរបៀបណាខ្លះ ?

គេស្ដាប់សន្និសីទស្ងៀមគ្រប់គ្នា កុមារមួយនេះងាកឆ្វេងងាកស្ដាំ បង្ខិតកៅអីឮសូរ ។ កុមារនេះប្រព្រឹត្តខុសនឹងបទសុភាវធម៌ត្រង់ណា ? ។

<u>ឧទាហរណ៍បរិយាយ</u> :

សុភាវធម៌នៅរោងទស្សនីយភាព (ភាពយន្ត - ល្ខោនសិល្បៈ - របាំ - តន្ត្រីជាដើម) រឿងនេះជារឿងបន្ថែមមួយទៀត ។ អ្នកខ្លះខ្លះសុភាវធម៌នៅក្នុងរោងទស្សនីយភាព ត្រឡប់ទៅជាធ្វើឲ្យពុ សម្ងំរំខានអ្នកឯទៀត ដោយការបរិភោគ ឬ ដោយនិយាយគ្នា ។ តាមបទសុភាវធម៌ត្រូវមករោងទស្សនីយភាពឲ្យទាន់ពេលវេលា ។ បើយើងមកមិនទាន់ហើយចូលទៅក្នុងរោងពេលសិល្បៈកំពុងសំដែង ជាបទរំខានទស្សនិកជនឯទៀត ទាំងរំខានសិល្បករយ៉ាងអនេក ។

នៅពេលដែលសិល្បករកំពុងសំដែង អ្នកខ្លះដែលសមរម្យ ទស្សនិកជនត្រូវសំដែងចិត្តអបអរដោយទះដៃ ។ ការទះដៃនេះទៀត ត្រូវតែឲ្យត្រូវបែបបទ កុំទះខុសចំនង កុំទះបញ្ឆោរផ្តួលផ្តាប ទំរំខានសិល្បករទៅវិញ ។

កុមារត្រូវយល់ថា នៅសម័យនេះ សិល្បករជាពលរដ្ឋថ្លៃថ្នូរ មិនមែនជាជនថោកទាបដែលយើងត្រូវហៅ អា មីង ឬមើលងាយមើលថោកឡើយ ។

ផ្ទុយទៅវិញ គោរពនឹងថា សិល្បករជាជនម្នាក់វិស្វករសត្តានមនោសញ្ចេតនា នឹងជាតំណាងជាតិខាងសិល្បៈវប្បធម៌ ។

នៅក្នុងសន្និសីទក៏ដូចជានៅរោងទស្សនីយភាពផ្សេងៗដែរ សុភាពធម៌បង្គាប់ឲ្យយើងរៀបចំឫកពា កាយវិការដូចគ្នាដែរ ។

---

## មេរៀនទី ៨៣
## ពិពណ៌នាកន្លែងតាំងរបស់មានតម្លៃផ្សេងៗ

**ផ្ដើមការសន្ទនា :** នៅកន្លែងពិពណ៌អចិន្ត្រៃយ៍សង្គម អ្នកឃើញក្មេងម្នាក់យកក្រាមដៃ ទៅស្ទាបផ្ទាំងគំនូរ នឹងវត្ថុបូរាណផ្សេងៗ ។ តើអ្នកយល់ឃើញដូចម្ដេចចំពោះអាកប្បកិរិយាក្មេងនេះ ?

**ឧទាហរណ៍បរិយាយ :**

កន្លែងតាំងរបស់មានតម្លៃ មានច្រើនបែបច្រើនយ៉ាងណាស់ មានពិពណ៌សេដ្ឋកិច្ច ផ្ដើម៉ុកេងមុយយាម ពិពណ៌អចិន្ត្រៃយ៍នៃសមិទ្ធិសង្គម ពិពណ៌រូបភាព ពិពណ៌គំនូរ

ផាត់ពណ៌ សារមន្ទីរជាតិ ។ នៅតាមជនបទនានា គេតែងឃើញមានកន្លែងតាំងបុរាណវត្ថុតាមវត្តអារាមខ្លះ ។

កុមារ, កុមារីមិនលែងមានឱកាសចូលទៅមើលវត្ថុទាំងនោះ ដោយម្នាក់ឯង ឬ ដោយក្រុម ៗ ត្រូវប្រុងប្រយ័ត្នស្មារតី តាមបែបបទដូចតទៅនេះ ៖

- រក្សាភាពស្ងប់ស្ងៀមជាកិច្ចគោរពដល់ស្នាដៃនៃបុព្វបុរសដែលទុកកេរ្ដិ៍ដំណែលប្រសើរឲ្យយើងឃើញ ។

- គោរពតាមបទបញ្ញត្តិដែលមាននៅកន្លែងនោះ ។

- កុំពាល់ កុំស្ទាប មើលតែនឹងភ្នែកបានហើយ ។

- បើមានអ្វីមិនពេញចិត្តយើង ឬ ដែលយើងមិនយល់ (រូបភាពគំនូរ) កុំបង្អាប់ កុំបញ្ចេញការធ្លល់របស់យើងហួសហេតុ ។ ដូនកាលមានម្ចាស់របស់ ឬ បងប្អូនគេឈរនៅជិតយើង ។ ផ្ទុយទៅវិញ កុំបញ្ចេញការសរសើរហួសហេតុ ព្រោះមានទស្សនិកជនខ្លះ គេមិនមានរសដូចយើង ។



# ជំពូកទី ៧

# សុភាវធម៌នៅពិធីបុណ្យសាសនា

# និងនៅវត្តអារាម

## មេរៀនទី ៥៤ – អំពីសាសនា

ផ្ដើមការសន្ទនា : នៅនគរខ្មែរយើង បណ្ដាជនប្រព្រឹត្តសាសនាអ្វីខ្លះ ?

– ព្រះពុទ្ធសាសនាយើង អាចសង្កេតលើវត្ថុ ឬទម្លាប់អ្វីខ្លះ ? (វត្តអារាម ព្រះសង្ឃ ព្រះពុទ្ធរូប ...) ។

ឧទាហរណ៍បរិយាយ :

រឿងនេះអាចមានកើតឡើងជាបញ្ហា អ្នកអប់រំខ្លះរមែងមានយោបល់ថា រឿងសាសនាជារឿងដោយឡែក ជារឿងជំនឿរបស់ពលរដ្ឋ ហើយពលរដ្ឋម្នាក់ៗ មានសិទ្ធិសេរីភាពជឿ ឬ មិនជឿសាសនា ។

យើងក៏យល់ស្របដូចអ្នកអប់រំទាំងនេះដែរ ៖

សេចក្ដីនៅនេះ ឥតជាបទអំពាវនាវហៅជនណា ឬណែនាំកុមារឲ្យជឿ ឬប្រព្រឹត្តសាសនាណាមួយឡើយ ។ តែយើងគ្រាន់តែសុំរំលែកញែកតាមបទសុភាវធម៌ប៉ុណ្ណោះ ដែលណែនាំយើងឲ្យមានអាកប្បកិរិយាក្រៅ ស្របទៅតាមចំនួនភាគច្រើន ព្រោះមិនចង់ឲ្យអាកប្បកិរិយាយើងឈ្លើយតែម្នាក់ឯងរំខានចិត្តអ្នកផង ។

ខ្មែរយើងភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ សាសនានេះដូចសាសនាឯទៀតមានទំនៀមទម្លាប់ មានរបៀបបទប្រតិបត្តិ មានពិធីបុណ្យ ដែលអ្នកស្រុកនិយមនាំគ្នាធ្វើតាមវត្ត ។

រឿងដែលគេធ្វើនោះខុស ឬ ត្រូវ ក៏មិនមែនជាបញ្ហាដែលយើងលើកមកជជែកក្នុងពេលនេះ តែរឿងដែលយើងចង់ថានោះ គឺ នៅតាមបទសុភាវធម៌ ។ បើខ្មែរទាំងអស់ចេះសូត្រធម៌ទៅហើយ ហើយមានគ្រូបង្រៀនឬសិស្សអង្គុយស្ងៀម នោះជាការមិនសមរម្យទេ ។

យើងរស់ជាមួយខ្មែរ ត្រូវមានភាពសមរម្យជាមួយខ្មែរ ហើយមិនចង់ឲ្យខ្មែរខូចចិត្តដោយសារយើង ចោទថាយើងជាពួកទំនើបអសៃយសាសន៍ ។

## មេរៀនទី ៥៥ – រឿងសូត្រធម៌

**ផ្ដើមការសន្ទនា :** នៅឱកាសបុណ្យទាន ក្នុងសាលា ឬក្នុងគ្រួសារ សុខអង្គុយជាមួយមីងគេឯងដែរ តែមិនចេះថ្វាយបង្គំព្រះសង្ឃ ហើយដល់គេសូត្រធម៌ថ្វាយបង្គំព្រះទាំងអស់គ្នា សុខនៅស្ងៀម ។ អ្នកយល់ឃើញដូចម្ដេចចំពោះអំពើនេះ ?

**ឧទាហរណ៍បរិយាយ :**

ពិធីបុណ្យនិមួយៗ តែងមានទម្លាប់ពិសេសរបស់គេ មានរបៀបចាត់តាំងពីការស្លៀកពាក់ របៀបអង្គុយតាមកន្ទេល របៀបសំពះនឹងថ្វាយបង្គំ របៀបគុជដួប របៀបប្រគេនចង្ហាន់ របៀបរក្សាទឹកមុខជាដើម ។ ដូច្នេះហើយ បើយើងចូលទៅ

ក្នុងពិធីបុណ្យនិមួយៗ យើងមិនត្រូវបង្កក្តីកែវក្នុងបុណ្យនោះទេ យើងតោងមានពតិមានឲ្យច្បាស់ តើយើងត្រូវធ្វើដូចម្តេចឲ្យត្រូវនឹងរបៀបគេ ? ស្លៀកពាក់យ៉ាងណា ? ឈរត្រង់ណា ? សំពះបែបដូចម្តេច ? ។

យើងគង់ដឹងថា អ្នកជឿសាសនារមែងមានចិត្តប្រកាន់ជាទីបំផុត ព្រោះការគោរពចំពោះសាសនាក៏គោរពជាយខ្ពស់បំផុតដែរ ។ កាលបើយើងមានធ្វើអំពើឆ្គងការឆ្គងនោះក៏នឹងរឹតធំអាក្រក់ឥតគណនា ។

គួរយើងចាប់អារម្មណ៍ថា អ្នកស្រុកសាមញ្ញខ្មែរ តែងពោលរអ៊ូរទាំពីយុវជនទំនើបខ្លះដែលកាន់ឬកថាខ្លួនមិនមែនជាអ្នកសាសនា ។ ម្ល៉ោះហើយពេលគេសំពះព្រះសង្ឃ ខ្លួនមិនសំពះ ពេលគេស្មូត្រធម៌ ខ្លួនមិនស្មូត្រ ត្រឡប់ជានិយាយពាក្យជំទាស់នឹងសាសនាខ្លះផង ។

យុវជនណាប្រព្រឹត្តដូច្នេះ អាចចាត់ទុកជាអ្នកប្រព្រឹត្តខុសនឹងបទសុភាវធម៌ពេញទី ។ ច្បាប់សុភាវធម៌បង្គាប់កូនខ្មែរធម្មតា ឲ្យចេះយ៉ាងហោចណាស់ត្រឹមចេះសំពះព្រះសង្ឃនឹងស្មូត្រធម៌បានខ្លះ ហើយគោរពតាមទំនៀមទម្លាប់ខ្លះ ដែលខ្មែរយើងធ្លាប់និយមរាប់ពាន់ឆ្នាំមកហើយ ។

# មេរៀនទី ៥៦ - វត្តអារាម

**ផ្តើមការសន្ទនា** : ចូរអ្នករៀបរាប់ពីអំពើផ្តាំផ្តែងទាំងឡាយ ដែលគេតែងជួបប្រទះក្នុងវត្តអារាម (សំលៀកបំពាក់សំដី ភាពស្ងប់ស្ងៀម បុណ្យវត្ត ព្រះពុទ្ធរូប . . .)

— ខ្មែរយើងខ្លះ ឃើញជនជាតិចាមថ្វាយបង្គំបែរទៅទិសខាងលិច (ម៉េកាស) ក៏នាំគ្នាសើច ។ អ្នកយល់ថាមិនត្រូវសើច ពីព្រោះហេតុអ្វី?

## ឧទាហរណ៍បរិយាយ :

ក្នុងវត្តសាសនាដែល មានទីស្ថានខ្លះ មានវត្ថុខ្លះ មានរូបខ្លះជាទីគោរពដ៏ខ្ពង់ខ្ពស់ដល់សាសនា ។

— ព្រះពុទ្ធសាសនាគឺវត្តអារាម គឺគម្ពីរសៀវភៅ គឺព្រះពុទ្ធរូប ដើមពោធិព្រឹក្ស...

— គ្រិស្តសាសនាគឺព្រះវិហារ គឺរូបព្រះឆ្កាង គឺសម្ពន៍ជួន . . .

— សាសនាមហាម៉ាត់គឺវត្តមហាម៉ាត់ គឺទំនៀមទម្លាប់ចាមខ្លះ ដែលចាមគោរពមានពិធីថ្វាយបង្គំថ្ងៃ . . .

ច្បាប់សុជីវធម៌ ទោះបីយើងមិនជឿសាសនានោះក៏ដោយ ក៏ត្រូវតែយើងគោរពទីស្ថាន វត្ថុនិងរូបទាំងនោះ ចៀសវាងធ្វើអំពើដែលប្រឆាំងនឹងបទបញ្ញារបស់គេ ប្រៀបដូចជា សាសនាព្រះពុទ្ធហាមមិនឲ្យផឹកស្រា រួចយើងយកស្រាទៅផឹកក្នុងវត្ត សាសនាមហាម៉ាត់ឲ្យតមសាច់ជ្រូក យើងយកសាច់ជ្រូកទៅបរិភោគនៅកន្លែងគេ ។ ខ្ពស់ជាងនេះទៅទៀត យើងមិនត្រូវប្រើមធ្យោបាយណាទៅបន្ថោកតម្លៃទីស្ថាន វត្ថុ

ដែលគេបូជាឡើយ ។ ច្បាប់សុភាវធម៌បង្គាប់ហើយថា បើមិនគោរពក៏កុំបន្ទាក ដោយកាយវិការ ដោយវាចា ។

វត្តជាកន្លែងគោរព ជាកន្លែងដែលនាំឲ្យចិត្តស្ងប់ ។ ដូច្នេះ កុមារ កុមារីទៅវត្តអារាម ត្រូវមានសំលៀកបំពាក់ឲ្យស្អាតបាត ឲ្យមានចិត្តថ្លាដោយសារសម្លៀកបំពាក់នោះ តែឲ្យរាបសា កុំឲ្យឆើត កុំឲ្យស្រើបស្រាល កុំឲ្យហ៊ឺហាលេងខ្លួនទៅវិញ ។

សំដីសំដៅ កាយវិការ បរិយាកាសទូទៅក្នុងវត្ត ក៏ត្រូវរក្សា ដោយទឹកក្នុងចិត្តថា ទីនេះជាទីសមរម្យ ជាទីរម្ងាប់អារម្មណ៍ ជាទីគោរព មិនមែនជាទីសប្បាយអាឡេអាឡូវទេ ។

យើងរំឭកឡើងវិញថា យើងឥតត្រូវដេដែកពីជំនឿ ឬ ពីគុណសម្បត្តិរបស់សាសនាណាទេ តែគ្រូត្រូវទម្លាប់ក្មេងឲ្យមានភាពសមរម្យក្នុងពិធីបុណ្យសាសនា ក្នុងវត្តអារាម ក្នុងកន្លែងដែលអ្នកផងគោរពទៅតាមបទបញ្ញាររបស់សុភាវធម៌ប៉ុណ្ណោះ ។

---

## មេរៀនទី៤៧ – សំពះព្រះសង្ឃនិងគោរពវត្ត

ផ្ដើមការសន្ទនា : បង្ហាញរបៀបសំពះថ្វាយបង្គំព្រះពុទ្ធរូប ឬ ព្រះសង្ឃតាមបែបបទ ស្រីតាមរបៀបស្រី ប្រុសតាមរបៀបប្រុស ។

បង្ហាញរបៀបដាក់បាត្រលោកតាមបែបបទ ។

( សុំលោកគ្រូ – អ្នកគ្រូ កុំញញើត នឹង បង្ហាញរបៀបទាំងនោះដល់សិស្សឲ្យសិស្សធ្វើបានត្រឹមត្រូវម្ដងម្នាក់ៗ )

## ឧទាហរណ៍បរិយាយ :

ចំពោះកូនខ្មែរ ការថ្វាយបង្គំព្រះសង្ឃជាកិច្ចត្រូវប្រព្រឹត្ត ដូច្នេះយើងត្រូវប្រព្រឹត្តឡើងដោយសមរម្យតាមក្បួនខ្នាត ។ បើអង្គុយបត់ជើង ឬលុតជង្គង់ធ្វើដោយសណ្ដាប់ធ្នាប់ ដៃសំពះផ្គុំឡើងជារូបនិមិត្តផ្កាឈូកក្រពុំ ប្រណម្យសំពះលើកឡើងឲ្យសមរម្យ ឲ្យមានរបៀបរៀបរយ មិនហុចដៃទៅមុខប្រឆាំងពេក ឬតៀតជាប់នឹងខ្លួនពេក តែឲ្យល្មម ឲ្យមានទំនង ឲ្យសម្រួម ឲ្យជាសិល្បៈ ។



នារីខ្មែរយើងដែលស្លៀកពាក់តាមរបៀបសម័យ ត្រូវតែហាត់ឲ្យបានស្ទាត់នូវកាយវិការនេះ ព្រោះកម្រនឹងធ្វើឡើងឲ្យបានសមរម្យណាស់ ។

នារីខ្មែរយើងគួរស្គាល់ខ្លះនូវវិន័យដ៏តឹងរ៉ឹងបំផុតនៃព្រះសង្ឃចំពោះភេទស្រី ដូចជាវិន័យហាមមិនឲ្យព្រះសង្ឃគង់នៅបន្ទប់ស្ងាត់ជាមួយនឹងស្ត្រី មិនឲ្យប៉ះសាច់ស្ត្រីជាដើម ។

របៀបប្រគេន របៀបរាប់បាត របៀបដាក់បាតលោក ក៏ត្រូវនារីចេះយ៉ាងស្ទាត់ជាការចាំបាច់ ព្រោះអំពើនេះត្រូវមានការប្រព្រឹត្តឡើងស្ទើរតែរាល់ថ្ងៃ ។

## មេរៀនទី ៤៨ – ចំពោះចាស់ទុំអ្នកកាន់សីល

ផ្ដើមការសន្ទនា : ចៅជាចង់ទៅស្ទូចត្រី ទៅពឹងតាវាឲ្យគាត់ធ្វើដងសន្ទូចឲ្យ ។ តាញញឹម តែពុំព្រមធ្វើឲ្យចៅ ។ ហេតុអ្វីបានជាគាត់ពុំព្រមធ្វើ? ចៅជាធ្វើខុសនេះត្រង់ណា?

### ឧទាហរណ៍បរិយាយ :

ចាស់ៗខ្មែរយើងភាគច្រើន ទាំងប្រុសទាំងស្រីជាពុទ្ធបរិស័ទកាន់ខ្ជាប់នូវសីល មានសីលប្រាំ និងសីលប្រាំបីជាដើម ។ ជនជំពូកនេះមិនសម្លាប់សត្វ មិនកុហក មិនផឹកស្រា មិនឆបោកលួចរបស់អ្នកដទៃឡើយ ។

នៅក្នុងគ្រួសារជាមួយ កុមារកុមារី មិនលែងមានជីដូនជីតា ឪពុកម្ដាយ ជាអ្នកកាន់ខ្ជាប់នូវឧបោសថសីល ជាអ្នកជឿជាក់នូវបាបបុណ្យ ។ នៅចំពោះមុខជនប្រភេទនេះ កុមារត្រូវប្រុងប្រយ័ត្ននូវកាយវិការ នឹងសំដីខ្លះដែលអាចប៉ះប្រទាំងនឹងជំនឿរបស់គាត់ ។ កុមារជាបទសុភាវធម៌ មិនថ្លែងពីសេចក្ដីសប្បាយដោយបានស្ទូចត្រី បាញ់សត្វ ឬ សំខាន់ទៅទៀត មិនសម្លាប់សត្វ ឬ គ្រាន់តែធ្វើបាបសត្វដោយអំពើផ្សេង នៅមុខចាស់ៗនោះ ។ កំពុងតែស្ទូចត្រី បើឃើញព្រះសង្ឃ ឬ ចាស់ទុំអ្នកកាន់សីល មកជិត គួរដាក់ដងសន្ទូចចុះ លាក់ឲ្យបាត់បន្ទំធ្វើនេះ ធ្វើនោះសិនទៅ ។

## មេរៀនទី៥៩ – សង្ឃសព្ទ

**ការសង្កេតទូទៅ :** ក្នុងការសង្កេតទូទៅ កុមារ-កុមារីដែលចេញពីសាលាបឋមសិក្សាសាធារណៈយើង បើពុំបានទទួលការអប់រំដោយឡែកពីមាតាបិតាផងទេ ឃើញថា មានកាយវិការនឹងសំដីផ្គាំផ្គង ប្រាកដ កាលណាមានឱកាសត្រូវប្រស្រ័យនឹងព្រះសង្ឃម្ដងៗ ។ ម្ល៉ោះហើយច្រើនតែគាំងដៃគាំងសំដី ច្រើនតែឃ្លាតឆ្ងាយបន្តិចម្ដងៗពីព្រះសង្ឃនឹងវត្តអារាម ដែលជាប្រភពសំខាន់បំផុតក្នុងសង្គមខ្មែរយើង ។

បន្ទាប់ពីកាយវិការសមរម្យមក យើងសូមបង្ហាញភាសាខ្លះ ដែលត្រូវប្រើក្នុងការប្រស្រ័យទាក់ទងនឹងព្រះសង្ឃ :

១– សរីរាវយវ (កាយ) ឬ អង្គកាយ

| | | |
|---|---|---|
| ព្រះកេស | = | ក្បាល |
| ព្រះភក្ត្រ | = | មុខ |
| ព្រះនេត្រ | = | ភ្នែក |
| ព្រះនាសា | = | ច្រមុះ |
| ព្រះកាណ៌ | = | ត្រចៀក |
| ព្រះឱស្ឋ | = | មាត់ |
| ព្រះនលាដ | = | ថ្ងាស |
| ព្រះទន្ត | = | ធ្មេញ |
| ព្រះសុរង្គ | = | កណ្ឋ៍ |
| ព្រះហស្ត | = | ដៃ |
| ព្រះបាទ | = | ជើង |
| ព្រះឧរា | = | ទ្រូង |
| ព្រះឧរូ | = | ភ្លៅ |
| ព្រះជង្ឃៈ | = | ស្មង |
| ម្រាមព្រះហស្ត | = | ម្រាមដៃ |
| ម្រាមព្រះបាទ | = | ម្រាមជើង |
| ព្រះអដ្ឋិ | = | ឆ្អឹង |

## ២– ឈ្មោះវត្ថុប្រើប្រាស់ ៖

| | |
|---|---|
| ត្រៃចីវរ | សំពត់ស្បៀកដណ្តប់មួយសម្រាប់ |
| បរិក្ខារ | គ្រឿងប្រើប្រាស់ពយរង |
| ស្បង់ | សំពត់ស្បៀក |
| ចីពរ | សំពត់មួយផ្ទាំងធំសម្រាប់ដណ្តប់ ឃុំ - គ្រង |
| សង្ឃាដី | សំពត់មួយផ្ទាំងធំសម្រាប់ដណ្តប់ ដាក់លើចីពរ |
| អង្សក | សំពត់ទ្រនាប់ញើស |
| វត្ថពន្ធចង្កេះ ឬ រ៉ាត់ប្រខ្គត | ខ្សែក្រវាត់ |
| និសីទនៈ | សំពត់ក្រាលអង្គុយ |
| វត្ថទ្រូង | សំពត់បំណង់ទ្រូង |
| ធម្មការក: | ដម្រង់ទឹក |
| ភាជនៈ | ពានទ្រ ចាន ថាស ជាដើម |
| សាដក | សំពត់ងូតទឹក |
| ថង់យាម | ប្រដាប់បរិក្ខារ |
| ប្រូត | ឈើប្រូត |
| ឈើស្ទន់ | ឈើចាក់ធ្មេញ |
| ទ្រនាប់ព្រះបាទ | ស្បែកជើង |
| ធាត | ប្រដាប់ដាក់ចង្ហាន់ (បាយ) |

## ៣ - សេនាសនបច្ច័យ (ទីលំនៅ និងគ្រឿងប្រើប្រាស់)

| | |
|---|---|
| កុដិ | ផ្ទះព្រះសង្ឃ |
| សាលា | សាលាបុណ្យ |
| ព្រះវិហារ ឬ រោងឧបោសថ | ទីកន្លែងធ្វើសង្ឃកម្ម ឬ ធ្វើបុណ្យធំៗ |
| ចេតិយ | កន្លែងសម្រាប់បញ្ចុះធាតុ |
| តូប | ផ្ទះតូចៗ របស់ព្រះសង្ឃ |
| ហោត | វត្តដែលមិនទាន់មានព្រះវិហារ គេធ្វើហោតជំនួស |
| ធម្មមន្ទីរ ឬ ហោត្រៃ | កុដិដែលដម្កល់ទុកក្បួនច្បាប់ធម៌ |
| គ្រែសំណឹង | គ្រែលោកសឹង |
| វត្ត ឬ អារាម - អាវាស | ទីកន្លែងដែលមានព្រំសីមា ព្រំដែន |
| ប្រាង្គណ៍ | មានសណ្ឋានដូចចេតិយ |
| សីមា | គោល |
| អាសនៈ | ទីដែលព្រះសង្ឃគង់ អង្គុយ |
| កន្លែងសមាធិ | ទីព្រះសង្ឃធ្វើសមាធិ |
| ទីរហោឋាន | ទីស្ងាត់ |
| បូជនិយដ្ឋាន | កន្លែងសំរាប់បូជាសក្ការៈ |

### ៤ – ឈ្មោះវត្ថុបរិភោគ

| | |
|---|---|
| ចង្ហាន់ | បាយ ឬ បង្អែមនំចំណាប |
| បណីតាហារ | គ្រឿងបរិភោគ ខ្ពង់ខ្ពស់ ឬ ឆ្ងាញ់ពិសា |
| យាគូ | បបរ |

### ៥ – ឈ្មោះថ្នាំកែរោគ

| | |
|---|---|
| ភេសជ្ជៈ | តែស្ករ កាហ្វេ ។ល។ |
| គិលានភេសជ្ជៈ | ថ្នាំកែរោគផ្សេង ៗ |
| អដ្ឋបាន | ភេសជ្ជៈម្យ៉ាងដែលធ្វើពីវត្ថុ ៨ មុខ |
| ខីរៈ | ទឹកដោះស្រស់ |

### ៦ – ឈ្មោះបច្ច័យទាំង ៤ :

| | |
|---|---|
| ចីវរបច្ច័យ | ត្រៃចីវរ និង បរិក្ខារ |
| បិណ្ឌបាតប្បច្ច័យ | គ្រឿងឆាន់ទាំងអស់ |
| សេនាសនប្បច្ច័យ | ទីកន្លែងនៅទាំងអស់ |
| គិលានភេសជ្ជប្បច្ច័យ | ថ្នាំកែរោគទាំងអស់ |

### ៧ – ឈ្មោះគម្ពីរច្បាប់សិក្សា (គម្ពីរ)

| | |
|---|---|
| ព្រះត្រៃបិដក | ឈ្មោះគម្ពីរធំរបស់ព្រះសង្ឃ |
| ព្រះសូត្រ | គម្ពីរច្បាប់បង្ហាញរឿងរ៉ាវផ្សេង ៗ |
| ព្រះវិន័យ | ច្បាប់ទូន្មាន ( សុភាវធម៌ ) |
| ព្រះអភិធម្ម ។ល។ | ច្បាប់ធម៌យ៉ាងល្អិតល្អន់ ខ្ពង់ខ្ពស់របស់ព្រះសង្ឃ |

## ៨ – ឈ្មោះបុណ្យ (ដែលឧបាសកតែងធ្វើញឹកញាប់)

| | |
|---|---|
| បុណ្យសង្ឃទាន | ឲ្យទានសង្ឃ |
| បុណ្យទក្ខិណានុប្បទាន | បុណ្យដែលឧទ្ទិសដល់បុព្វការីជន |
| បុណ្យនាគមហាបង្សុកូល | និមន្តលោកឆាក |
| បុណ្យភ្ជុំបិណ្ឌ | បុណ្យចាប់ពីថ្ងៃ ១ រោចខែភទ្របទដល់ ១៥ រោចភ្ជុំ |
| បុណ្យចូលវស្សា - ចេញវស្សា | បុណ្យថ្ងៃ ១ រោចខែអាសាឍ ចេញថ្ងៃ ១៥ ខែអស្សុជ |
| បុណ្យកតញ្ញូ - កតវេទី | ជូនវត្ថុដល់អ្នកមានគុណ |
| បុណ្យកឋិន | បុណ្យកឋិន |
| បុណ្យផ្កា | បុណ្យយកប្រាក់សង់សាលា - កុដិ - ព្រះវិហារ ។ល។ |
| បុណ្យចំរើនព្រះជន្ម | ចំរើនអាយុ |
| បុណ្យអុំទូក សំពះព្រះខែ | បុណ្យទំនៀមទម្លាប់មានរាល់ឆ្នាំ |
| បុណ្យវេរបច្ច័យ ៤ | ឲ្យទានទូវបច្ច័យ ៤ ដល់ព្រះសង្ឃ |
| បុណ្យដាក់បាត | ដាក់បិណ្ឌប្រគេនលោក |
| បុណ្យបំបួសនាគ | ឲ្យបួលកាន់ផ្នួសជាសាមណេរ ឬភិក្ខុ |
| បុណ្យសព | ព្រះសង្ឃសុគត គេបូជា |
| បុណ្យសម្ពោធ | បុណ្យធ្វើសាលា - កុដិ - វិហារ ជាដើម ។ |
| បុណ្យចូលឆ្នាំ ។ល។ | បុណ្យខែចេត្រ ចែកឆ្នាំចាស់ |
| បុណ្យមាឃបូជា | បុណ្យរំលឹកថ្ងៃព្រះពុទ្ធដាក់អាយុសង្ខារ |
| បុណ្យវិសាខបូជា | បុណ្យរំលឹកថ្ងៃព្រះពុទ្ធ ព្រះសូត្រ ទឹង និព្វាន |
| បុណ្យពុទ្ធាភិសេក | បុណ្យអភិសេក ព្រះពុទ្ធបដិមាករ |

## ៩ – កិរិយាសង្ឃស័ព្ទ:

| | |
|---|---|
| លោកសឹង | ដេក |
| លោកតើន | ក្រោកពីដំណេក |
| លោកស្រង់ទឹក | ងូត ឬមុជ |
| លោកអាពាធ | ជម្ងឺ - ឈឺ |
| លោកខ្វាល់ | ខឹង |
| លោកនិមន្ត | ដើរ |
| លោកទ្រង់ឈរ | ឈរ |
| លោកគង់ | អង្គុយ |
| លោកនិទានធម៌ | និយាយធម៌ |
| លោកសំដែងធម៌ | ទេសនា |
| លោកសូត្រមន្ត | សូត្រធម៌ |
| លោកបិណ្ឌបាត | សុំចង្ហាន់ |
| ឆាន់ចង្ហាន់ដែលគេប្រគេន | បរិភោគអាហារ |
| លោកគ្រង់ចីពរ - ស្បៀកស្បង់ | យកចីពរព័ទ្ធឈៀងស្មា |
| លោកមានព្រះពុទ្ធដីកា | និយាយ |
| លោកទេសន៍ | សំដែងធម៌ |
| លោកចំរើនបរិត្ត | សូត្រធម៌ |
| លោកស្វាធ្យាយន៍ | រៀន - សូត្រ - ទន្ទេញ |

| | |
|---|---|
| លោកបង្រៀនភាវនា | ដើរ ទិនទឹកធម៌ ពោមកៗ |
| លោកដោះទុក្ខសត្វ - ធំ - តូច | ផុះ នោម បន្ទោបង់ឧច្ចារៈ |
| លោកស្រពព្រះភ័ក្ត្រ | លប់មុខ |

## ១០– ពាក្យជាប់ជាន់ (សម្រាប់បុគ្គលក្នុងសាសនា)

| | |
|---|---|
| ព្រះពុទ្ធ | អ្នកប្រាជ្ញយ៉ាងឆ្នើមខាងពុទ្ធសាសនា (ព្រះមុនីនាថ) |
| ព្រះធម៌ | ធម៌ដែលព្រះពុទ្ធទ្រង់សំដែងហើយ |
| ព្រះសង្ឃ ។ល។ | សិស្សផ្ទាល់របស់ព្រះពុទ្ធ លោកកាន់ធម៌ - វិន័យ |
| សម្ដេចសង្ឃ | ស្ដេចសង្ឃ |
| លោកគ្រូចៅអធិការ | មេវត្ត |
| លោកគ្រូសង្ក្រាជ | មេវត្ត |
| លោកបរិស័ទ | លោកភិក្ខុ |
| លោកភិក្ខុ | លោកភិក្ខុ |
| លោកគ្រូអាចារ្យ | លោកគ្រូបង្រៀនខាងធម៌វិន័យ |
| លោកសាមណេរ ឬលោកនេន | លោកនេនកាន់សីល ១០ |
| លោកគ្រូមេគណ | មន្ត្រីសង្ឃធំបង្អស់នៅខេត្តនិមួយៗ |
| លោកគ្រូអនុគណ | មន្ត្រីសង្ឃធំបង្អស់ នៅក្នុងស្រុកនីមួយៗ |

## ១១- ផ្នែកគ្រហស្ថ

| | |
|---|---|
| ឧបាសក | ឧបាសក បុរសដែលកាន់សីល ៥-៨ |
| ឧបាសិកា | ឧបាសិកា ស្ត្រី -ដ- |
| ទាយក | បុរសដែលជ្រះថ្លាសាសនាព្រះពុទ្ធ |
| ទាយិកា | ស្ត្រី -ដ- |
| គ្រហស្ថ | ឧបាសក និង ឧបាសិកា |
| សិស្សលោក | ក្មេងដែលនៅជាមួយព្រះសង្ឃ |
| លោកអាចារ្យវត្ត | អ្នកចាត់ចែងការនៅក្នុងវត្ត |
| ប្រធានវត្ត | អ្នកទទួលទ្បូការខុសត្រូវវត្ត |
| សមាជិក | ក្រុមអ្នកទទួលការខុសត្រូវវត្ត |
| គណកម្មការវត្ត | -ដ- |
| ញោម | ឪពុក-ម្ដាយ ឬ ញាតិជិតខាងទូទៅ |
| ញោមវត្ត - ញាតិញោម | អ្នកទំនុកបំរុងវត្ត |
| ញោមឧបដ្ឋាក | -ដ |
| ជីតុន | ព្រះសង្ឃដែលធ្លាប់តែទៅទូន្មានធម៌នៅឯត្រកូលណាមួយ |
| ដូនជី | យាយចាស់ដែលកាន់សីលនៅវត្ត |
| អន្តេវាសិក: | កូនសិស្សសិក្សាធម៌វិន័យ |
| ករុណា | ពាក្យឆ្លើយរបស់ព្រះសង្ឃ និង ព្រះសង្ឃដូចគ្នា ឬ ឧបាសក-សិកា ឆ្លើយតបនឹងព្រះសង្ឃថា ករុណាៗ |

| | |
|---|---|
| ខ្ញុំព្រះករុណា | ពាក្យដែលឧបាសកនិយាយជាមួយព្រះសង្ឃ |
| ខ្ញុំព្រះករុណាម្ចាស់ | — ជ — |
| លោកគ្រូម្ចាស់-ព្រះតេជគុណ | ពាក្យឧបាសកហៅព្រះសង្ឃ |
| អាត្មា - អាត្មាភាព | ពាក្យព្រះសង្ឃហៅខ្លួនឯង និយាយជាមួយឧបាសក-ឧបាសិកា |
| ឆាន់ - ក្ដី | លោកគ្រូចៅអធិការហៅខ្លួនលោកថា ឆាន់ - ក្ដី |
| ករុណា | ពាក្យឆ្លើយរបស់ឧបាសកឆ្លើយទឹងព្រះសង្ឃ (បាទ) |
| ចំរើនពរ | ពាក្យឆ្លើយរបស់ព្រះសង្ឃទៅកាន់ឧបាសកថា (ចំរើនពរញោម) |

## ១១- ឃ្លាខ្លះ (ដែលត្រូវប្រើជាញឹកញាប់)

- ឪពុកខ្ញុំទៅនិមន្តព្រះសង្ឃ ។
- ឪពុកខ្ញុំទូលលោកថា: "សូមនិមន្តព្រះគុណម្ចាស់ទៅសំដែងធម៌ទេសនា" ។
- ព្រះសង្ឃទទួលនិមន្ត ។
- លោកសំដែងធម៌ ។
- លោកចំរើនពរលា ឧបាសក - ឧបាសិកា ។
- លោកសឹងនៅលើសំណឹង ។
- លោកឆាន់ភេសជ្ជៈ ។

– លោកមានពុទ្ធដីកាថា: "អាត្មាភាពទៅបិណ្ឌបាត" ។

– ម្តាយខ្ញុំថ្វាយបង្គំលោក ។

- ម្តាយខ្ញុំប្រគេនចង្ហាន់លោក ។

– ឪពុកខ្ញុំបវារណាលោក ។

– ខ្ញុំសំពះលោក ។

– ខ្ញុំយកទឹកមកលាងព្រះបាទលោក ។

– ខ្ញុំជាកូនសិស្សលោកវត្ត . . . ។

កាលពីល្ងាចថ្ងៃសៅរ៍មុននេះ ឪពុកខ្ញុំបានអញ្ជើញទៅកាន់វត្តឧណ្ណាលោម ដើម្បីនិមន្តសម្តេចសង្ឃ សំដែងធម៌ទេសនា ។ លុះបានទៅដល់វត្តកាលណា ក៏ចូលទៅក្រាបថ្វាយបង្គំសម្តេច ដោយគារវភក្តិភាព ។

សម្តេចមានព្រះពុទ្ធដីកា សួរថា :

ស - ញោមមានការអ្វី ?

ឪ – ខ្ញុំព្រះករុណា មានការមកសូមនិមន្តសម្តេចទៅសំដែងធម៌ទេសនា ពានព្រះអង្គ!

ស – ចុះញោមធ្វើបុណ្យអ្វីទៅ ?

ឪ - ខ្ញុំព្រះករុណា ធ្វើបុណ្យសង្ឃទាន ពានព្រះអង្គ!

ស – បុណ្យនោះ ធ្វើក្នុងថ្ងៃណា ?

ឪ – បុណ្យនោះ ធ្វើក្នុងថ្ងៃអាទិត្យ ទានព្រោស!

ស – ផ្ទះញោមនៅដល់ណាទៅ ?

ឪ – ទានព្រោស! ផ្ទះខ្ញុំព្រះករុណា នៅតំបន់ទួលគោក ទាន!

សម្តេចក៏មានពុទ្ធដីកាទទួលនិមន្តថា :

"ចំរើនពរ អាត្មាទទួលនិមន្តបាន" ។

លុះសម្តេចទទួលនិមន្តហើយ ឪពុកខ្ញុំក៏ក្រាបថ្វាយបង្គំលាសម្តេច ត្រឡប់ទៅកាន់ផ្ទះវិញដោយក្តីរីករាយ ។



# ជំពូកទី ៨

# សុភាវធម៌ចំពោះជនបរទេស

# មេរៀនទី៦០– ជនបរទេសដែលនៅរួម សុខទុក្ខជាមួយនឹងយើងរហូត

ផ្ដើមការសិក្សា : ក្មេងពាលម្នាក់ឈ្មោះប្រុកែកនឹងអ្នកលក់ជាតិចិន ជេរដល់សញ្ជាតិគេដាច់សាច់ដោយពោលថា "អាចិន" ។ អ្នកយល់ឃើញដូចម្ដេច ចំពោះអាកប្បកិរិយានេះ?

## ឧទាហរណ៍បរិយាយ :

*បរទេសដែលឃើញនៅប្រទេសយើងចែកជាពីរសណ្ឋាន ៖*

*ក– បរទេសដែលមករួមរស់ក្នុងប្រទេសយើងតែម្ដងដូចជា ៖ ចិន - ជនវៀតណាម - កុល្លា - បារាំង ។ល។*

*ខ– បរទេសដែលមកមួយដង មួយយាម ។*

*ចំពោះបរទេសប្រភេទទីមួយ ច្បាប់ប្រទេសរបស់យើងមានចែងស្រាប់ហើយ ។ បទសុភាសិតធម៌ណា នាំយើង មិនឲ្យប្រកាន់ជាតិខ្មែរជ្រុលពេករំភានដោយចិត្តចង្អៀត មិនឲ្យជនបរទេសទាំងនោះរស់បានស្រួលក្នុងប្រទេសយើង ដោយប្រើអាកប្បកិរិយាមិនសមរម្យ ឬសំដីសំដៅទ្រគោះបោះបោក ។ ទំនៀមទំលាប់គេខ្លះ ផ្ទុយពីរបស់យើងពិត (ភាសា របៀបរកស៊ី សាសនា បុណ្យទាន) គួរយើងគោរពទំនៀមទំលាប់គេ កុំបង្អាប់បំផ្លាញដោយបទផ្សេងៗ ។ បើទំនៀមទំលាប់គេនោះ គ្មានអ្វីប៉ះពាល់ដល់កិត្តិយសស្រុកយើងទេ ។*

ត្រូវយើងដឹងថា ជនជាតិខ្មែរយើងក៏មានរស់នៅបរទេសដែរ មាននៅជាយូរអង្វែងហើយនៅប្រទេសថៃ-វៀតណាម-លាវ ហើយឥឡូវនេះទៀតមាននៅស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក ជានិស្សិត ឬ ជាភ្នាក់ងារអគ្គទូត ។ ខ្មែរយើងចង់បានទទួលការគួរសមពីគេ ដូចគេចង់ទទួលការគួរសមពីយើងដែរ ។

យើងត្រូវបញ្ជាក់ថា ច្បាប់សុភាពធម៌មិនមែនបង្រួញចិត្តយើងរហូតដល់ទៅឲ្យបរទេសលួចគំនិតបាននោះទេ ។

| មេរៀនទី ៦១ - ជនបរទេសដែលមក<br>មួយដង មួយយាម |
|---|

ផ្តើមការសន្ទនា : អ្នកឃើញក្មេងមួយក្រុម ចោមរោមជនបរទេសនិយាយគ្នាសើចលេងពីរូបរាង ពីភាសាបរទេសនោះ ។ គួរធ្វើដូចនេះឬមិនគួរ?

ឧទាហរណ៍បរិយាយ :

ចំពោះជនបរទេសជាទេសចរ សុភាពធម៌បង្គាប់យើងឲ្យជួយយកអាសា ជួយសម្រួលជីវភាពដែលនៅស្រុកយើង ឲ្យប្រកបដោយសេចក្ដីសុខសប្បាយ ។

តាមធម្មតាជនបរទេស ត្រូវការពត៌មាន ( សួរផ្លូវ - សួររកប្រៃសណីយ៍ សួរទស្សនីយភាព សួររកកន្លែងបុរាណវត្ថុ សួរទំនៀមទម្លាប់ . . . ) យើងត្រូវឲ្យពត៌មាននោះដោយរាក់ទាក់ ។

បើជនបរទេសនិយាយភាសាយើងមិនបានត្រឹមត្រូវ ដោយពោលមិនច្បាស់ ឬប្រើពាក្យខុស គួរយើងកុំសើចកុំមើលងាយ ឬសំខាន់ទៅទៀត កុំធ្វើត្រាប់តាម ។ សាច់ឈាម ពណ៌សម្បុរ រូបរាង (មាទធំ - ច្រមុះគោង លក់ក្រហម) មិនត្រូវយើងបញ្ចេញអាការៈក្រៅឲ្យឃើញថា មានអ្វីខុសពីធម្មតាឡើយ ។

បើឱកាសហុចឲ្យ យើងអាចណែនាំបង្ហាញប្រទេសយើង តើមានសភាពល្អនិងលក្ខណៈពិសេសយ៉ាងណាខ្លះ? ។ ចៀសវាងកុំឲ្យបរទេសទាំងនោះ ធ្លាក់ទៅជួបនឹងមនុស្សពួកឆបោក ឬ ឆក់ - លួច - ប្លន់ ។

ចំពោះបរទេស ជាភ្នាក់ងារអគ្គទូតប្រចាំនៅប្រទេសយើង ៗ ត្រូវតែមានការគួរសមជាងនេះទៅទៀត ។ គេអាចសំគាល់បានដោយរថយន្តមានស្លាកពណ៌លឿងលេខស ។

ជំពូកទី ៩

របៀបសរសេរនិងផ្ញើសំបុត្រ

# មេរៀនទី ៦២ - សំបុត្រ

ផ្ដើមការសន្ទនា : អ្នកដែលបានសរសេរសំបុត្រផ្ញើទៅមិត្តភក្ដិឯណាដែរឬទេ ? អ្នកបានផ្ញើដូចម្ដេចខ្លះ ?

## ឧទាហរណ៍បរិយាយ :

យើងមិនអធិប្បាយពីអត្ថបទសំបុត្រនោះទេ និយាយតែត្រង់បន្ទាប់ពីបានអត្ថបទហើយ ដាក់ក្រដាសទៅក្នុងស្រោម ការខ្ទង់សំបុត្រ បិទតែមប្រ៍ប៉ុណ្ណោះ ៗ ខ្មែរយើងមិននិយមសរសេរសំបុត្រឆ្លើយឆ្លងគ្នាជាញឹកញាប់ទេ ច្រើនតែវាហាៗទៅ ត្រូវការផ្ញើសំបុត្រម្ដងៗ ដោយមានការខានពុំបាន ក៏ខ្វះក្រដាសត្រឹមត្រូវ ខ្វះស្រោមសំបុត្រ ខ្វះតែមប្រ៍ ដោយកន្លែងលក់តែមប្រ៍ កោតទៀតក៏នៅឆ្ងាយពីផ្ទះ ៗ

ដូច្នេះ សំបុត្រដែលផ្ញើនោះ ផ្ញើដោយខ្ជីខ្ជា កម្រមានជនណាធ្វើតាមក្បួនខ្នាតឡើយ ៗ គ្រួសារខ្មែរសម័យ គួរមានទិញក្រដាស ស្រោម តែមប្រ៍ទុក ក្រែងមានរវល់ត្រូវផ្ញើសំបុត្រ ៗ មានហើយ គួរទម្លាប់ខ្លួន ទម្លាប់កូនចៅឲ្យមានការសរសេរឆ្លើយឆ្លងទីងមិត្តសំឡាញ់ ទីងគ្រួសារដែលនៅឆ្ងាយឲ្យបានញឹកញាប់បន្តិច ៗ

អង្គការអន្តរជាតិខ្លះ ក្នុងគំនិតចង់ឲ្យយុវជនក្នុងលោកទាំងមូលចេះទាក់ទងគ្នា រាប់អានគ្នា ដើម្បីឲ្យមានការយោគយល់គ្នារវាងជាតិនិងជាតិ បានតាំងស្នើសុំទៅអង្គការប្រៃសណីយ៍សកល កុំឲ្យមានការបិទតែមប្រ៍លើសំបុត្រផង ៗ

គ្រូសារសម័យខ្លះ គេនិយមឲ្យកូនចៅមានមិត្តនៅបរទេស ។ សិស្សខ្មែរយើង ដែលចេះភាសាបារាំងបានបន្តិចបន្តួចដែរ អាចឆ្លើយឆ្លងបានទាំងសិស្សជាតិបារាំង ស៊ុយស បិល្ស កាណាដាខ្លះបាន ។

ដើម្បីដោះស្រាយបញ្ហាភាសា យុវជនច្រើនប្រទេសនាំគ្នារៀនទាំងប្រើភាសាតែមួយ សម្រាប់លោកទាំងមូល ។ ភាសានេះដែលគេបានបង្កើតជាង ៦០ ឆ្នាំមកហើយ មានឈ្មោះថា "អិស្ពេរ៉ង់តូ" (espéranto) ។

ប្រយោជន៍នៃការឆ្លើយឆ្លងសំបុត្រគ្នាបែបនេះ មានវែងឆ្ងាយណាស់: រៀនភាសា រៀនប្រវត្តិសាស្ត្រ ភូមិសាស្ត្រ សន្សំទុកតែមប្រ៉ៃចំឡែកៗ រូបភាពប៉ុកៗ ។ល។

| មេរៀនទី ៦៣ |
|---|
| សុភាវធម៌ក្នុងរបៀបផ្ញើសំបុត្រ |

ផ្ដើមការសន្ទនា : អ្នកបានទទួលសំបុត្រមួយ ឃើញស្រោមកខ្វក់ ឈ្មោះអ្នក គេសរសេរមិនត្រូវ តែមប្រៃបិទមិនគ្រប់តម្លៃ ភ្នាក់ការប្រៃសណីយ៍បានពិន័យលើអ្នក ។ តើអ្នកមានអន់ចិត្តឬទេ?

ឧទាហរណ៍បរិយាយ :

ក្រដាសសរសេរ : បើសំបុត្រផ្ញើដើរតាមអាកាសយាន គេប្រើក្រដាសស្តើង ដើម្បីចៀសវាងចំណាយច្រើនទៅលើថ្លៃតែមប្រៃ ។ កុំបត់ក្រដាសជាច្រើន

ផ្ដេក មុននឹងដាក់ទៅក្នុងស្រោម ។ ឥឡូវគេច្រើននិយមឲ្យមានផ្នត់ក្រដាស លើសាច់អត្ថបទតែមួយ ឬ ពីរ តាមបណ្ដោយក្រដាស ។ នេះជាបទសុភាវធម៌ចំពោះអ្នកទទួលសំបុត្រ ។

ស្រោម : គេច្រើននិយមប្រើស្រោមវែងជាងមុន ដើម្បីជៀសវាងការបត់ក្រដាសខាងក្នុងជាច្រើនផ្នត់ ។ បើសំបុត្រផ្ញើដំណើរតាមអាកាសយាន គេច្រើនប្រើស្រោមស្ដើង ។ ស្រោមដែលមានលក្ខណៈត្រឹមត្រូវមានទំហំ ១១០ ម.ម × ១៤៥ ម.ម ស្រោមយ៉ាងតូចបំផុតមានទំហំ ៧០ ម.ម × ១០០ ម.ម ។

ជាបទសុភាវធម៌ចំពោះអ្នកទទួលសំបុត្រ គួរយើងបិទតែមប្រៃសណីយ៍ឲ្យគ្រប់គ្រាន់តាមកំរិតប្រៃសណីយ៍ ជៀសវាងកុំឲ្យមានការពិន័យនាំវិនាសដល់អ្នកទទួល ។

សរសេរឈ្មោះក្នុងអាសយដ្ឋានទៀត ក៏ត្រូវសរសេរឲ្យត្រូវមែនទែន ។ អ្នកទទួលមិនសប្បាយចិត្តទេ ដោយឃើញការសរសេរខ្វះខ្វា ឬ ខុស ឬ ប្រហាក់ប្រហែល ។ គេអាចមិនព្រមទទួលសំបុត្រនោះក៏សឹងបាន ។

- បិទតែមប្រៃសណីយ៍ឲ្យត្រូវកន្លែង គឺជ្រុងខាងលើហើយខាងស្ដាំខ្នងស្រោម ជាបទសុភាវធម៌ចំពោះភ្នាក់ងារប្រៃសណីយ៍ ដែលឥឡូវគេប្រើម៉ាស៊ីនសម្រាប់ផ្ញើតែមប្រៃសណីយ៍ឲ្យទៅជាមោឃៈ ។

សំបុត្រដែលបិទតែមប្រ៍ខុសកន្លែង គេដកស្រង់ចេញ ដើម្បីប្រថាប់ត្រាដោយដៃផ្ទាល់នាំឲ្យយូរការ ។ ជាបទសុភាវធម៌ចំពោះភ្នាក់ងារប្រៃសណីយ៍ទៀត បើកាលណាត្រូវការប្រើតែមប្រ៍ច្រើន ពីរ ឬ បី បួន គួរកុំបិទតែមប្រ៍នោះតែពាសច្រើនកន្លែង នាំឲ្យខាតពេលប្រថាប់ត្រា ។

- សំបុត្រដែលផ្ញើទៅបរទេស គួរមានការផ្ចិតផ្ចង់ជាងនេះទៅទៀត ។ របៀបធ្វើសំបុត្រ អាចឆ្លុះឲ្យឃើញដល់វឌ្ឍនភាពនៃខ្មែរយើងបាន ។ គេនិយមសន្សំតែមប្រ៍ប្លែកៗទុក ។ តែមប្រ៍មានតម្លៃទាល់តែបិទដោយផ្ចិតផ្ចង់មិនរហែក នៅមាន "ធ្មេញ" គ្រប់ ។ តែមប្រ៍ដែលភ្នាក់ងារប្រៃសណីយ៍ធ្វើឲ្យមោឃៈ ដោយប្រើម៉ាស៊ីនមិនសូវមានតម្លៃ បើចង់ឲ្យមានតម្លៃ អ្នកផ្ញើអាចទៅជួបភ្នាក់ងារនោះបោះត្រាយ៉ាងពិសេសដោយដៃលើតែមប្រ៍សំបុត្រ ។ នេះជាភារៈផ្ទាល់នៃក្រុមប្រៃសណីយ៍ដែលគេបំពេញដោយរីករាយ ។ តែមប្រ៍នៃប្រៃសណីយ៍ខ្មែរយើង បរទេសគេរាប់អានណាស់ គេចង់បានទុកណាស់ ។

## មេរៀនទី ២៤

### គួរធ្វើតាមគំរូខាងក្រោមនេះ ក្នុងរបៀប<br>ការខ្ចង់សំបុត្រ :

ផ្តើមការសន្ទនា : ឲ្យសិស្សយកក្រដាស កន្ត្រៃ ការ រៀនធ្វើស្រោមសំបុត្រឲ្យបានត្រឹមត្រូវ បង្ហាញរបៀបបត់ក្រដាសដាក់ក្នុងស្រោម តាខ្នងសំបុត្រ បិទតែមប្រ៍ឲ្យត្រូវកន្លែង គ្រប់ៗគ្នា ។

# សំបុត្រដែលផ្ញើក្នុងប្រទេស






## សំបុត្រដែលផ្ញើទៅបរទេស






– ទំនៀមទម្លាប់បរទេស ដែលឃើញអនុវត្តខ្លះហើយក្នុងសង្គមខ្មែរយើង

– ជំនឿប្លែកៗខ្លះនៃបរទេស ដែលយើងគួរដឹង

ខាងក្រោមនេះយើងសុំបង្ហាញតែអ្វីខ្លះ ដែលធ្លាប់សង្កេតឃើញជាញឹកញាប់ ហើយដែលនៅមានទ្គាំទ្គង ៗ យើងយល់ឃើញថា បើបានជាទទួលស្គាល់អារ្យធម៌បរទេសហើយ គួរប្រព្រឹត្តិឲ្យបានតាមបែបបទរបស់គេផង សំខាន់ក្នុងការប្រស្រ័យនឹងជនបរទេស ៗ

អ្វីណាដែលយើងយល់ឃើញថា ហួសពីការវិវត្តន៍នៃសង្គមខ្មែរយើងពេក យើងមិនយកមកនិយាយនៅពេលនេះទេ :

<u>មាសពេជ្រ :</u>

– ស្រីមិនពាក់មាស ឬ ពេជ្រពេលព្រឹកទេ ៗ ខ្សែកពេជ្រ ឬ គជ់ គេពាក់តែពេលយប់ ៗ

– នៅឱកាសទទួលភ្ញៀវ ស្ត្រីម្ចាស់ផ្ទះមិនពាក់មាសពេជ្រឡើយ ទុកឲ្យភ្ញៀវគេបញ្ចេញរបស់គេចុះ ៗ

<u>អំណោយ :</u>

– មុននឹងផ្ញើអំណោយ ត្រូវនឹកទៅដល់រសអ្នកដែលបំរុងទទួល ៗ

– បើមានបិទស្លាកតម្លៃ លើរបស់អំណោយនោះ ត្រូវយកចេញភ្លាម ៗ

– ចំពោះអ្នកទទួល តម្លៃរបស់មិនមែននៅលើតម្លៃជាប្រាក់កាសទេ គឺនៅលើកាយវិការយើងនេះឯង ៗ

**កម្រៃដល់អ្នកបំរើ :**

- ក្នុងភោជនីយដ្ឋាន រោងទស្សនីយភាព សណ្ឋាគារ នៅប្រទេសច្រើនក្នុងពិភពលោក ត្រូវឲ្យកម្រៃទៅអ្នកបំរើដោយខានពុំបាន គឺគិត ១០ ភាគរយ លើតម្លៃវត្ថុយ៉ាងតិច ។

**ការបង្ហាញរូបបង្ហាញឈ្មោះ: (présentation)**

- គេបង្ហាញរូបនឹងឈ្មោះអ្នកតូចទៅអ្នកធំ ក្មេងទៅចាស់ ពោលឈ្មោះអ្នកទី ១ មុន បន្ទាប់ទើបឈ្មោះអ្នកទី ២ ។
- គេបង្ហាញរូបប្រុសទៅស្ត្រី ។ ស្ត្រីដែលកំពុងអង្គុយមិនបាច់ក្រោកឈរទេ ។

**តាមដងផ្លូវនៅទីក្រុង :**

- បុរសបើមានស្ត្រីដើរជាមួយ ត្រូវដើរមកជិតថ្នល់ ទុកឲ្យស្ត្រីដើរជិតនៅផ្លូវផ្ទះ (ការពារស្ត្រីចំពោះគ្រោះថ្នាក់ផ្សេងៗ) ។

**នៅទ្វារផ្ទះ ឬ ការិយាល័យ :**

- អញ្ជើញភ្ញៀវចូលមុនដោយសំដី (សុំអញ្ជើញចូល ) នឹងកាយវិការ (លើកដៃស្តាំក្រោយខ្លួនគេបន្តិច) លើកលែងតែកន្លែងខ្លះ ដែលយើងត្រូវបង្ហាញផ្លូវគេ ។ ពេលនោះយើងដើរពីមុខគេ បន្ទាប់ពីបានសុំទោសគេជាមុន (សុំទោស! ខ្ញុំដើរមុខលោក ព្រោះផ្លូវចូលវាខ្វាត់ខ្វែងបន្តិច) ។

**កន្លែងបត់ជើង :**

- កុំមើលសៀវភៅ ឬ កាសែតក្នុងបន្ទប់ ព្រោះមានគេចាំយើងខាងក្រៅ ។
- រៀបចំខ្លួនឲ្យស្អាតបាតជាស្រេចមុននឹងចេញ ។
- ទុកកន្លែងនោះឲ្យស្អាត ដូចកាលដែលយើងចូលទៅ ។

**ត្រូវការចាកទីប្រជុំជនធំ :**

- ក្នុងទីប្រជុំជនខ្លះ បើយើងជាភ្ញៀវត្រូវការចាកទីនោះដោយខានពុំបាន កុំទៅរំខានគេឯងគ្រប់គ្នា ដោយចាប់ដៃ ឬ សំពះគេទាំងអស់ ៗ ដើរទៅជិតម្ចាស់ផ្ទះហើយខ្សឹបលាគេទៅ សន្មតថាសព្វគ្រប់ហើយ ។ របៀបនេះបារាំងគេថា "គេចតាមរបៀបអង់គ្លេស" ឯអង់គ្លេសវិញគេថា "គេចតាមរបៀបបារាំង" ។

**ចំនួន ១៣ :**

- បរទេសគេខ្លាចចំនួន ១៣ ណាស់ ៗ គេមិនអង្គុយទទួលទានអាហារចំនួន ១៣ នាក់ឡើយ ។
- បរទេសខ្លះចៀសវាង មិនធ្វើដំណើរថ្ងៃសុក្រទី ១៣ ផង ។

**[illegible] :**

- នៅចំពោះមុខគេឯង កុំដកបារីមួយមកទទួលទានតែម្នាក់ឯង ត្រូវហុចជូនបារីទៅគេមុនសិន ។